# របាយការណ៍ស្តីពីសិទ្ធិមនុស្ស នៅកម្ពុជា ឆ្នាំ ២០១៧

## សេចក្តីសង្ខេបរួម

ប្រទេសកម្ពុជាជាប្រទេសប្រកាន់របបរាជានិយមអាស្រ័យធម្មនុញ្ញ ដែលមានរដ្ឋាភិបាលមួយកើតចេញតាមរយៈការបោះឆ្នោតសភា ។ នៅក្នុងការបោះឆ្នោត ដែលរៀបចំធ្វើឡើងនៅ ឆ្នាំ២០១៣ គណបក្សប្រជាជនកម្ពុជា (CPP) បានទទួលបានអាសនៈចំនួន ៦៨ ចំណែកគណបក្សសង្គ្រោះជាតិកម្ពុជា (CNRP) បានទទួលអាសនៈចំនួន ៥៥ ។ អ្នកសង្កេតការណ៍នៃអង្គការមិនមែនរដ្ឋាភិបាល (NGO) ក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិបានវាយតម្លៃថា ដំណើរការបោះឆ្នោតនេះមានខ្វះចន្លោះច្រើន។ ការបោះឆ្នោតក្រុមប្រឹក្សាឃុំនៅពេលថ្មីបំផុតនេះបានប្រព្រឹត្តទៅ នៅថ្ងៃទី ៤ ខែមិថុនា ហើយគណបក្សធំជាងគេទាំងពីរទទួលយកលទ្ធផល។ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិចាត់ទុកការបោះឆ្នោតនេះថា មានលក្ខណៈយុត្តិធម៌ជាងគេ នៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ថ្វីបើអ្នកវិភាគឯករាជ្យភាគច្រើនបានកត់សំគាល់ឃើញថា ដំណើរការបោះឆ្នោតមានការខ្វះចន្លោះច្រើន ដោយចំណោញទៅខាងគណបក្សកាន់អំណាច ដោយឈ្នះបានជាង ២ ភាគ ៣ នៃចំនួនឃុំ។

អាជ្ញាធរស៊ីវិលគ្រប់គ្រងលើកងកម្លាំងសន្តិសុខ ថ្វីបើកំលាំងសន្តិសុខច្រើនគំរាមប្រើកំលាំងប្រឆាំងនឹងអ្នកដែលប្រឆាំងនឹងនាយករដ្ឋមន្ត្រី ហ៊ុន សែន ។

នៅថ្ងៃទី ៣ ខែកញ្ញា រដ្ឋាភិបាលបានចាប់ និងឃុំខ្លួនលោក កឹម សុខា ប្រធានគណបក្សសង្គ្រោះជាតិកម្ពុជា (CNRP) ដោយចោទថាក្បត់ជាតិ។ នៅថ្ងៃទី ១៦ ខែវិច្ឆិកា តុលាការកំពូល ដែលគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា (CPP) បានរំលាយជាផ្លូវការនូវគណបក្ស CNRP ដោយលើកហេតុផលដដែល ហើយបានហាមមិនអោយថ្នាក់ដឹកនាំនៃគណបក្សនេះធ្វើនយោបាយ និងឈរឈ្មោះបោះឆ្នោតចំនួន ៥ ឆ្នាំ។ សមាជិកដទៃទៀតជាច្រើននៃគណបក្សប្រឆាំង ដោយរួមទាំងអ្នកធ្វើការផ្នែកសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ត្រូវបានឃុំខ្លួន លាក់ខ្លួន ឬគេចទៅក្រៅប្រទេស ដោយខ្លាចការចាប់ខ្លួន។

បញ្ហាធំបំផុតផ្នែកសិទ្ធិមនុស្សរួមមានការសំលាប់នៅក្រៅប្រព័ន្ធតុលាការ ។ យ៉ាងហោចណាស់មានមនុស្សម្នាក់បាត់ខ្លួនដោយសារកំលាំងសន្តិសុខមូលដ្ឋាន ការបន្តរំលោភលើអ្នកជាប់ពន្ធនាគាររដ្ឋ ការចាប់ខ្លួនតាមទំនើងចិត្តដោយរដ្ឋាភិបាល ដោយរួមទាំងការចាប់ខ្លួនដោយគ្មានហេតុផលត្រឹមត្រូវលើមេដឹកនាំគណបក្ស CNRP កឹម សុខា ការរឹតត្បឹតកាន់តែច្រើនឡើងលើសេរីភាពក្នុងការបញ្ចេញមតិ ការជួបជុំគ្នា និងការចងក្រងគ្នាជាក្រុម ដោយរួមទាំងសេរីភាពសារព័ត៌មាន និងសេរីភាពក្នុងការបញ្ចេញមតិតាមអ៊ិនធ័រណែត ការប្រើហឹង្សា និងការចាប់ដាក់ពន្ធនាគារ ទាំងធ្វើជាក់ស្តែង ទាំងការគ្រាន់តែគំរាម ដើម្បីបំភិតបំភ័យគណបក្សប្រឆាំង និងសង្គមស៊ីវិល ព្រមទាំងការបង្ក្រាបលើសំ

លេងប្រឆាំង អំពើពុករលួយ ហឹង្សាទៅលើស្ត្រី និងមនុស្សស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់មនុស្សទាំងពីរភេទ និងមនុស្សកែភេទ ការរំលោភបំពានលើកុមារ និងការបង្ខំអោយធ្វើពលកម្ម។

ទោះបីជារដ្ឋាភិបាលកាត់ទោសមន្ត្រីខ្លះដែលបានប្រព្រឹត្តបទរំលោភ រួមទាំងអ្នកដែលមានការពាក់ព័ន្ធនឹងករណីពុករលួយក្តី តែនិទណ្ឌភាពចំពោះការរំលោភភាគច្រើននៅតែមាននៅឡើយ។

**ផ្នែកទី១ ៖ ការគោរពតម្លៃថ្លៃថ្នូររបស់មនុស្ស រួមទាំងសេរីភាពរួចផុតពី ៖**

**ក. ការដកហូតជីវិតតាមអំពើចិត្ត និងការសំលាប់ដោយសារហេតុផលនយោបាយ ឬដោយខុសច្បាប់**

គិតមកត្រឹមខែកក្កដា អង្គការ NGO ដែលមានឈ្មោះថា អាដហុក បានរាយការណ៍ពីករណីសំលាប់ក្រៅប្រព័ន្ធតុលាការចំនួន ៤ ករណី។

នៅខែមិនា តុលាការបានកាត់ទោសអោយឈ្មោះ អឿត អាងជាប់ពន្ធនាគារអស់មួយជីវិត ចំពោះការសំលាប់លោកកែម ឡី ដែលជាអ្នកវិភាគនយោបាយ និងសង្គមដ៏ក្លាហាន និងប្រកបដោយប្រជាប្រិយភាព កាលពីខែកក្កដា ឆ្នាំ ២០១៦។ នគរបាលបានចាប់ខ្លួនអឿតអាង ដែលបានអះអាងថា ខ្លួនបានសំលាប់កែម ឡី ដោយសារកែម ឡីជំពាក់បំណុលគាត់ចំនួន ១២ លានរៀល (៣ពាន់ដុល្លា) មិនព្រមសង។ ទាំងសមាជិកគ្រួសារលោក កែម ឡី ទាំងសមាជិកគ្រួសារអ្នកសំលាប់បាននិយាយថា  បុរសទាំងពីរនាក់នោះមិនបានស្គាល់គ្នាទេ។ ដោយកត់សំគាល់ចំពោះរឿងនេះ និងលក្ខណៈមិនប្រក្រតីដទៃទៀត ដូចជាការដែលបុរសក្រីក្ររូបនេះមានកាំភ្លើងថ្លៃប្រើ អ្នកសង្កេតការណ៍ជាច្រើនជឿថា ភាគីទី ៣ បានជួលអឿត អាង។

តុលាការកាត់ទោសខ្មែរក្រហម (ECCC) ត្រូវបានបង្កើតឡើងដើម្បីចាប់អោយមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនៅក្រោមរបបខ្មែរក្រហម ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ECCC  បន្តការស៊ើបអង្កេត និងការកាត់ក្តី នៅក្នុងឆ្នាំនៃរបាយការណ៍នេះ (សូមមើលផ្នែក ៥)។

**ខ. ការបាត់ខ្លួន**

នៅឆ្នាំ ២០១៤ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយបាននិយាយថា ខែម សុផាតបាត់ខ្លួនបន្ទាប់ពីកំលាំងសន្តិសុខរបស់រដ្ឋាភិបាលត្រូវបានគេនិយាយថា  បានបាញ់គាត់ នៅក្នុងការប៉ះទង្គិចហឹង្សាមួយ នៅក្រៅរោងចក្រកាត់ដេរ Canadia ។ សាក្សីបានឃើញគាត់ត្រូវបានគេលើកដាក់ក្នុងឡានពេទ្យ។ គិតមកដល់ខែកញ្ញា សុផាតនៅបាត់ខ្លួននៅឡើយ។

ព្រះតេជគុណ មាស វិចិត្រ ដែលជាសង្ឃមានឈ្មោះល្បីម្នាក់ បានបាត់ខ្លួននៅថ្ងៃទី ១៨ មិថុនា នៅឃុំក្របីរៀល ខេត្តសៀមរាប។ អាចារ្យដែលនៅជាមួយគាត់មុនពេលគាត់បាត់ខ្លួន បាននិយាយថា មន្ត្រីសន្តិសុខក្របីរៀលបានឃាត់ខ្លួនពួកគាត់ ហើយសំរាតខោអាវ ស្បង់ជីពរ វាយពួកគាត់ ដោយអះអាងថា ពួកគាត់មានព័ត៌មានស្តីពីការសំលាប់លោកកែម ឡី។ ដល់ដំណាច់ឆ្នាំ សង្ឃមាស វិចិត្រនៅបាត់ខ្លួននៅឡើយ។

## គ. ការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬដាក់ទណ្ឌកម្មបន្ថោកបន្ទាប អមនុស្សធម៌ ឬឃោរឃៅដទៃទៀត

រដ្ឋធម្មនុញ្ញហាមប្រាមទង្វើបែបនេះ តែការវាយដំ និងទំរង់ដទៃទៀតនៃការធ្វើបាបលើរូបរាងកាយទៅលើអ្នកជាប់ឃុំរបស់នគរបាល និងអ្នកជាប់ពន្ធនាគារនៅតែមានជាបន្ត នៅក្នុងឆ្នាំនៃរបាយការណ៍។

មានរបាយការណ៍ដែលអាចទុកចិត្តបានថា យោធា និងនគរបាលស៊ីវិលបានធ្វើទារុណកម្មលើរាងកាយ និងផ្លូវចិត្ត ហើយមានពេលខ្លះ វាយដុំយ៉ាងធ្ងន់ធ្ងរទៅលើជនដែលត្រូវឃុំខ្លួនដោយសារបទព្រហ្មទណ្ឌទៀតផង ជាពិសេសនៅអំឡុងពេលសួរចម្លើយ ។ គិតមកដល់ខែកក្កដា អង្គការអាដហុកបានរាយការណ៍ថា អាជ្ញាធរបានធ្វើទារុណកម្មទៅលើអ្នកជាប់ពន្ធនាគារឬអ្នកជាប់ឃុំចំនួន ១០ ករណី ចំណែកនៅក្នុងឆ្នាំ ២០១៦ ទាំងមូលមាន១៥ ករណី។ អង្គការ NGO បានរាយការណ៍ពីការរំលោភធ្វើបាបលើជនសង្ស័យដែលត្រូវបានឃាត់ខ្លួន រហូតទាល់តែពួកគេសារភាពថាបានប្រព្រឹត្តបទល្មើស។

គិតមកត្រឹមខែកក្កដា អង្គការអាដហុកបានរាយការណ៍ពីករណីចំនួន ១៣ ដែលក្នុងនោះ អាជ្ញាធរមូលដ្ឋាន ភ្នាក់ងាររដ្ឋាភិបាល ឬអង្គរក្សឯកជនរបស់មន្ត្រីរដ្ឋាភិបាលបានប្រើកំលាំងវាយដំទៅលើជនស៊ីវិល។

## ស្ថានភាពពន្ធនាគារ និងមជ្ឈមណ្ឌលឃុំខ្លួន

ស្ថានភាពពន្ធនាគារមិនសមស្របតាមបទដ្ឋានអន្តរជាតិឡើយ ។ ស្ថានភាពជាច្រើននៅតែមានលក្ខណៈយ៉ាប់ ហើយក្នុងករណីជាច្រើន គម្រាមកំហែងដល់អាយុជីវិតទៀតផង ។

<u>ទិដ្ឋភាពទីកន្លែង៖</u> ការមានអ្នកទោសច្រើននាំអោយចង្អៀតខ្លាំងគឺជាបញ្ហាមួយ។ យោងតាមអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ ដោយគិតត្រឹមខែកក្កដា មានអ្នកទោស និងអ្នកជាប់ពន្ធនាគារ ចំនួន ប្រមាណជាង ២៦ ០០០ នាក់ នៅក្នុងពន្ធនាគារចំនួន ២៩ ដែលត្រូវបានបង្កើតឡើងដើម្បីដាក់អ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំត្រឹមតែចំនួន ១១ ០០០ នាក់ ។ មន្ត្រីផ្នែកពន្ធនាគារបាននិយាយថា “សង្គ្រាមប្រឆាំងនឹងគ្រឿងញៀន” របស់រដ្ឋាភិបាលបានធ្វើអោយពន្ធនាគារកាន់តែចង្អៀតខ្លាំងឡើង។

នៅក្នុងពន្ធនាគារភាគច្រើន គ្មានការដាក់អោយនៅដាច់ពីគ្នាទេរវាងអ្នកទោសជាមនុស្សពេញវ័យ និងអ្នកទោសជាកុមារ រវាងប្រុស និងស្រី ឬរវាងអ្នកទោសធ្ងន់ និងអ្នកទោសស្រាល ឬសំរាប់ការឃុំមុនសវនាការទេ។ បើយោងតាមមន្ត្រីធនាគារ ក្នុងចំណោមអ្នកទោសទាំង ២១ ៩៨៩ ដែលជាប់ឃុំនៅឆ្នាំ ២០១៦ មានប្រហែល ៣៥% មិនទាន់កាត់ក្តី ២៩% បានទទួលការកាត់ក្តីចុងក្រោយ ហើយប្រហែល ៨% នៃអ្នកទោសគឺជាស្ត្រី និង ៩% ជាអនិតិជន។

បើយោងតាមអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ នារីមានផ្ទៃពោះ និងកូនមួយចំនួនរស់នៅជាមួយម្តាយរបស់គេក្នុងពន្ធនាគារ។

នាយកដ្ឋានពន្ធនាគារបានរាយការណ៍ថា នៅក្នុងឆ្នាំ ២០១៦ មានអ្នកជាប់ពន្ធនាគារចំនួន ៧៦ នាក់បានស្លាប់ក្នុងពន្ធនាគារ។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបានអះអាងថា នៅក្នុងករណីជាច្រើន របបអាហារសម្រាប់អ្នកជាប់ពន្ធនាគារ និងរបស់ចាំបាច់ផ្សេងៗទៀត តែនៅតែមិនគ្រប់គ្រាន់ទេ។ អ្នកសង្កេតការណ៍បានបន្តរាយការណ៍ថា របបសំរាប់ទិញអាហារសំរាប់អ្នកទោស ពេលខ្លះ ត្រូវបានកិបកេងយកដោយអាជ្ញាធរ ដែលជាការធ្វើអោយមានកង្វះអាហារូបត្ថម្ភ និងជំងឺអ្នកទោសមានកាន់តែច្រើន។ អ្នកទោសមានទឹកស្អាតប្រើប្រាស់តែនៅក្នុងពន្ធនាគារចំនួន ១៨ ទេ ក្នុងចំណោមពន្ធនាគារចំនួន ២៩។ ពន្ធនាគារគ្មានកន្លែងគ្រប់គ្រាន់សំរាប់ជនពិការរាងកាយ និងអ្នកឡប់សតិឡើយ។ អង្គការមិនមែនរដ្ឋាភិបាលបានចោទប្រកាន់ថា អ្នកគ្រប់គ្រងពន្ធនាគារប្រព្រឹត្តមិនស្មើគ្នាលើអ្នកទោស ដូចជាករណីផ្តល់ការអនុញ្ញាតអោយអ្នកចូលសួរសុខទុក្ខ ការប្តូរទៅបន្ទប់ល្អ និងឱកាសចេញពីបន្ទប់ នៅពេលថ្ងៃ សំរាប់អ្នកទោសដែលគ្រួសាររបស់គេមានលុយសូក។ បើយោងតាមអង្គការមិនមែនរដ្ឋាភិបាល អ្នកទោសដែលមានការចងក្រងគ្នាគេ ហើយត្រូវបានរៀបចំឡើងនិងដឹកនាំដោយឆ្មាំពន្ធនាគារ ដែលគេហៅថា "គណកម្មាធិការគ្រប់គ្រងខ្លួនឯងរបស់អ្នកទោស" ពេលខ្លះ ធ្វើការវាយដំលើអ្នកទោសដទៃទៀត។ មានសេចក្តីរាយការណ៍ថា មានការប្រើប្រាស់គ្រឿងញៀននៅក្នុងពន្ធនាគារ ដែលគេអាចធ្វើទៅបានដោយសូកប៉ាន់មន្ត្រីពន្ធនាគារ។

មានមជ្ឈមណ្ឌលបន្សាបថ្នាំញៀនរបស់រដ្ឋាភិបាលចំនួន ៧ និងមាន៣ ទៀតជារបស់ឯកជន នៅកម្ពុជា។ អ្នកសង្កេតការភាគច្រើនបានយល់ស្របថា ភាគច្រើននៃអ្នកដែលត្រូវបានយកមកឃុំនៅទីនេះគឺត្រូវបានឃុំដោយបង្ខំ ឬផ្ញើនៅមណ្ឌល ដោយសមត្ថកិច្ច ឬសមាជិកគ្រួសារ ដោយគ្មានឆ្លងកាត់ដំណើរការក្តីត្រឹមត្រូវទេ។ យោងតាមអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គ្មានអ្នកដែលជាប់នៅក្នុងមណ្ឌលមានអាយុក្រោម ១៨ ឆ្នាំទេ។ អ្នកសង្កេតការណ៍បានកត់សំគាល់ឃើញថាបុគ្គលិកក្នុងមណ្ឌលជាញឹកញាប់ប្រើវិធីបង្ខំ ដើម្បី "គ្រប់គ្រង"ទៅលើអ្នកជាប់ក្នុងនោះ ដូចជាចងពួកគេ ឬអោយហាត់ប្រាណយ៉ាងខ្លាំង ។

រដ្ឋបាលៈ អាជ្ញាធរមិនបានប្រើវិធីផ្សេងក្រៅពីការដាក់គុកទេ សំរាប់ជនល្មើសអហឹង្សា។ អ្នកទោស និងអ្នកជាប់ការឃុំឃាំងជាធម្មតាត្រូវបានអនុញ្ញាតអោយជួបជាមួយអ្នកទៅមើល តែអង្គការសិទ្ធិមនុស្សបានអះអាងថា ពេលខ្លះ គ្រួសារត្រូវផ្តល់សំណូកដល់មន្ត្រីពន្ធនាគារដើម្បីបានសួរសុខទុក្ខអ្នកជាប់ពន្ធនាគារ ឬត្រូវផ្តល់ស្បៀងអាហារ និងរបស់របរចាំបាច់ដទៃទៀត ។ មានរបាយការណ៍គួរអោយជឿទុកចិត្តបានថា ជាញឹកញាប់ មន្ត្រីបានទាមទារប្រាក់សំណូក មុននឹងអនុញ្ញាតអោយអ្នកជាប់ពន្ធនាគារចូលរួមការជំនុំជម្រះក្តី ឬសវនាការឧទ្ធរណ៍ និងមុនពេលដោះលែងអ្នកជាប់ពន្ធនាគារដែលបានបញ្ចប់អាណត្តិជាប់ពន្ធនាគាររបស់ខ្លួនពេញលេញហើយនោះ ។

អ្នកទោសអាចដាក់បណ្តឹងស្តីពីការរំលោភបំពានទៅតុលាការ តាមរយៈមេធាវី ដោយមិនមានការត្រួតពិនិត្យកែប្រែឡើយ។ តែអ្នកទោសមួយចំនួនធំគ្មានលទ្ធភាពរកមេធាវីតំណាងផ្លូវច្បាប់ឡើយ។ រដ្ឋាភិបាលស៊ើបអង្កេតលើពាក្យបណ្តឹងបែបនេះ ហើយតាមមើលស្ថានភាពពន្ធនាគារ និងមជ្ឈមណ្ឌលឃុំឃាំង តាមរយៈអគ្គនាយកដ្ឋានពន្ធនាគាររបស់ក្រសួងមហាផ្ទៃ ដែលធ្វើរបាយការណ៍ប្រចាំឆមាសស្តីពីការគ្រប់គ្រងពន្ធនាគារ។ អគ្គនាយកដ្ឋានពន្ធនាគារមិនបញ្ចេញរបាយការណ៍នេះដល់ ទោះបីជាអង្គការសង្គមស៊ីវិលបានធ្វើការស្នើសុំជាញឹកញាប់ក្តី។

ការតាមដានដោយឯករាជ្យៈ ដោយមានលក្ខខ័ណ្ឌជាមុន និងការដាក់កំហិត ជាទូទៅ រដ្ឋាភិបាលបន្តអនុញ្ញាតអោយក្រុមសិទ្ធិមនុស្សអន្តរជាតិ និងក្រុមសិទ្ធិមនុស្សក្នុងស្រុក ដូចជាគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ និងការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UNHCHR) ចូលមើលពន្ធនាគារ និងផ្តល់ការបណ្តុះបណ្តាលសិទ្ធិមនុស្សដល់ឆ្មាំពន្ធនាគារ ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានរាយការណ៍ថា ជួនកាល ការសហការពីអាជ្ញាធរដែនដីនៅមានកម្រិត ដែលជាការធ្វើអោយមានការលំបាកសម្រាប់ទាក់ទងអ្នកជាប់ឃុំដែលមិនទាន់ទទួលការជំនុំជម្រះក្តី ។ រឿងនេះមានជាពិសេសលើករណីធំៗ ដូចជាការឃុំខ្លួនមេដឹកនាំបក្សប្រឆាំង កឹម សុខា និងការចាប់ខ្លួនតាមទំនើងចិត្តលើបុគ្គលិកអង្គការអាដហុកទាំង ៥ នាក់។ ក្រសួងមហាផ្ទៃតម្រូវអោយមេធាវី អ្នកត្រួតពិនិត្យសិទ្ធិមនុស្ស និងអ្នកសួរសុខទុក្ខដទៃទៀតសុំការអនុញ្ញាត មុននឹងចូលជួបអ្នកជាប់ពន្ធនាគារ ហើយក្នុងករណីខ្លះ រដ្ឋាភិបាលតំរូវអោយអង្គការមិនមែនរដ្ឋាភិបាលចុះហត្ថលេខាលើអនុស្សារណនៃការយោគយល់ជាផ្លូវការ ដោយបញ្ជាក់ព្រំដែននៃ “តួនាទី” របស់គេ ក្នុងពេលទៅមើលអ្នកទោស។

ថ្វីបើក្រុមមនុស្សក្នុងស្រុកដែលធ្វើការតាមដានដោយឯករាជ្យ អាចជួបជាលក្ខណៈឯកជនជាមួយអ្នកទោសក្តី តែអ្នកខ្លះក៏មិនអាចជួបបានទេ។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកផ្នែកសិទ្ធិមនុស្សមួយដែលជាធម្មតា ផ្តល់ការថែទាំសុខភាពដល់អ្នកទោស បាននិយាយថា ពេលខ្លះ រដ្ឋាភិបាលមិនអនុញ្ញាតអោយគេចូលមើលអ្នកទោសដែលកាត់ក្តីហើយ និងជាសមាជិកនៃគណបក្សប្រឆាំងឡើយ។ អង្គការបាននិយាយថា រដ្ឋាភិបាលបានចោទខ្លួនថា មានគំនិតលំអៀងនយោបាយ ហើយប្រើការទៅមើលអ្នកទោសដើម្បីជំរុញអ្នកទោសនយោបាយអោយកាន់តែផ្តើនខ្លាំងឡើង។

តំណាងនៃការិយាល័យស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបាននិយាយថា ធម្មតា ខ្លួនអាចជួបជាលក្ខណៈឯកជននៅពេលសម្ភាសន៍អ្នកជាប់ពន្ធនាគារពិសេសណាម្នាក់។

### ឃ. ការចាប់ ឬឃុំខ្លួនតាមអំពើចិត្ត

ច្បាប់ហាមប្រាមការចាប់ឬឃុំខ្លួនតាមអំពើចិត្ត តែពេលខ្លះ រដ្ឋាភិបាលមិនបានគោរពបំរាមទាំងនេះទេ ដូចជាបានធ្វើការឃុំខ្លួនតាមអំពើចិត្តលើបុគ្គលិកនៃអង្គការអាដហុកចំនួន ៤២៧ ថ្ងៃ ក្រោមការចោទប្រកាន់ដែលមានលក្ខណៈនយោបាយ។

### តួនាទីរបស់នគរបាល និងយន្តការសន្តិសុខ

អគ្គស្នងការនគរបាលជាតិ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ គ្រប់គ្រងអង្គភាពនគរបាលស៊ីវិលទាំងអស់ ។ កម្លាំងនគរបាលត្រូវបែងចែកជាកម្លាំងដែលមានអំណាចដើម្បីធ្វើការចាប់ខ្លួន កម្លាំងដែលគ្មានអំណាចចាប់ខ្លួន និងនគរបាលយុត្តិធម៌ ដែលអំណាចរបស់ខ្លួនមានដល់ការអនុវត្តដីការបស់តុលាការ ។ កងរាជអាវុធហត្ថទទួលបានការអនុញ្ញាតអោយចាប់ខ្លួនជនស៊ីវិល ប្រសិនបើមន្ត្រីទាំងនោះបំពេញលក្ខខ័ណ្ឌក្នុងការបណ្តុះបណ្តាល និងបទពិសោធន៍ដើម្បីបំពេញការងារជានគរបាលស៊ីវិល ប្រសិនបើជនស៊ីវិលស្ថិតនៅកន្លែងរបស់យោធា ឬក្នុងករណីទទួលបានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន ។ តែតាមភាពជាក់ស្តែង កងរាជអាវុធហត្ថធ្វើសកម្មភាពលើជនស៊ីវិលជាធម្មតា ក្រោមការអនុញ្ញាតនិងចង្អុលរបស់អាជ្ញាធរខេត្ត និងអាជ្ញាធរមូលដ្ឋាន ដោយជាញឹកញាប់ ដើម្បីជួយនគរបាលស៊ីវិលដែលមិនអាចទប់ទល់នឹងហ្វូងមនុស្សដោយខ្លួនឯងបាន។

មានការនិយាយមកថា មន្ត្រីនគរបាលបានប្រព្រឹត្តអំពើរំលោភបំពានផ្សេងៗដោយមាននិទណ្ឌភាព(ភាពគ្មានទោស) ហើយក្នុងករណីភាគច្រើន អាជ្ញាធរបានចាត់វិធានការបន្តិចបន្តួច ឬពុំមានចាត់វិធានការអ្វីឡើយ ។

គិតមកត្រឹមខែតុលា អង្គការសិទ្ធិមនុស្សសក្នុងស្រុកមួយបានរាយការណ៍ថា មានករណីនិទណ្ឌភាពចំនួន ៣៤ តែបាននិយាយថា តាមពិត ចំនួនគឺមានច្រើនជាងនេះឆ្ងាយ។ ក្រសួងមហាផ្ទៃទទួលខុសត្រូវលើការវាយតំលៃការសំលាប់ដោយកំលាំងសន្តិសុខ ហើយច្បាប់តម្រូវ អោយនគរបាល ព្រះរាជអាជ្ញា និងចៅក្រមធ្វើការស៊ើបអង្កេតរាល់ពាក្យបណ្តឹងទាំងអស់ រួមទាំងបណ្តឹងអំពីការរំលោភបំពានរបស់នគរបាលផងដែរ ។ ទោះជាយ៉ាងនេះក្តី ក្នុងការអនុវត្តជាក់ស្តែង ចៅក្រម និង ព្រះរាជអាជ្ញាកម្រធ្វើការស៊ើបអង្កេតដោយឯករាជ្យណាស់។ ចៅក្រមជំនុំជម្រះ ជាធម្មតាចេញសាលក្រមផ្អែកតាមតែរបាយការណ៍ជាលាយលក្ខណ៍អក្សរ ដែលទទួលបានមកពីនគរបាល និងសក្ខីកម្មរបស់

សាក្សីតែប៉ុណ្ណោះ ។ ជាទូទៅ នគរបាលបានទទួលការបណ្តុះបណ្តាលស្តីពីការការពារ ឬគោរពសិទ្ធិមនុស្សតែបន្តិចបន្តួចប៉ុណ្ណោះ។

## នីតិវិធីចាប់ខ្លួន និងការប្រព្រឹត្តទៅលើអ្នកជាប់ឃុំ

ច្បាប់តម្រូវអោយនគរបាលសុំដីកាពីចៅក្រមស៊ើបអង្កេត មុនធ្វើការចាប់ខ្លួន ប៉ុន្តែនគរបាលអាចចាប់ខ្លួនដោយគ្មានដីកាចំពោះជនណាដែលត្រូវបានប្រទះឃើញកំពុងប្រព្រឹត្តបទល្មើស ។ ជាញឹកញាប់ លើកឡើងពីការលើកលែងនេះ នៅពេលចាប់ខ្លួនឥស្សរជននយោបាយបក្សប្រឆាំង បើទោះបីជាបទល្មើសដែលគេចោទនោះ បានកើតឡើងរាប់ឆ្នាំមកហើយក្តី។ អ្នករិះគន់បានចោទរដ្ឋាភិបាលពីការធ្វើដូច្នេះ ដើម្បីគេចពីច្បាប់ដែលផ្តល់អោយសមាជិកសភានូវអភ័យឯកសិទ្ធិសភា។ ច្បាប់អនុញ្ញាតអោយនគរបាលឃាត់ខ្លួនបុគ្គលណាម្នាក់ រួចធ្វើការស៊ើបអង្កេតក្នុងរយៈពេល២៤ ម៉ោងដោយមិនរាប់បញ្ចូលរយៈ ពេលចុងសប្តាហ៍ និងថ្ងៃឈប់សម្រាកផ្លូវការ មុននឹងធ្វើការចោទប្រកាន់ ឬជនសង្ស័យត្រូវបានដោះលែង ។ ក្នុងករណីបទឧក្រិដ្ឋក្នុងស្ថានភាពពិសេសដែលចែងដោយច្បាប់  នគរបាលអាចឃុំខ្លួនជនសង្ស័យរយៈពេល ២៤ ម៉ោងបន្ថែមដោយមានការឯកភាពពីព្រះរាជអាជ្ញា ។ ទោះជាយ៉ាងនេះក្តីជាទម្លាប់ អាជ្ញាធតែងតែឃុំខ្លួនមនុស្សហួសរយៈពេលកំណត់ មុននឹងធ្វើការចោទប្រកាន់ ។

មានវិធីនៃការធានាអោយនៅក្រៅឃុំ តែអ្នកជាប់ពន្ធនាគារជាច្រើន ជាពិសេសអ្នកដែលគ្មានតំណាងផ្នែកច្បាប់ ឬមេធាវី គ្មានឱកាសស្វែងរកការដោះលែងដោយការធានាអោយនៅក្រៅឃុំឡើយ ។ ជាធម្មតា សេចក្តីស្នើអោយនៅក្រៅឃុំត្រូវបានបដិសេធចំពោះករណីដែលត្រូវបានចាត់ទុកថា បណ្តាលមកពីហេតុផលនយោបាយ។

តាមច្បាប់ ជនជាប់ចោទអាចត្រូវបានចាប់ខ្លួន និងឃុំខ្លួនរហូតដល់រយៈ ពេល ២៤ម៉ោង មុននឹងអាចមានលទ្ធភាពទទួលបានប្រឹក្សាច្បាប់ ប៉ុន្តែអ្នកជាប់ពន្ធនាគារ ជាធម្មតា ត្រូវជាប់ឃុំជាច្រើនថ្ងៃ មុននឹងអាចជួបមេធាវី ឬជួបសមាជិកគ្រួសារ ។ យោងតាមមន្ត្រីរដ្ឋាភិបាល ការឃុំខ្លួនយូរបែបនេះ ភាគច្រើនបណ្តាលមកពីសមត្ថភាពមានកម្រិតរបស់ប្រព័ន្ធតុលាការ ។ រដ្ឋាភិបាលមិនបានផ្តល់មេធាវីសំរាប់ជនជាប់ឃុំដែលក្រីក្រខ្លាំងទេ។

<u>ការចាប់ខ្លួនតាមអំពើចិត្ត៖</u> គិតមកដល់ខែកក្កដា អង្គការអាហុក បាននិយាយថា មានករណីចាប់ខ្លួន ឬឃុំខ្លួនយ៉ាងហោចណាស់ចំនួន ៣៨ ដែលភាគច្រើនជាស្ត្រីដែលចូលរួមនៅក្នុងយុទ្ធនាការ “ថ្ងៃចន្ទពណ៌ខ្មៅ” ដែលបានចាប់ផ្តើមជាការតវ៉ាមួយប្រឆាំងនឹងការឃុំខ្លួនបុគ្គលិកបច្ចុប្បន្ន និងអតីតបុគ្គលិកនៃអង្គការអាដហុកចំនួន ៥ នាក់ តែរដ្ឋាភិបាលបានអះអាងថា ការតវ៉ានេះមានបំណងញុះញង់អោយមាន “បដិវត្តន៍ពណ៌” ដែលជាពាក្យមួយរបស់រដ្ឋាភិបាល សំដៅលើចលនាមហាជនដែលប្រឆាំងនឹងការគ្រប់គ្រងរបស់ខ្លួន។ ២ នាក់ក្នុងចំណោម ៣៨ នោះដែលត្រូវបានចាប់ខ្លួន ត្រូវបានចោទប្រកាន់ជាផ្លូវការ និងត្រូវបានតុលាការដាក់ទោស។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងអង្គការអាដហុក

បាននិយាយថា មានករណីចាប់ខ្លួនតាមអំពើចិត្តចំនួន ៣៥ ទៅលើមនុស្សចំនួន ២១ នាក់ ពីខែឧសភា ឆ្នាំ ២០១៦ ដល់ខែមិនា។ ចំនួននៃការចាប់ខ្លួននិងឃុំខ្លួនតាមអំពើចិត្តទំនងជាមានច្រើនជាងនេះ ពីព្រោះជនរងគ្រោះនៅតាមតំបន់ជនបទមិនប្តឹង ដោយសារមានការពិបាកធ្វើដំណើរមកការិយាល័យរបស់អង្គការអាដហុក ឬមានកង្វល់ពីសុវត្ថិភាពនៃគ្រួសាររបស់គេ។ អាជ្ញាធរមិនបានចាត់វិធានដាក់ទណ្ឌកម្ម ឬវិធានការផ្លូវច្បាប់ប្រឆាំងនឹងអ្នកទទួលខុសត្រូវចំពោះការឃុំខ្លួនគេដោយខុសច្បាប់ទេ។

នៅក្នុងឆ្នាំនៃរបាយការណ៍នេះ អាជ្ញាធរក្រុងភ្នំពេញបានចាប់ខ្លួនមនុស្សរាប់សិបអ្នក ដែលជាធម្មតា គឺអ្នកគ្មានផ្ទះសម្បែង អ្នកវិកលចរិក អ្នកប្រើគ្រឿងញៀន ឬអ្នករកស៊ីផ្លូវភេទ  ក្នុងអំឡុងពេលយុទ្ធនាការចុះបោសសំអាតតាមផ្លូវក្នុងក្រុង។  អាជ្ញាធរយកអ្នកទាំងនោះទៅដាក់នៅមជ្ឈមណ្ឌលព្រៃស្តឹរបស់ក្រសួងសង្គមកិច្ច ដែលមានចំងាយ ១៥ម៉ៃល៍ ពីក្រុងភ្នំពេញ ។ មជ្ឈមណ្ឌលនេះល្បីថា ធ្វើបាបមនុស្ស ដែលធ្វើអោយអ្នកជាប់ឃុំ ២ នាក់ស្លាប់ នៅក្នុងឆ្នាំ ២០១៥។

<u>ការឃុំខ្លួនមុនសវនាការ៖</u> ច្បាប់អនុញ្ញាតអោយមានការឃុំខ្លួនមុនសវនាការរហូតដល់រយៈពេល ៦ ខែ ចំពោះបទល្មើសមជ្ឈិម និង ១៨ ខែ ចំពោះបទឧក្រិដ្ឋ។ នៅឆ្នាំ ២០១៦ ក្រសួងមហាផ្ទៃបាននិយាយថា មានមនុស្សចំនួន ៧៤៩៥ នាក់ស្ថិតក្នុងការឃុំខ្លួនមុនសវនាការ។ ពេលខ្លះ អាជ្ញាធរឃុំមុនសវនាការដោយគ្មានតំណាងផ្នែកច្បាប់ក្តី។ អង្គការមិនមែនរដ្ឋាភិបាលបាននិយាយថា អាជ្ញាធរឃុំអ្នកដែលត្រូវបានចោទពីបទល្មើសស្រាល មុនសវនាការ លើសពីរយៈពេល ៦ ខែ។

<u>លទ្ធភាពរបស់អ្នកជាប់ឃុំក្នុងការចោទសួរពីភាពស្របច្បាប់នៃការឃុំខ្លួនមុនចូលតុលាការ</u>៖ សំណុំរឿងនៅគរមិនទាន់ចាត់ការ និងការពន្យារពេលយូរក្នុងការទទួលបានសាលដីការ ប៉ះពាល់ដល់សិទ្ធិក្នុងការធ្វើការតតាំងនៅក្នុងតុលាការប្រឆាំងនឹងមូលដ្ឋានច្បាប់ ឬលក្ខណៈធ្វើតែតាមទំនើងចិត្តនៃការឃុំខ្លួនមនុស្ស។

### ង. ការបដិសេធមិនអោយទទួលបានការជំនុំជម្រះក្តីជាសាធារណៈដោយយុត្តិធម៌

រដ្ឋធម្មនុញ្ញបានចែងថាតុលាការមានភាពឯករាជ្យ ប៉ុន្តែ រដ្ឋាភិបាល ជាទូទៅ មិនគោរពឯករាជ្យភាពរបស់តុលាការឡើយ ។ តុលាការស្ថិតក្រោមឥទ្ធិពល និងការជ្រៀតជ្រែករបស់ផ្នែកនីតិប្រតិបត្តិ ដែលមានអំណាចដំឡើងសក្តិ បណ្តេញចេញ និងដាក់ពិន័យលើចៅក្រមតាមចិត្ត។ មន្ត្រីតុលាការច្រើនតែមានមុខតំណែងក្នុងពេលជាមួយគ្នានៅក្នុងគណបក្សកាន់អំណាច ហើយអ្នកសង្កេតការណ៍បាននិយាយថា មានតែអ្នកដែលមានទំនាក់ទំនងជាមួយនឹងគណបក្សប្រជាជន ឬផ្នែកប្រតិបត្តិទេ ដែលបានទទួលមុខតំណែងក្នុងតុលាការ។មានអំពើពុករលួយយ៉ាងរាលដាលក្នុង

ចំណោមចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការ ។ ផ្នែកតុលាការគ្មានប្រសិទ្ធិភាព ហើយមិនអាចធានាដំណើរក្តីដោយយុត្តិធម៌ត្រឹមត្រូវបានទេ។

អ្នកសង្កេតការណ៍និយាយថា សមាគមមេធាវីជាតិលំអៀងយ៉ាងខ្លាំងទៅរកសមាជិកដែលមានខ្សែស្រឡាយជាមួយគណបក្សប្រជាជន នៅក្នុងការជ្រើសរើសសមាជិក។ ចំណែកមេធាវីមកពីគណបក្សប្រឆាំងឬក្រុមផ្សេងមិនសូវមានឱកាសទេ។ ពេលខ្លះ សមាគមជ្រើសយកអ្នកដែលគ្មានសមត្ថភាព ដោយសារតែខ្សែស្រឡាយនយោបាយ។ អ្នកវិភាគដោយមិនលំអៀងបានបង្ហាញអោយឃើញថា អ្នកដាក់ពាក្យចូលជាសមាជិកនៅក្នុងសមាគមនេះបានធ្វើការសូកប៉ាន់យ៉ាងច្រើន ដើម្បីបានចូល។ ជាញឹកញាប់ លទ្ធផលនៃសវនាការហាក់មានការកំណត់ទុកជាមុនស្រេច។ ឧទាហរណ៍ នាយករដ្ឋមន្ត្រី ហ៊ុន សែនបានប្រកាសនៅមុនសវនាការរបស់តុលាការកំពូលបន្តិច ស្តីពីការរំលាយគណបក្ស CNRP បន្តិចថា លោកមានការទុកចិត្ត “៩៩,៩៩%” ពីសាលដីការតុលាការនេះ។ មានសេចក្តីរាយការណ៍ថា មេដឹកនាំគណបក្ស CPP ក្នុងមូលដ្ឋានបានទទួលបញ្ជារអោយបណ្តេញភាគីខាងគណបក្ស CNRP ចេញ មុនពេលសាលដីការបានចេញទៅទៀត។ នៅក្នុងករណីមុន អ្នកសង្កេតការណ៍នៅក្នុងសវនាការនៃសកម្មជនរបស់គណបក្សប្រឆាំងចំនួន ១១ រូប ដែលរងការចោទថា បានធ្វើការបះបោរ បាននិយាយថា បន្ទាប់ពីចៅក្រមសំរាកដើម្បីធ្វើការពិចារណា នគរបាលយុត្តិធម៌បានព័ទ្ធបន្ទប់សវនាការ ហើយបានរៀបចំផ្ទេរជនសង្ស័យទៅពន្ធនាគារ ដែលជាការបង្ហាញថាសាលក្រមដាក់អោយជាប់ទោសត្រូវបានកំណត់ជាមុនស្រេចទៅហើយ (សូមមើលត្រង់អ្នកជាប់ឃុំ និងអ្នកទោសនយោបាយខាងក្រោម)។

បើតាមអង្គការ NGO កង្វះចៅក្រម និងបន្ទប់តុលាការបានពន្យាករណីជា ច្រើន។ អង្គការ NGO ក៏ជឿផងដែរថា មន្ត្រីតុលាការច្រើនផ្តោតលើករណីដែលក្នុងនោះ គេបានទទួលលុយ។ការពន្យារពេលរបស់តុលាការ ឬអំពើពុករលួយរបស់តុលាការច្រើនតែធ្វើអោយជនរងការចោទប្រកាន់រួចផុតពីការកាត់ទោស។ អង្គការមិនមែនរដ្ឋាភិបាលបានអះអាងថា ដូចនៅក្នុងឆ្នាំកន្លងទៅដែរ ចុងចោទដែលមានទ្រព្យឬមានអំណាច រួមទាំងសមាជិកនៃកងកំលាំងសន្តិសុខផង តាមធម្មតា បង់លុយអោយជនរងគ្រោះ និងអាជ្ញាធរ ដើម្បីអោយទំលាក់ការចោទប្រកាន់ព្រហ្មទណ្ឌ។ អាជ្ញាធរត្រូវបានគេដឹងថា បានតឿនអោយជនរងគ្រោះ ឬគ្រួសាររបស់គេទទួលយកនូវសំណងប៉ះប៉ូវជាលុយកាក់ ជាថ្នូរនឹងការទំលាក់ចោលការចោទប្រកាន់ព្រហ្មទណ្ឌ ឬការមិនបង្ហាញមុខជាសាក្សី។

**នីតិវិធីជំនុំជម្រះក្តី**

ច្បាប់ចែងពីសិទ្ធិក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌ និងជាសាធារណៈ តែតុលាការកម្រអនុវត្តច្បាប់លើសិទ្ធិនេះណាស់។

តាមច្បាប់ ចុងចោទមានសិទ្ធិត្រូវបានគេសន្មតថា ជាជនស្លូតត្រង់ និងមានសិទ្ធិប្ដឹងឧទ្ធរណ៍ ជារឿយៗចុងចោទត្រូវស្នូកចៅក្រម ដើម្បីអោយចេញសាលក្រមដែលមានលក្ខណៈអនុគ្រោះ ។ សវនាការត្រូវបានធ្វើជាសាធារណៈ តែច្រើនតែត្រូវបានពន្យាពេល ដោយសារការិយាធិបតេយ្យក្នុងតុលាការ។ គេនិយាយថា មន្ត្រីតុលាការខំពន្លឿនការពិនិត្យសំរេចលើសំណុំរឿង។ ចុងចោទមានសិទ្ធិបង្ហាញវត្តមាន ហើយពិគ្រោះយោបល់ជាមួយមេធាវី ប្រឈមនិងចោទសួរសាក្សីប្រឆាំងនឹងខ្លួន ហើយ បង្ហាញសាក្សី និងភស្តុតាងដោយខ្លួនគេ។ ក្នុងករណីព្រហ្មទណ្ឌ ប្រសិនបើចុងចោទគ្មានប្រាក់រកមេធាវីម្នាក់បាន តុលាការត្រូវផ្ដល់តំណាងផ្នែកច្បាប់ដោយឥតគិតថ្លៃដល់ចុងចោទ ។ ទោះជាយ៉ាងណាក៏ដោយ ជារឿយៗ តុលាការតែងតែខ្វះធនធានដើម្បីផ្ដល់ប្រឹក្សាផ្នែកច្បាប់ ហើយចុងចោទភាគច្រើនស្វះស្វែងរកជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ឬត្រូវឡើងតុលាការដោយគ្មានតំណាងផ្នែកច្បាប់ ។ នៅក្នុងករណីគ្មានមេធាវីការពារចុងចោទក្នុងរឿងព្រហ្មទណ្ឌ តុលាការពន្យាករណីរហូតទាល់តែមេធាវីត្រូវបានរកបាន ហើយករណីបែបនេះច្រើនតែស៊ីពេលរាប់ខែ។ ការជំនុំជម្រះក្ដីច្រើនតែធ្វើឡើងគ្រាន់តែបង្គ្រប់កិច្ច ហើយការសួរដេញដោលច្រើនដោយភាគីម្ខាងទៅភាគីម្ខាង ជាធម្មតា មិនបានកើតមានឡើយ ។ ច្បាប់ចែងពីសិទ្ធិទាំងនេះសំរាប់ចុងចោទទាំងអស់។

មានការខ្វះមេធាវីច្រើនដែលមានជំនាញត្រឹមត្រូវ ពិសេសនៅក្រៅក្រុងភ្នំពេញ។ អ្នកដែលគ្មានធនធានសំរាប់រកមេធាវី បាត់បង់សិទ្ធិទទួលបានការកាត់ក្ដីដោយយុត្តិធម៌។ យោងតាមសមាគមនៃគណមេធាវី គិតមកដល់ខែតុលា មានមេធាវីចំនួន ១០១៩ នាក់ (២០៦ នាក់ជានារី) ផ្ដល់សេវាផ្លូវច្បាប់ នៅទូទាំងប្រទេស។ នៅក្នុងឆ្នាំ ២០១៦ មានមេធាវីចំនួន ៨៦៩ នាក់។ របាយការណ៍របស់អង្គការ International Commission of Jurists អោយដឹងថា ការត្រូវធ្វើការស្នូកប៉ាន់ច្រើនដើម្បីបានចូលជាសមាជិកនៃសមាគមមេធាវីធ្វើអោយចំនួនមេធាវីតិច ដែលជាការធ្វើអោយមេធាវីបច្ចុប្បន្នមានឱកាសគ្រប់គ្រាន់ក្នុងការទទួលបានលុយ តាមរយៈមធ្យោបាយស្របច្បាប់ ឬមិនស្របច្បាប់។

អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា ការថ្លែងជាលាយលក្ខណ៍អក្សររបស់សក្សី និងអ្នករងការចោទប្រកាន់ច្រើនតែត្រូវបានយកធ្វើជាភស្តុតាងតែមួយ នៅក្នុងសវនាការ។ ពេលខ្លះ ជនរងការចោទប្រកាន់ត្រូវបានបង្ខំអោយនិយាយ ដោយការវាយដំ ឬការគំរាមកំហែង ហើយចុងចោទដែលមិនចេះអក្សរ ជាញឹកញាប់ មិនត្រូវបានប្រាប់ពីសេចក្ដីនៅក្នុងចំលើយសារភាព ដែលគេត្រូវបានបង្ខំអោយចុះហត្ថលេខាទៅលើនោះទេ។ តុលាការទទួលយកការសារភាពដោយបង្ខំបែបនេះ យកធ្វើជាភស្តុតាង នៅក្នុងសវនាការ ទោះបីជាមានច្បាប់ហាមការធ្វើដូច្នេះក្ដី។ សិទ្ធិរបស់ពលរដ្ឋក្នុងការមានវត្តមាននៅក្នុងសាលាឧទ្ធរណ៍ជាញឹកញាប់មានកំរិត ដោយសារការពិបាកនៅក្នុងការដឹកអ្នកទោសពីពន្ធនាគារខេត្តមកសាលាឧទ្ធរណ៍នៅភ្នំពេញ។ ដូច្នេះ ជាងពាក់កណ្ដាលនៃសវនាការឧទ្ធរណ៍ប្រព្រឹត្តទៅដោយគ្មានវត្តមានរបស់ចុងចោទឡើយ។

**អ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំដោយសារមូលហេតុនយោបាយ**

យោងតាមអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកផ្នែកសិទ្ធិមនុស្សមួយ គិតមកត្រឹមខែវិច្ឆិកា អាជ្ញាធរបានចាប់ខ្លួនឬឃុំខ្លួនមនុស្សយ៉ាងតិចចំនួន ២៤ នាក់ ទាក់ទងនឹងនយោបាយ។

នៅថ្ងៃទី ៣ ខែកញ្ញា នគរបាលបានចាប់ខ្លួនប្រធានគណបក្ស CNRP គឺលោក កឹម សុខា ដោយចោទថាក្បត់ជាតិ។ មន្ត្រីជាន់ខ្ពស់គណបក្ស CNRP បានលាក់ខ្លួន ហើយភាគច្រើនគេចទៅបរទេស។ ហេតុផលដែលរដ្ឋាភិបាលលើកឡើងប្រឆាំងនឹងលោក កឹម សុខាគឺផ្អែកលើវីដេអូ កាលពី ៤ ឆ្នាំមុន ដែលក្នុងនោះ មេបក្សនេះបានប្រាប់ទស្សនិកជន នៅប្រទេសអូស្ត្រាលី ពីការងាររបស់គណបក្សលោក នៅក្នុងការរៀបចំការងារនៅតាមមូលដ្ឋាន ដោយមានការណែនាំពីអ្នកជំនាញបរទេស។ រដ្ឋាភិបាលបានអះអាងថា ការនិយាយដូច្នេះស្មើនឹងការដែលលោក កឹម សុខា "សារភាព" ថាប្រទេសមួយទៀតបានប្រាប់គាត់ពីរបៀបបង្កើត "បដិវត្តន៍ពណ៌" នៅកម្ពុជា។

បន្ទាប់ពីការចាប់ខ្លួនលោក កឹម សុខា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែនបានគំរាមកាត់ទោសអ្នកដែលមានការពាក់ព័ន្ធនៅក្នុងការ "ការពារ" ជនក្បត់ជាតិ ដែលត្រូវបានចោទប្រកាន់។ លោកថែមទាំងបានគំរាមបើកឡើងវិញនូវការស៊ើបអង្កេតទៅលើការសំលាប់សមាជិកសហជីពចំនួន ៥ នាក់ នៅក្នុងការប្រមូលផ្តុំមួយដែលដឹកនាំដោយបក្សប្រឆាំង កាលពីឆ្នាំ ២០១៤ ដែលនៅក្នុងនោះ កម្មករកាត់ដេររាប់ពាន់នាក់បានធ្វើការតវ៉ាលទ្ធផលនៃការបោះឆ្នោតជាតិឆ្នាំ ២០១៣។ ការគំរាមរបស់លោកនាយករដ្ឋមន្ត្រីសំដៅទៅលើអតីតសមាជិកសភាពចំនួន ៧ នាក់របស់គណបក្ស CNRP រួមទាំងអតីតអនុប្រធានគណបក្សនេះ និងជាអ្នកដឹកនាំការតវ៉ា គឺលោកស្រី មូ សុខហួ។ អ្នកទាំងអស់នោះត្រូវបានចាប់ខ្លួន បន្ទាប់ពីការតវ៉ា ក្រោមបទចោទ រាប់ពីការធ្វើបាតុកម្មខុសច្បាប់ដល់ការបះបោរហឹង្សា។ មេដឹកនាំសហជីពឯករាជ្យល្បីឈ្មោះ យ៉ាងហោចណាស់ ៥ នាក់ក៏ស្ថិតនៅក្រោមការគំរាមកំហែងដែរ។ អ្នកទាំងអស់នោះត្រូវបានចោទពីបទបះបោរ ហើយត្រូវបានដាក់អោយស្ថិតនៅក្រោមការតាមដានរបស់តុលាការ។ ថ្វីបើកំលាំងសន្តិសុខត្រូវបានគេជឿថា បានបញ្ជាហើយធ្វើការសំលាប់ តែលោកនាយករដ្ឋមន្ត្រីបានបន្ទោសគណបក្សប្រឆាំងចំពោះហឹង្សាដែលបានកើតឡើង ហើយបានគំរាមចាត់ការទៅលើមេដឹកនាំការតវ៉ា។ លោកនាយករដ្ឋមន្ត្រី និងអ្នកក្រោមបង្គាប់របស់លោកថែមទាំងបានធ្វើការព្រមានជាសាធារណៈ ដល់សមាជិកដទៃទៀតនៃបក្សប្រឆាំងថា គេអាចនឹងត្រូវចាប់ខ្លួនចំពោះ "ការសហការ" ជាមួយលោកកឹម សុខា។ ការរំលាយគណបក្ស CNRP នៅថ្ងៃទី ១៦ ខែវិច្ឆិកាធ្វើអោយការចូលរួមណាមួយជាមួយគណបក្សនេះខុសច្បាប់។

នៅក្នុងករណីដោយឡែក កាលពីថ្ងៃទី ២៣ សីហា សាលាឧទ្ធរណ៍បានយល់ព្រមបំបែកសំណុំរឿងឧទ្ធរណ៍នៃសកម្មជនគណបក្ស CNRP ដេលជាប់ពន្ធនាគារនៅឆ្នាំ ២០១៥ ចំពោះតួនាទីរបស់គេតាមការចោទប្រកាន់មក នៅក្នុងការតវ៉ា ឆ្នាំ ២០១៤ ដែលនាំអោយអ្នកតវ៉ាចំនួន ៦ នាក់ និងឆ្មាំសន្តិសុខខ័ណ្ឌដូនពេញចំនួន ៣៩ នាក់របួស។ តុលការសំរេចថា ករណីមួយពិនិត្យទៅលើសាលដីការ ហើយករណីទី២ នឹងពិចារណាលើការចោទប្រកាន់ស្តីពីនិតិវិធីច្បាប់មិន

សមស្រប។ អ្នកសង្កេតការណ៍ខ្លះអះអាងថា តុលាការចេញសាលដីការដោយគ្មានភស្តុតាងភ្ជាប់សកម្មជនទៅនឹងបទចោទ ហើយចាត់ទុកការដាក់ទោសទៅលើពួកគេថាជាទណ្ឌកម្មចំពោះការដែលសកម្មជនបានធ្វើការរិះគន់ទៅលើការកំណត់ព្រំដែនរបស់ប្រទេសកម្ពុជាជាមួយប្រទេសវៀតណាម ដែលជាបញ្ហាមានលក្ខណៈនយោបាយច្រើន។

សមាជិកសភា អ៊ុំ សំអាន ដែលត្រូវបានចាប់ខ្លួននៃខែមេសា ឆ្នាំ ២០១៦ នៅបន្តស្ថិតនៅក្នុងពន្ធនាគារ ចំពោះការចោទរដ្ឋាភិបាលថា បានលក់ដីអោយវៀតណាម និងចំពោះការផ្សព្វផ្សាយតាមហ្វេសបុកនូវអ្វីដែលរដ្ឋាភិបាលបានអះអាងថា ផែនទីព្រំដែនក្លែងក្លាយ។ ការចោទប្រកាន់នេះត្រូវបានគេមើលឃើញជាទូទៅថា មានលក្ខណៈនយោបាយ។ សមាជិកព្រឹទ្ធសភា ហុង សុខហួ ដែលតុលាការបានដាក់ទោសចំពោះការចោទប្រកាន់ដូចគ្នានេះ បានទទួលការលើកលែងទោស បន្ទាប់ពីបានសុំទោស និងសរសើរការដឹកនាំរបស់នាយករដ្ឋមន្ត្រី។ សមាជិកសភា និងព្រឹទ្ធសភាទាំងពីរនាក់នេះត្រូវបានគេដកអភ័យឯកសិទ្ធិសភា ដោយសភាជាតិ នៅក្នុងការបោះឆ្នោតដោយមិនប្រក្រតីមួយ ដែលទទួលបានសំលេងឆ្នោតមិនដល់ ២ ភាគ ៣ ដូចដែលតំរូវដោយរដ្ឋធម្មនុញ្ញឡើយ។ សភាជាតិក៏បានប្រើវិធីនេះផងដែរនៅក្នុងការដកអភ័យឯកសិទ្ធិរបស់លោក កឹម សុខា។

អ្នកនយោបាយនៃគណបក្សប្រឆាំង និងអង្គការសង្គមស៊ីវិលបាននិយាយថា អាជ្ញាធរច្រើនតែមិនផ្តល់លទ្ធភាពអោយជួបអ្នកទោស ដែលគេជឿថា ទោសរបស់គេនោះបណ្តាលមកពីហេតុផលនយោបាយ។ ក្នុងករណីលោក កឹម សុខា មន្ត្រីធនាគារមិនបានអនុញ្ញាតអោយតំណាងនៃគណបក្ស CNRP សង្គមស៊ីវិល ឬបេសកកម្មបរទេសចូលជួបលោកទេ។ មានតែក្រុមមេធាវីនិងភរិយារបស់លោកទេ ដែលត្រូវបានអនុញ្ញាតអោយចូលជួប ហើយខាងពន្ធនាគារធ្វើការថតវីដេអូនៃការចូលជួបទាំងនោះ។

**នីតិវិធីតុលាការស៊ីវិល និងដំណោះស្រាយ**

ប្រទេសកម្ពុជាមានអង្គតុលាការមួយសម្រាប់បណ្តឹងរដ្ឋប្បវេណី ហើយប្រជាពលរដ្ឋមានសិទ្ធិដាក់ពាក្យបណ្តឹងស្វែងរកសំណងការខូចខាតចំពោះការរំលោភសិទ្ធិមនុស្ស ។ ជាទូទៅ មានទាំងដំណោះស្រាយតាមផ្លូវរដ្ឋបាល ទាំងដំណោះស្រាយតាមផ្លូវតុលាការ តែអាជ្ញាធរច្រើនតែមិនអនុវត្តសាលដីកាតុលាការ។

**សំណងទ្រព្យសម្បត្តិ** (Property Restitution)

នៅខែតុលា ក្រសួងមហាផ្ទៃបានផ្អាកអង្គការ NGO ក្នុងស្រុកដ៏ល្បីមួយ ដែលធ្វើការងារតស៊ូមតិដើម្បីសិទ្ធិដីធ្លី ដោយសារហេតុផលចោទថា រំលោភលើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានប្រកាសអោយប្រើ នៅឆ្នាំ ២០១៥។ នាយកប្រតិបត្តិនៃអង្គការនេះត្រូវបានហៅសួរ ដោយក្រសួងមហាផ្ទៃ និងក្រសួងការងារ។

ការបង្ខំយកមកដាក់ជាសមូហភាព នៅក្រោមរបបខ្មែរក្រហម និងការផ្លាស់ទីលំនៅរបស់ប្រជាជនបានធ្វើអោយកម្មសិទ្ធិដីធ្លីមានភាពមិនច្បាស់លាស់។ ច្បាប់ភូមិបាលចែងថា អ្នកដែលមានកម្មសិទ្ធិដោយសុខសាន្តលើដីឯកជន ឬដីរដ្ឋ (មិនរាប់បញ្ចូលដីសាធារណៈ ដូចជាសួនច្បារ) ឬបានរស់នៅក្នុងអាគាររដ្ឋដោយគ្មានការតវ៉ាទាមទារពីអ្នកផ្សេង ក្នុងរយៈពេល ៥ឆ្នាំ មុនការប្រកាសអោយប្រើច្បាប់នេះ នៅឆ្នាំ ២០០១ មានសិទ្ធិដាក់ពាក្យសុំកម្មសិទ្ធិលើដី/អាគារនោះជាស្ថាពរ។ តែ ប្រជាជនភាគច្រើននៅតែខ្វះការយល់ដឹងនិងមធ្យោបាយសំរាប់ទទួលបានឯកសារកម្មសិទ្ធិដីធ្លីជាផ្លូវការគ្រប់គ្រាន់។

ការិយាល័យសុរិយោដីខេត្តនិងស្រុកបន្តធ្វើតាមនិតិវិធីនៃការចុះបញ្ជីដីមុនឆ្នាំ ២០០១ ដែលមិនបញ្ចូលការសិក្សាអង្កេតបានត្រឹមត្រូវលើដី ឬឱកាសសំរាប់អោយសាធារណជនផ្តល់មតិ។ ការទិញដីទុកលក់ ដោយគ្មានប័ណ្ណកម្មសិទ្ធិច្បាស់លាស់ បានបណ្តាលអោយមានជំលោះ នៅគ្រប់ខេត្តទាំងអស់ ហើយបានបង្កើនភាពតានតឹងរវាងអ្នកភូមិក្រីក្រតាមជនបទ និងឈ្មួញទិញលក់ដី។ សហគមន៍រស់នៅតាមតំបន់ក្រុងប្រឈមនឹងការបណ្តេញចេញដោយបង្ខំ ដើម្បីយកកន្លែងសំរាប់គំរោងអភិវឌ្ឍន៍ពាណិជ្ជកម្ម។

ករណីអាជ្ញាធរបានបន្តបង្ខំអោយអ្នកស្រុកផ្លាស់ទីលំ ទោះបីក្នុងប៉ុន្មានឆ្នាំមកនេះ មានការថយចុះក្តី។ អ្នកខ្លះប្រើការគំរាមកំហែងប្តឹង ឬបណ្តេញចេញ ដើម្បីសំឡុតអ្នកក្រ និងអ្នកស្ថិតក្នុងស្ថានភាពខ្សត់ខ្សោយ អោយទូទាត់សំណងដីរបស់គេ នៅក្នុងតំលៃក្រោមតំលៃទីផ្សា។ ដោយគិតមកត្រឹមខែកក្កដា អង្គការអាដហុកបាននិយាយថា បានទទួលសំណុំរឿងថ្មីទាក់ទងនឹងជំលោះដីធ្លីរវាងអ្នករកស៊ី និងអ្នកភូមិ ចំនួន ៤៥ ករណី ដែលរួមមានការចោទពីការចាប់យកដី ការលួចធនធានធម្មជាតិ ដីសម្បទានសេដ្ឋកិច្ច និងការបណ្តេញចេញពីដីធ្លី។ អ្នកក្រគ្មានឯកសារផ្លូវច្បាប់សំរាប់បញ្ជាក់លើអំណះអំណាងរបស់គេលើដីទេ។ អ្នកដែលរងការបណ្តេញចេញខ្លះបានតវ៉ាបានជោគជ័យនៅតុលាការ តែករណីភាគច្រើនមិនទាន់ត្រូវបានគេចាត់ការទៅលើទេ។

### ច. ការជ្រៀតជ្រែកតាមអំពើចិត្តក្នុងភាពឯកជន គ្រួសារ គេហដ្ឋាន ឬក្នុងការឆ្លើយឆ្លងគ្នា

ច្បាប់មានចែងអំពីភាពឯកជននៃលំនៅដ្ឋាន និងការឆ្លើយឆ្លងគ្នា ហើយហាមឃាត់ការឆែកឆេរខុសច្បាប់ ។ ទោះជាយ៉ាងណាក៏ដោយក៏អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថាជាទម្លាប់ នគរបាលធ្វើការ ឆែកឆេរ និងរឹបអូស ដោយគ្មានដីកាពីតុលា ។ រដ្ឋាភិបាលបានដាក់កាមេរ៉ាថតនៅកន្លែងគណកម្មាធិការបោះឆ្នោតជាតិ ដែលមានភាព

អព្យាក្រឹតផ្នែកនយោបាយ ហើយជាធម្មតា បញ្ចេញសារឆ្លើយឆ្លងផ្ទាល់ខ្លួន ហើយថតការនិយាយឆ្លើយឆ្លងតាមទូរស័ព្ទ របស់មេដឹកនាំបក្សប្រឆាំង និងមេដឹកនាំសង្គមស៊ីវិល ហើបញ្ចេញទៅអោយប្រព័ន្ធផ្សព្វផ្សាយដែលត្រូវគ្នាជាមួយរដ្ឋាភិបាល។ នគរបាលដែលចាប់លោក កឹម សុខា នៅថ្ងៃទី ៣ កញ្ញា ត្រូវបានគេនិយាយថា បានចូលផ្ទះគាត់ដោយប្រើកំលាំង ហើយគ្មានដីការតុលាការទេ។

## ផ្នែកទី២ ៖ ការគោរពសេរីភាពពលរដ្ឋ ដែលរួមមាន

### ក. សេរីភាពបញ្ចេញមតិ និងសេរីភាពសារព័ត៏មាន

ថ្វីបើរដ្ឋធម្មនុញ្ញមានចែងពីសេរីភាពបញ្ចេញមតិ រួមទាំងសេរីភាពផ្នែកសារព័ត៏មានក្តី តែ នៅក្នុងការអនុវត្ត ជាក់ស្តែង សិទ្ធិទាំងនេះមិនត្រូវបានគោរពជានិច្ចឡើយ ។

<u>សេរីភាពក្នុងការបញ្ចេញមតិ</u>

រដ្ឋធម្មនុញ្ញអនុញ្ញាតអោយមានការបញ្ចេញមតិដោយសេរី លើកលែងតែក្នុងករណីដែលវាប៉ះពាល់ដល់សន្តិសុខសាធារណៈ ។ រដ្ឋធម្មនុញ្ញក៏ប្រកាសផងដែរថា ព្រះមហាក្សត្រ “មិនអាចត្រូវគេរំលោភបាន” ហើយសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ដែលអនុលោមតាមច្បាប់បរិហាកេរ្តិ៍ បញ្ជាក់ជាថ្មីនូវដែនកំណត់ទាំងនេះ ហើយហាមប្រាមមិនអោយអ្នកបោះពុម្ព និងនិពន្ធនាយកផ្សព្វផ្សាយរឿងណា ដែលប្រមាថ និងបរិហាកេរ្តិ៍ព្រះមហាក្សត្រ ថ្នាក់ដឹកនាំនិងស្ថាប័នរដ្ឋាភិបាល ។

ច្បាប់បោះឆ្នោតមានខដែលតំរូវអោយអង្គការសង្គមស៊ីវិលមានភាព “អព្យាក្រិត” នៅក្នុងអំឡុងពេលនៃយុទ្ធនាការនយោបាយ ហើយហាមពួកគេមិនអោយ “ប្រមាថ” គណបក្សនយោបាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ។

រដ្ឋាភិបាលបានប្រើក្រមព្រហ្មទណ្ឌដើម្បីកាត់ទោសពលរដ្ឋពីបទបទបរិហារកេរ្តិ៍ ផ្សាយព័ត៌មានមិនពិត និងញុះញង់ ដែលអាចនាំដល់ការដាក់ពន្ធនាគាររហូតដល់ ៣ ឆ្នាំ។ ចៅក្រមក៏អាចបញ្ជាអោយបង់ការផាកពិន័យផងដែរ ដែលអាចនាំអោយមានការចាប់ដាក់ពន្ធនាគារ បើមិនបង់ទេ។ តុលាការបានបកស្រាយក្នុងលក្ខណៈទូលំទូលាយនូវទោស “ញុះញង់” ហើយមន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋាភិបាលបានគំរាមឥស្សរជនគណបក្សប្រឆាំង ពីបទញុះញង់ ដោយសារអំពើ ដូចជាការអំពាវនាវអោយមាន “ការផ្លាស់ប្តូរក្នុងរដ្ឋាភិបាល” តាមមធ្យោបាយបោះឆ្នោត។

អង្គការ NGO ក្នុងស្រុកផ្នែកសិទ្ធិមនុស្សមួយ ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកវិភាគឯករាជ្យមួយចំនួនបានបន្តសំដែងកង្វល់ជាសាធារណៈអំពីសកម្មភាពរបស់រដ្ឋាភិបាលដែលដៅលើការងាររបស់គេ ដោយរួមទាំងករណីប្រឆាំងនឹងមន្ត្រីសមាគមអាដហុកផងដែរ។ នៅថ្ងៃទី ១៣ កញ្ញា អាជ្ញាធរបានចាប់ខ្លួនឈ្មោះ Dem Kundy និងហ៊ុន វណ្ណៈ

ដែលធ្វើការអោយអង្គការមិនមែនរដ្ឋាភិបាលមួយឈ្មោះអង្គការ Mother Nature ពីបទចោទថា បានញុះញង់អោយប្រព្រឹត្តបទឧក្រិដ្ឋ ហើយរំលោភទៅលើភាពឯកជន ដោយថតវីដេអូសកម្មភាពបូមខ្សាច់ នៅខេត្តកោះកុង ដែលជាបញ្ហាបរិស្ថានមានភាពរសើបផ្នែកនយោបាយ។

<u>សេរីភាពសារព័ត៌មាន៖</u> កាសែតជាភាសាខ្មែរភាគច្រើនទទួលបានការគាំទ្រថវិកាពីបុគ្គលដែលស្និទ្ធនឹងគណបក្សប្រជាជនដែលកំពុងដឹកនាំប្រទេស ។

នៅថ្ងៃទី ៤ កញ្ញា កាសែត *The Cambodia Daily* ដែលជាកាសែតឯករាជ្យជាភាសាអង់គ្លេស បានធ្វើការបោះពុម្ពដោយគ្មានអាក់ តាំងពីឆ្នាំ ១៩៩៣ មក បានបិទ មួយសប្តាហ៍បន្ទាប់ពីបានទទួលការព្រមានពីរដ្ឋាភិបាលអោយបង់ពន្ធជំពាក់ ដែលមានតំលៃជាង ៦ លានដុល្លា។ប្រធានផ្នែកសារព័ត៌មានរបស់កាសែតនេះបានអះអាងថា រដ្ឋាភិបាលបានប្រើការចោទប្រកាន់ពីបទគេចពន្ធ ធ្វើជាលេសដើម្បីបិទសេរីភាពសារព័ត៌មានឯករាជ្យ នៅក្នុងប្រទេស។ អាជ្ញាធរមិនព្រមបង្ហាញព័ត៌មានលំអិតស្តីពីការចោទប្រកាន់ទាក់ទងនឹងពន្ធ ហើយព័ត៌មានស្តីពីពន្ធដែលមិនទាន់បានបង់ក៏បានផ្សាយយ៉ាងឆាប់ដល់ប្រព័ន្ធផ្សព្វផ្សាយដែលគ្រប់គ្រងដោយរដ្ឋាភិបាល ទោះបីជាមានច្បាប់អោយរដ្ឋាភិបាលព្យាយាមធ្វើការដោះស្រាយបញ្ហានៃការមិនគោរពតាមពន្ធ ជាលក្ខណៈឯកជនក្តី។

កាសែតចំនួន ៣ ដែលបោះពុម្ពច្រើនជាងគេ ហើយគាំទ្រគណបក្សប្រជាជន មិនដែលរិះគន់រដ្ឋាភិបាលបញ្ហាសិទ្ធិមនុស្ស ឬបញ្ហាដែលមានលក្ខណៈនយោបាយទេ។ គិតមកត្រឹមខែសីហា គ្មានកាសែតប្រឆាំងចេញទៀងទាត់ទេ ហើយរដ្ឋាភិបាលធ្វើការរឹតត្បិតលើសំលេងប្រឆាំងតាមប្រព័ន្ធអ៊ិនធ័រណែត និងប្រព័ន្ធផ្សព្វផ្សាយសង្គម។

រដ្ឋាភិបាល កងកំលាំងយោធា និងគណបក្សនយោបាយកាន់អំណាចបានបន្តមានឥទ្ធិពលលើប្រព័ន្ធផ្សព្វផ្សាយ។ ស្ថានីយ៍វិទ្យុ និងស្ថានីយ៍ទូរទស្សន៍ភាគច្រើន ស្ថិតក្រោមការគ្រប់គ្រង ឬក្រោមឥទ្ធិពលយ៉ាងខ្លាំងរបស់គណបក្សប្រជាជនកម្ពុជា ។ នៅខែសីហា រដ្ឋាភិបាលបានបិទស្ថានីយ៍វិទ្យុមហានគរដែលស្និទ្ធនឹងគណបក្ស CNRP ហើយបានបិទស្ថានីយ៍ទាំងអស់ដែលផ្សាយព័ត៌មានរបស់វិទ្យុសំលេងសហរដ្ឋអាមេរិក VOA និងសំលេងប្រជាធិបតេយ្យ ដោយអះអាងថា ស្ថានីយ៍ទាំងនោះបានរំលោភច្បាប់ដោយគេចមិនបង់ពន្ធ និងមិនបានទទួលការអនុញ្ញាតពីក្រសួងព័ត៌មានមុនពេលផ្សាយព័ត៌មានថ្មីៗ។ យោងតាមអង្គការ NGO មួយដែលតាមដានប្រព័ន្ធផ្សព្វផ្សាយ ជាធម្មតា រដ្ឋាភិបាលប្រើទូរទស្សន៍រដ្ឋដើម្បីផ្សាយពីសកម្មភាពរបស់រដ្ឋាភិបាល និងគណបក្ស CPP និងដើម្បីរិះគន់គណបក្សប្រឆាំង ដោយមិនផ្តល់លទ្ធភាពស្មើគ្នាអោយគណបក្សប្រឆាំងឡើយ។ នៅខែកញ្ញា ទី ១២ វិទ្យុអាស៊ីសេរី បានប្រកាសពីការបិទការិយាល័យរបស់ខ្លួននៅកម្ពុជា ដោយលើកឡើងពីការយាយីតាមផ្លូវច្បាប់ និងការបង្ក្រាបរបស់រដ្ឋាភិបាលទៅលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ នៅមុនពេលបោះឆ្នោតជាតិ។ នៅថ្ងៃទី ១៤ វិច្ឆិកា អាជ្ញធរបានចាប់ខ្លួនអតីតអ្នកយក

ព័ត៌មានអោយវិទ្យុអាស៊ីសេរីចំនួន ២ រូប ដោយចោទពីបទធ្វើចារកម្ម និងចោទថាបានជួយបង្កើត "បដិវត្តន៍ពណ៌" នៅកម្ពុជា។ ការចោទប្រកាន់នោះត្រូវបានគេមើលឃើញជាទូទៅថា មានលក្ខណៈនយោបាយ។

អាជ្ញាធរមិនដែលអនុញ្ញាតអោយគណបក្ស CNRP បើកស្ថានីយ៍វិទ្យុរបស់ខ្លួនទេ ទោះបីមានកិច្ចព្រមព្រៀងពីរដ្ឋាភិបាលដែលផ្តល់ការអនុញ្ញាតក្តី។

<u>អំពើហឹង្សា និងការយាយី៖</u> ហឹង្សា និងការគំរាមកំហែងលើអ្នកសារព័ត៌មាននៅមានច្រើននៅឡើយ។ នៅខែឧសភា អាជ្ញាធរមូលដ្ឋាន នៅខេត្តរតនគីរី បានឃុំខ្លួនអ្នកកាសែតចំនួន ៦ នាក់មួយរយៈខ្លី ដោយសារពួកគេយកព័ត៌មានស្តីពីការកាប់ឈើនៅតំបន់អភិរក្សជីវសាស្ត្រចំរុះដែនសីមា។ នៅថ្ងៃទី ២៨ ខែសីហា  អាជ្ញាធរបានចោទប្រកាន់អ្នកកាសែត Cambodia Daily ពីរនាក់ពីបទ "ញុះញង់អោយមានហឹង្សា" ចំពោះការយកព័ត៌មានទាក់ទងនឹងការបោះឆ្នោត នៅរតនគីរី។

<u>ការចាប់ពិរុទ្ធ ឬការដាក់កំហិតលើសេចក្តីក្នុងអត្ថបទ៖</u> ច្បាប់ហាមការចាប់ពិរុទ្ធមុនបោះពុម្ពផ្សាយ ហើយគ្មានប្រព័ន្ធចាប់ពិរុទ្ធផ្លូវការទេ។ តែរដ្ឋាភិបាលបានប្រើកាន់តែច្រើនឡើងនូវមធ្យោបាយផ្សេងទៀត ដើម្បីធ្វើការចាប់ពិរុទ្ធលើប្រព័ន្ធផ្សព្វផ្សាយ និងប្រព័ន្ធផ្សព្វផ្សាយសង្គម បន្ទាប់ពីលោក កែម ឡីត្រូវបានសំលាប់ បន្ទាប់ពីមានការចាប់ខ្លួនអ្នករិះគន់រដ្ឋាភិបាល តាមរយៈការគំរាមរបស់រដ្ឋាភិបាល រួមទាំងលោកនាយករដ្ឋមន្ត្រីផង។ វិធីដែលគេប្រើរួមមានការយាយី និងការសំឡុត។ ដោយសាររដ្ឋាភិបាលគ្រប់គ្រងលើច្បាប់អនុញ្ញាតនិងអាជ្ញាប័ណ្ណសំរាប់អ្នកសារព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយភាគច្រើន ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋាភិបាលឬគណបក្ស CPP បានធ្វើការចាប់ពិរុទ្ធលើខ្លួនឯងខ្លះ។ អ្នកយកព័ត៌មាន និងនិពន្ធនាយកខ្លះបានសារភាពថាបានបង្អង់ដៃក្នុងការសរសេររបស់គេ ដោយខ្លាចរដ្ឋាភិបាលធ្វើការសងសឹក។ ផ្នែកសារព័ត៌មានខ្លះបាននិយាយថា បានទទួលការហៅទូរស័ព្ទពីក្រសួងមហាផ្ទៃ ដែលគំរាមដកអាជ្ញាប័ណ្ណ បើគេមិនព្រមបញ្ឈប់ការផ្សាយខ្លឹមសារដែលសរសេរដោយគណបក្សប្រឆាំង និងកម្មវិធីរបស់វិទ្យុ VOA, RFA និង VOD។

<u>ច្បាប់បរិហារកេរ្តិ៍៖</u> រដ្ឋាភិបាលប្រើច្បាប់បរិហារកេរ្តិ៍ និងផ្តល់ព័ត៌មានមិនពិតដើម្បីធ្វើការរឹតត្បិតលើការពិភាក្សាគ្នាជាសាធារណៈលើបញ្ហាដែលរដ្ឋាភិបាលគិតថាមានភាពរសើប ឬប្រឆាំងនឹងផលប្រយោជន៍របស់ខ្លួន។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែនបានប្តឹងអ្នកវិភាគនិងជាអ្នកធ្វើអត្ថាធិប្បាយនយោបាយ គឹម សុខ ចំពោះការចោទប្រកាន់តាមអ៊ិនធ័រណែតរបស់គាត់ថា រដ្ឋាភិបាលមានការពាក់ព័ន្ធនៅក្នុងការសំលាប់លោក កែម ឡី។ នៅខែសីហា តុលាការបានកាត់ទោសអោយលោក គឹម សុខជាប់ពន្ធនាគារចំនួន ១៨ ខែ ហើយពិន័យគាត់នូវប្រាក់ចំនួន ៨00 លានរៀល (២ សែនដុល្លា)។

សន្តិសុខជាតិ៖ រដ្ឋាភិបាលតែងតែលើកឡើងពីកង្វល់សន្តិសុខជាតិធ្វើជាហេតុផលនៃការរឹតត្បិតលើសិទ្ធិរបស់ពលរដ្ឋដែលរិះគន់មន្ត្រី និងនយោបាយរដ្ឋាភិបាល។ ដោយឡែក រដ្ឋាភិបាលតែងតែគំរាមកាត់ទោស និងចាប់ខ្លួនអ្នកដែលចោទសួរពីការកំណត់ព្រំដែនរបស់រដ្ឋាភិបាលជាមួយប្រទេសវៀតណាម ឬអ្នកដែលនិយាយថា រដ្ឋាភិបាលបានកាត់ដីអោយវៀតណាម ។

**សេរីភាពអ៊ីនធឺណែត**

រដ្ឋាភិបាលបានដាក់កំហិតនិងបង្អាក់លើការទទួលបានអ៊ិនធ័រណែតប្រើ ចាប់ពិរុទ្ធលើខ្លឹមសារបង្ហោះតាមអ៊ិនធ័រណែត ហើយមានសេចក្តីរាយការណ៍ដ៏គួរអោយទុកចិត្តបានថា ស្ថាប័នរដ្ឋាភិបាលបានតាមដានការទាក់ទងគ្នាជាឯកជន តាមអ៊ិនធ័រណែត។ បើយោងតាមក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍ ជាង ៣១% នៃប្រជាជនកម្ពុជាមានប្រើសេវាអ៊ិនធ័រណែត ពិសេសអ្នករស់នៅតាមតំបន់ក្រុង។

ច្បាប់ស្តីពីទូរគមនាគមន៍ត្រូវបានគេរិះគន់ជាទូទៅ ដោយសកម្មជនសិទ្ធិមនុស្ស និងសង្គមស៊ីវិលធំៗនៅក្នុងប្រទេស ដែលបានអះអាងថា វាផ្តល់អោយរដ្ឋាភិបាលនូវអំណាចទូលំទូលាយក្នុងការលួចស្តាប់ការពិភាក្សាជាសាធារណៈតាមអ៊ិនធ័រណែត ដោយប្រើឧបករណ៍ទាក់ទងគ្នាជាឯកជន។ យោងតាមអង្គការសិទ្ធិមនុស្សលីកាដូ រដ្ឋាភិបាលមានអំណាចតាមផ្លូវច្បាប់ក្នុងការតាមដានគ្រប់ការសន្ទនាតាមទូរស័ព្ទ សារតាមទូរស័ព្ទ អ៊ីម៉ែល សកម្មភាពតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងការឆ្លើយឆ្លងរបស់បុគ្គល ដោយគ្មានការយល់ព្រមឬដឹងពីពួកគេ។ មតិសំដែងដែលត្រូវបានគេគិតថា រំលោភលើន័យសន្តិសុខជាតិដែលកំណត់ដោយរដ្ឋាភិបាល អាចនាំដល់ការចាប់ដាក់ពន្ធនាគាររហូតដល់ ១៥ឆ្នាំ។

គិតមកត្រឹមខែតុលា អង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សក្នុងស្រុកមួយបានអះអាងថា មានករណីចាប់ខ្លួនមនុស្សយ៉ាងតិច ៥នាក់ ដោយសារសារដែលគេបានបង្ហោះតាមអ៊ិនធ័រណែត។ នារីម្នាក់រងការគំរាមកំហែងដោយរដ្ឋាភិបាល នៅខែមេសា ដោយសារបង្ហោះវីដេអូនៃរូបនាងយកស្បែកជើងគប់ផ្ទាំងប៉ាណូដែលមានរូបលោកនាយករដ្ឋមន្ត្រី។

"ក្រុមសង្គ្រាមតាមប្រព័ន្ធអ៊ិនធ័រណែត" នៅក្នុងអង្គភាពប្រតិកម្មរហ័សនិងផ្នែកសារព័ត៌មានរបស់ទីស្តីការគណរដ្ឋមន្ត្រី មាននាទីតាមដាន និងប្រឆាំងនឹងព័ត៌មាន "មិនត្រឹមត្រូវ" ពីផ្នែកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ អង្គភាពប្រតិកម្មរហ័សមាននាទីទទួលខុសត្រូវក្នុងការផ្សាយវីដេអូដែលនិយាយថា សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងគណបក្សប្រឆាំងឃុបឃិតជាមួយមហាអំណាចបរទេស ដើម្បីផ្តួលរំលំរដ្ឋាភិបាល។ រដ្ឋាភិបាលច្រើនប្រើវីដេអូទាំងនេះធ្វើជាហេតុផលសំរាប់បង្ក្រាបទៅលើអ្នកដែលប្រឆាំងនឹងការគ្រប់គ្រងរបស់លោកនាយករដ្ឋមន្ត្រី។

## សេរីភាពខាងការសិក្សាអប់រំ និងពិធីវប្បធម៌

ជាទូទៅ រដ្ឋាភិបាលពុំមានរឹតត្បិតសេរីភាពផ្នែកការសិក្សាអប់រំឬពិធីវប្បធម៌ឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ក៏អ្នកធ្វើការក្នុងផ្នែកសិក្សាអប់រំច្រើនមានការប្រុងប្រយ័ត្ន នៅពេលបង្រៀនមុខវិជ្ជាពាក់ព័ន្ធនឹងនយោបាយ ដោយសារខ្លាចប៉ះពាល់អ្នកនយោបាយ ។ មានគ្រូជាច្រើនធ្វើការចាប់ពិរុទ្ធលើខ្លួនឯង ឬសំដែងមតិជាលក្ខណៈមិនបញ្ចេញឈ្មោះ។ នៅខែឧសភា ក្រសួងអប់រំបានរំលឹកដល់គ្រឹះស្ថានអប់រំរដ្ឋ និងឯកជន ពីច្បាប់ដែលហាមការពិភាក្សា និងសកម្មភាពនយោបាយទាំងអស់ នៅក្នុងសាលា។ មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលរំលឹកស្ថាប័នអប់រំសាធារណៈម្តងទៀតពីច្បាប់នេះ នៅមុនពេលបោះឆ្នោតឃុំសង្កាត់ នៅថ្ងៃទី ៤ មិថុនា។ សកម្មជនជាច្រើនបានអះអាងថា ច្បាប់នេះមានបំណងរាំងខ្ទប់ការគាំទ្ររបស់យុវជនចំពោះគណបក្សប្រឆាំង ដោយបន្ថែមថា ភាគច្រើននៃនាយកសាលាគាំទ្រគណបក្ស CPP ។មន្ត្រីរដ្ឋាភិបាលហាក់ដូចជាលើកលែងអង្គការធំៗមួយចំនួននៅតាមសាលា ដែលមានការទាក់ទងជាមួយគណបក្សកាន់អំណាច រួមទាំងអង្គការមួយដែលដឹកនាំដោយកូនរបស់នាយករដ្ឋមន្ត្រី ដោយលើកឡើងថាអង្គការទាំងនោះគឺជាក្រុម “ក្រៅការសិក្សា” ដែលជំរុញ “បុព្វហេតុមនុស្សធម៌”។ នៅខែសីហា អភិបាលស្រុកម្នាក់ នៅខេត្តបាត់ដំបង បានបណ្តេញនាយករងវិទ្យាល័យម្នាក់ ដោយចោទថា បានបង្រៀន “នយោបាយ”។

## ខ. សេរីភាពប្រមូលផ្តុំគ្នា និងសេរីភាពបង្កើតអង្គការ/សមាគម

### សេរីភាពប្រមូលផ្តុំគ្នា

រដ្ឋធម្មនុញ្ញមានចែងពីសេរីភាពប្រមូលផ្តុំគ្នាដោយសន្តិវិធី ប៉ុន្តែមានពេលខ្លះ រដ្ឋាភិបាលមិនបានគោរពសិទ្ធិនេះទេ ។

ច្បាប់ស្តីពីអង្គការ សមាគមតំរូវអោយអង្គការ សមាគមទាំងអស់ចុះបញ្ជី ហើយតំរូវអោយមានការប្រាប់ជាមុននូវការប្រជុំ ការបើកវគ្គរៀនសូត្រ ការតវ៉ា ការដើរក្បួន ឬបាតុកម្ម តែអាជ្ញាធរមិនបានអនុវត្តបានខ្ជាប់ខ្ជួនលើការទាមទារនេះទេ។ ខមួយចែងពីការត្រូវជំរាបប្រាប់ចំនួន ៥ ថ្ងៃមុន សំរាប់ការធ្វើបាតុកម្មដោយសន្តិវិធីភាគច្រើន ចំណែកខមួយទៀតចែងពីការតំរូវអោយជូនដំណឹងចំនួន ១២ ម៉ោងមុន សំរាប់ការប្រមូលផ្តុំគ្នាដោយមិនមានការគ្រោងទុក នៅលើទីកន្លែង ឯកជន ឬសំរាប់ការតវ៉ានៅកន្លែងកំណត់ ហើយកំរិតចំនួនអ្នកចូលរួមត្រឹម ២០០ នាក់។ តាមច្បាប់ អាជ្ញាធរខេត្ត និងអាជ្ញាធរក្រុងមានអំណាចសំរេចចេញការអនុញ្ញាតអោយធ្វើបាតុកម្ម។ តាមភាពជាក់ស្តែង ពិសេសនៅភ្នំពេញ មន្ត្រីអាជ្ញាធរថ្នាក់ក្រោមបដិសេធសំណើសុំ បើសិនជាថ្នាក់ជាតិមិនផ្តល់ការអនុញ្ញាតច្បាស់លាស់ សំរាប់ការប្រមូលផ្តុំគ្នានោះទេ។ តាមធម្មតា អាជ្ញាធរតាមគ្រប់លំដាប់ថ្នាក់មិនផ្តល់ការអនុញ្ញាតដល់ក្រុមដែលរិះគន់គណបក្សដឹកនាំប្រទេសទេ ។

របាយការណ៍ដែលគួរអោយទុកចិត្តបាន បានអោយដឹងថា ពេលខ្លះ រដ្ឋាភិបាលរារាំងមិនអោយសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលរៀបចំពិធីជាសាធារណៈ ដោយលើកហេតុផលថា ក្រុមទាំងនោះមិនបានចុះបញ្ជីការ។ បញ្ញាតិដែលប្រកាសអោយប្រើ នៅមុនពេលបោះឆ្នោតឃុំសង្កាត់ ៤ មិថុនា អនុញ្ញាតអោយមន្ត្រីរាជការធ្វើយុទ្ធនាការ នៅក្រោយមកធ្វើការ តែមិនបានផ្តល់សេរីភាពនេះដល់បុគ្គលិកនៃអង្គការ NGO ឬអ្នកធ្វើការនៅក្នុងសង្គមស៊ីវិលទេ។ បន្ទាប់ពីការចាប់ខ្លួនមេដឹកនាំគណបក្សប្រឆាំង កឹម សុខា នៅថ្ងៃទី ៣ កញ្ញា អាជ្ញាធរខេត្តជាច្រើនបានហាមប្រាមការ ប្រជុំគ្នា ពិធីនានា និងការធ្វើបាតុកម្មរបស់គណបក្សប្រឆាំង CNRP ដែលជាអំឡុងពេលមុនគណបក្សនេះត្រូវបានគេ រំលាយដោយបង្ខំ នៅថ្ងៃទី ១៦ ខែវិច្ឆិកា។

អាជ្ញាធរលើកហេតុផលពីតំរូវការអោយមាន"ស្ថិរភាព" និង "សន្តិសុខសាធារណៈ" ដែលជាពាក្យមិនមាន និយាយនៅក្នុងច្បាប់ ហើយដូច្នេះ ត្រូវបានបកស្រាយតាមចិត្ត សំរាប់ការមិនផ្តល់ការអនុញ្ញាត។ អាជ្ញាធររដ្ឋាភិបាល ពេលខ្លះថែមទាំងលើកឡើងពីខនៅក្នុងច្បាប់អង្គការ ដើម្បីរារាំងអង្គការ សមាគមមិនអោយរៀបចំពិធីជាសាធារណៈ ឬបំបែកការប្រជុំឬការរៀនសូត្រ ដែលគេគិតថា ប្រឆាំងនឹងរដ្ឋាភិបាល។ ទន្ទឹមនឹងនោះ អាជ្ញាធរតែងតែអនុញ្ញាតអោយមានការធ្វើបាតុកម្មដែលគាំទ្ររដ្ឋាភិបាល។

ទោះបីជាមានការរឹតត្បិតទាំងនេះក្តី តែផ្នែកសារព័ត៏មានបានរាយការណ៍ពីការតវ៉ាជាសាធារណៈជាច្រើន ដែលភាគច្រើនទាក់ទងនឹងដីធ្លី ឬជំលោះដីធ្លី។ ក្នុងករណីខ្លះ នគរបាលបំបែកហ្វូងមនុស្សដែលប្រមូលផ្តុំគ្នាដោយគ្មាន ការអនុញ្ញាត ដោយក្នុងករណីខ្លះ បណ្តាលអោយមានរបួសតិចតួចដល់បាតុករ។ នៅក្នុងករណីផ្សេងទៀត នគរបាល បានប្រើកំលាំងប្រឆាំងនឹងបាតុករ បន្ទាប់ពីពួកគេធ្វើអោយស្ទះចរាចរ គំរាមប្រើឬប្រើហឹង្សា ឬមិនព្រមស្តាប់ការបញ្ជា អោយបំបែកគ្នា។

បើយោងតាមរបាយការណ៍រួមគ្នា ដែលចេញនៅខែសីហា របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា អង្គការអាដហុក អង្គការ American Center for International Labor Solidarity និង International Center for Not-for- Profit Law គិតពីខែមេសា ឆ្នាំ ២០១៦ ដល់ខែមិនា មាន ៦០ ករណីនៃការរារាំងដោយអាជ្ញាធរ មិនអោយអង្គការ NGO ធ្វើការប្រជុំ បើកវគ្គរៀនសូត្រ ឬប្រមូលផ្តុំគ្នា ដោយសារច្បាប់ស្តីពីអង្គការ សមាគម។ របាយការណ៍នេះ ថែមទាំងកត់ត្រាការដាក់កំហិតចំនួន ២៤៦ លើកដោយរដ្ឋាភិបាល និងស្ថាប័នភាគីទី ៣ ដែលមានការទាក់ទងជាមួយរដ្ឋាភិបាល លើសេរីភាពជាមូលដ្ឋាន ពីខែមេសា ដល់ខែកញ្ញា។ ថ្វីបើការរឹតត្បិតភាគច្រើនមាននៅភ្នំពេញក្តី តែក៏មានផងដែរនៅតាមគ្រប់ខេត្ត លើកលែងខេត្តព្រៃវែង និងខេត្តកែប។ ពេលខ្លះ អាជ្ញាធរប្តឹងអ្នកធ្វើការតវ៉ាដោយសន្តិភាព។ នៅថ្ងៃទី ២៧ ខែតុលា អាជ្ញាធរបានចាប់ខ្លួនមនុស្ស ៥ នាក់ ដែលមានផែនការចែកខិតប័ណ្ណ នៅថ្ងៃបុណ្យអុំទូក ដែលអំពាវនាវអោយធ្វើបាតុកម្មដើម្បីទាមទារអោយរដ្ឋាភិបាលដោះលែងអ្នកទោសនយោបាយ។ នៅថ្ងៃដដែលនោះ តុលាការក្រុងភ្នំពេញបានកោះហៅឡេង សេងហុង ប្រធានសហព័ន្ធបញ្ញវ័ន្តនិស្សិតប្រជាធិបតេយ្យកម្ពុជា ទាក់ទងនឹង

បទចោទថា បានញុះញង់អោយប្រព្រឹត្តបទឧក្រិដ្ឋ ដោយអំពាវនាវអោយសាធារណជនធ្វើការតវ៉ា បើសិនជាគណបក្ស CNRP ត្រូវបានរំលាយ។

មន្ត្រីយោធា និងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ រួមទាំងនាយករដ្ឋមន្ត្រី ហ៊ុន សែន អភិបាលរាជធានីភ្នំពេញ ឃួង ស្រេង អ្នកនាំពាក្យគណបក្ស CPP សុខ ឥសាន អ្នកនាំពាក្យក្រុមប្រឹក្សារដ្ឋមន្ត្រី ផៃ ស៊ីផាន អគ្គមេបញ្ជាការកងទ័ព ប៉ុល សារឿន បានព្រមានសាធារណជនមិនអោយប្រមូលផ្តុំឬធ្វើបាតុកម្ម នៅក្នុងទីក្រុង នៅក្នុងសវនាការក្តីមេដឹកនាំបក្សប្រឆាំង កឹម សុខា បន្ទាប់ពីការចាប់ខ្លួនលោក នៅថ្ងៃទី ៣ កញ្ញា។ រដ្ឋមន្ត្រីក្រសួងការពារជាតិ ទា បាញ់ បានអំពាវនាវជាសាធារណៈអោយ "កំទេចការប្រឆាំង" ដោយព្រមានថា យោធានឹង "វាយបំបាក់ធ្មេញអ្នកតវ៉ា" ដែលគ្រោងធ្វើបាតុកម្ម ប្រឆាំងនឹងលទ្ធផលឆ្នោតឃុំសង្កាត់ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ៤ មិថុនា។ លោករដ្ឋមន្ត្រីក្រសួងសង្គមកិច្ច វង សូតបាននិយាយថា អ្នកធ្វើបាតុកម្មប្រឆាំងនឹងការបោះឆ្នោត ឆ្នាំ ២០១៨ ខាងមុខ នឹង "ត្រូវវាយនឹងគល់ឬស្សី"។ មេបញ្ជាការនៃកងអង្គរក្សនាយករដ្ឋមន្ត្រី គឺឧត្តម សេនីយ ហ៊ីង ប៊ុនហៀង បានគំរាមប្រើកំលាំងដើម្បី"កំទេចបាតុកម្ម ដោយលោកបានលើកឡើងថា មាន "រថគ្រោះ ១០០ គ្រឿង"។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស ខេង ថែមទាំងបានណែនាំអោយអភិបាលខេត្ត និងមេនគរបាលរាំងមិនអោយអ្នកគាំទ្របក្សប្រឆាំងធ្វើដំណើរមកទីក្រុង ដើម្បីការពារមិនអោយមានបាតុកម្ម។ លោក ឃួង ស្រេងបាននិយាយថា អាជ្ញាធរនឹងមិនអនុញ្ញាតអោយមានការតវ៉ា "អាណាធិបតេយ្យ" នៅក្នុងទីក្រុងទេ ហើយកំលាំងសន្តិសុខនៅក្នុងខ័ណ្ឌទាំង ១២ ក្នុងរាជធានី ត្រូវប្រុងជើងការ។ លោកស្រេងបាននិយាយថា "វិធានការដ៏ក្តៅបំផុតនឹងត្រូវប្រើទៅលើអ្នកតវ៉ាប្រឆាំងនឹងតុលាការ ហើយយើងនឹងមិនអត់ឱនចំពោះអ្នកទាំងនោះទេ"។ ការគំរាមកំហែងទៅលើការតវ៉ាដោយសន្តិភាព មានបន្ទាប់ពីរយៈពេលរាប់ខែនៃការព្រមានប្រឆាំងនឹងលទ្ធផលឆ្នោត។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែនបានគំរាមថា ជោគជ័យរបស់គណបក្ស CNRP នៅក្នុងការបោះឆ្នោតឃុំសង្កាត់អាចនាំអោយមាន "សង្គ្រាមស៊ីវិល"។

## សេរីភាពបង្កើតអង្គការ/សមាគម

រដ្ឋធម្មនុញ្ញមានចែងអំពីសេរីភាពបង្កើតអង្គការ/សមាគម តែរដ្ឋាភិបាលមិនបានគោរពសិទ្ធិ នេះអោយបានជាប់លាប់ទេ ពិសេសទាក់ទងនឹងសិទ្ធិរបស់កម្មករ (សូមមើលត្រង់ផ្នែក ៧.ក) ។ ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល តំរូវអោយគ្រប់អង្គការ សមាគមទាំងអស់មានអព្យាក្រិតភាពផ្នែកនយោបាយ ដែលការនេះមិនត្រឹមតែរឹតត្បិតលើសិទ្ធិក្នុងការចូលរួមតែប៉ុណ្ណោះទេ តែថែមទាំងរឹតត្បិតសិទ្ធិនៃអង្គការទាំងនោះ នៅក្នុងការសំដែងមតិដោយសេរី។

នៅខែមិថុនា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែនបានបញ្ជាអោយក្រសួងមហាផ្ទៃរំលាយបន្ទប់ស្ថានការណ៍របស់ក្រុងអង្គការNGO ចំនួន៤០ ដែលភាគច្រើនធ្វើការផ្នែកសិទ្ធិមនុស្ស បន្ទាប់ពីអង្គការទាំងនោះបានចេញលទ្ធផលរកឃើញទាក់ទងនឹងដំណើរការបោះឆ្នោតឃុំនៅថ្ងៃ ៤ មិថុនា។ បន្ទប់ស្ថានការណ៍បានរងការចោទថា បានរំលោភលើ

ច្បាប់ស្តីពីអង្គការ សមាគម ដោយសារមិនបានចុះបញ្ជីការជាអង្គការមិនមែនរដ្ឋាភិបាល (ថ្វីបើអង្គការនិមួយៗក្នុងចំណោមអង្គការទាំង ៤០ នោះបានចុះបញ្ជីការហើយក្តី) និងពីបទរំលោភលើបញ្ញាតិនៃច្បាប់នេះស្តីពីអព្យាក្រិតភាពផ្នែកនយោបាយ។

បញ្ញាតិដែលចែងមិនច្បាស់នៅក្នុងច្បាប់ស្តីពីអង្គការសមាគម ច្បាប់ស្តីពីសហជីព និងច្បាប់ស្តីពីគណបក្សនយោបាយដែលត្រូវបានធ្វើវិសោធនកម្ម ហាមប្រាមសកម្មភាពដែលអាច "ធ្វើអោយខូចដល់សន្តិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ" ឬប៉ះពាល់ដល់ "សន្តិសុខជាតិ សាមគ្គីជាតិ ប្រពៃណី និងវប្បធម៌នៃសង្គមជាតិកម្ពុជា"។ អង្គការសង្គមស៊ីវិលបានសំដែងកង្វល់ចំពោះបទបញ្ញាតិដែលចែងមិនច្បាស់ ថា បានបង្កើតអោយមានការប្រឈមខ្លាំងនឹងការរឹតត្បិតតាមចិត្ត លើសិទ្ធិរបស់អង្គការ សមាគម។ យោងតាមអ្នករិះគន់ ច្បាប់អង្គការ និងច្បាប់សហជីពចែងពីដំណើរការចុះបញ្ជីស្មុគស្មាញ និងច្រើនជំហាន ហើយខ្វះការការពារផ្នែករដ្ឋបាល ដែលជាការធ្វើអោយដំណើរការនៃការចុះបញ្ជីរងលក្ខណៈនយោបាយ។ ច្បាប់នេះថែមទាំងកំណត់អោយមានការធ្វើរបាយការណ៍យ៉ាងតឹងតែង ស្តីពីថវិកា និងសកម្មភាព រួមទាំងការត្រូវបង្ហាញសំណើសុំថវិកាដែលបានទទួលថវិកា កិច្ចព្រមព្រៀងលើថវិកាជំនួយ ឬកិច្ចព្រមព្រៀងផ្នែកហិរញ្ញវត្ថុ។ កាតព្វកិច្ចបន្ថែមទៀតរួមមានការបង្ហាញសំណើសុំថវិកាដែលបានទទួលការយល់ព្រមកិច្ចព្រមព្រៀងលើថវិកាឬអំណោយថវិកា និងគណនេយ្យធនាគាររបស់អង្គការសមាគម។

គណកម្មាធិការសហប្រតិបត្តិការសំរាប់កម្ពុជា ដែលជារបស់បណ្តុំនៃអង្គការ NGO ក្នុងស្រុក បាននិយាយកាលពីខែកក្កដាថា ជាទូទៅ អង្គការ NGO ខ្វះការណែនាំពីរដ្ឋាភិបាល ស្តីពីការគោរពតាមលក្ខខ័ណ្ឌទាមទារ។ គិតមកត្រឹមខែសីហា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកោះហៅអង្គការសារព័ត៌មាន និងអង្គការសង្គមស៊ីវិលចំនួន ៦ ដើម្បីអោយបង្ហាញការគោរពតាមរបស់គេលើច្បាប់ពន្ធដាក្នុងស្រុក។ អង្គការទាំងនេះមានអង្គការអាដហុក លីកាដូ អង្គការគណកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា កាសែត Cambodia Daily វិទ្យុ VOA និងវិទ្យុអាស៊ីសេរី។

នៅថ្ងៃទី ១៥ ខែកញ្ញា ក្រសួងមហាផ្ទៃបានលុបចោលការចុះបញ្ជីនៃអង្គការ Mother Nature ដែលជាអង្គការ NGO មួយធ្វើការការការពារបរិស្ថាន ដោយមិនបានផ្តល់ហេតុផលដល់អង្គការនេះទេ។ នៅចុងខែកញ្ញា រដ្ឋាភិបាលបានចាប់ផ្តើមទាមទារអោយ NGO ទាំងអស់រាយការណ៍ពីរចនាសម្ព័ន្ធគ្រប់គ្រង ប្រភពថវិកា និងសេចក្តីលំអិតដទៃទៀតទៅក្រសួងមហាផ្ទៃ។ នៅថ្ងៃទី ២៣ ខែសីហា រដ្ឋាភិបាលបានបណ្តេញចេញនូវអង្គការ វិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) និងបុគ្គលិកបរទេសរបស់ខ្លួនចេញពីប្រទេសកម្ពុជា ដោយអះអាងថា អង្គការនេះមិនបានចុះបញ្ជីការត្រឹមត្រូវ នៅក្រោមច្បាប់ស្តីពីអង្គការសមាគម។ អង្គការ NDI បានដាក់ជូននូវឯកសារចុះបញ្ជី រយៈពេល ១៨ ខែមុនពេលត្រូវបានបណ្តេញចេញ ហើយអាជ្ញាធរមិនបានធ្វើការឆ្លើយតបវិញ ទោះបីជានៅក្នុងច្បាប់មានចែងថា ការឆ្លើយតបត្រូវធ្វើនៅក្នុងរយៈពេល ៤៥ ថ្ងៃនៃការដាក់ជូនឯកសារ។

## គ. សេរីភាពសាសនា

ចំពោះសេចក្ដីរៀបរាប់លំអិតស្ដីពីសេរីភាពសាសនា សូមមើល *របាយការណ៍ស្ដីពីសេរីភាពសាសនា* តាមគេហទំព័រ www.state.gov/religiousfreedomreport/ ។

## ឃ. សេរីភាពដើរហើរ

ច្បាប់មានចែងអំពីសេរីភាពដើរហើរនៅក្នុងប្រទេស ការធ្វើដំណើរនៅបរទេស និរប្រវេសន៍ និងមាតុភូមិនិវត្តន៍ ហើយជាទូទៅ ក្នុងការអនុវត្តជាក់ស្ដែង រដ្ឋាភិបាលបានគោរពសិទ្ធិទាំងនេះ ។

និរទេស៖ នៅឆ្នាំ ២០១៦ រដ្ឋាភិបាលបានបញ្ជាអោយមន្ត្រីអន្តោប្រវេសន៍ចាត់វិធានការផ្លូវច្បាប់ដ៏មិនច្បាស់មួយ ដើម្បីរារាំងអតីតមេដឹកនាំគណបក្សប្រឆាំង សម រង្ស៊ី មិនអោយត្រឡប់មកវិញ។ លោកបាននិរទេសខ្លួននៅប្រទេសបារាំងនៅឆ្នាំ ២០១៥ ដោយនៅពេលនោះ រដ្ឋាភិបាលបានចេញដីការចាប់ខ្លួនគាត់ ដោយចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ក្នុងពេលដែលលោកស្ថិតនៅក្រៅប្រទេស។ លោក ធន សារ៉ាយ ប្រធានអង្គការអាដហុក បានគេចចេញពីប្រទេសទៅប្រទេសកាណាដា ដោយធ្វើនិរទេសខ្លួនឯង ដោយសារភ័យខ្លាចរដ្ឋាភិបាលចាប់ខ្លួនគាត់។ បន្ទាប់ពីលោក កឹម សុខាត្រូវបានចាប់ខ្លួន ស្ទើរតែគ្រប់មេដឹកនាំជាន់ខ្ពស់របស់គណបក្ស CNRP បានលាក់ខ្លួន ឬនិរទេសខ្លួនឯង ដោយនៅសល់តែប្រធានស្ដីទី ប៉ុល ហម និងលោក ស៊ុន ឆៃ គឺជាមេដឹកនាំជាន់ខ្ពស់តែពីរនាក់គត់ ដែលបន្តស្ថិតនៅភ្នំពេញ ចំណែកសកម្មជនរបស់បក្សនៅថ្នាក់ក្រោមជាច្រើនទៀតបាននិយាយថា ស្ថិតនៅក្រោមការតាមដាន និងការគំរាមកំហែងពីនគរបាលកាន់តែច្រើនឡើង។

## ការការពារជនភៀសខ្លួន

ការចាប់បញ្ជូនជនភៀសខ្លួនត្រឡប់វិញ៖

ដោយបាននិយាយថា ពួកគេគឺជា "ជនអន្តោប្រវេសន៍សេដ្ឋកិច្ច" រដ្ឋាភិបាលបានចាប់បញ្ជូនអ្នកស្រុកភ្នំវៀតណាមចំនួនយ៉ាងហោចណាស់ ១៤០ នាក់ទៅប្រទេសវៀតណាមវិញ គិតតាំងពីឆ្នាំ ២០១៥ មក ដោយរួមទាំង ១៣ នាក់ នៅខែសីហា ដោយមិនបានធ្វើការកំណត់ឋានៈជនភៀសខ្លួនបានត្រឹមត្រូវឡើយ។ នៅខែសីហា លោកស្រី Rhona Smith អ្នករាយការណ៍ពិសេសផ្នែកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅកម្ពុជា បានចេញសេចក្ដីថ្លែងការណ៍មួយ បន្ទាប់ពីបេសកកម្មរបស់លោកស្រីនៅកម្ពុជាចំនួន ២ សប្ដាហ៍ ដោយនៅក្នុងនោះ លោកស្រីបានបញ្ជាក់ថា ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិ (UNHCR) ទទួលស្គាល់ភាពត្រឹមត្រូវនៃការអះអាងសុំសិទ្ធិជ្រកកោនរបស់ជនជាតិភ្នំវៀតណាមដែលកាន់សាសនាគ្រឹះទាំង ៣៦ នាក់ ហើយបានសំរេចចិត្តស្វែងរកដំណោះស្រាយនៅក្រៅប្រទេស និងថា រដ្ឋាភិបាលមិនបានយល់ព្រមអោយស្ថិតនៅក្នុងប្រទេសកម្ពុជា

ឬសំរួលដល់ការផ្ទេរពួកគេទៅប្រទេសទី ៣ ឡើយ។ នៅខែតុលា រដ្ឋាភិបាលបានធ្វើសហប្រតិបត្តិការក្នុងការបញ្ជូនអ្នកស្រុកភ្នំចំនួន ៧ នាក់ ក្នុងចំណោម ៣៦ នាក់ទៅប្រទេសទី ៣ ដោយអះអាងថាការអះអាងស្នើសុំសិទ្ធិជ្រកកោនរបស់អ្នកនៅសល់ចំនួន ២៩ នាក់នោះមិនខ្លាំងគ្រប់គ្រាន់។ រដ្ឋាភិបាលបានបដិសេធសេចក្តីថ្លែងរបស់អ្នករាយការណ៍ពិសេស ហើយបានថ្កោលទោសលោកស្រី ចំពោះអ្វីដែលខ្លួននិយាយថា ជាការជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួន។

រដ្ឋាភិបាលបានបង្កើនការតាមដាន នៅបរិវេណដែលគ្រប់គ្រងដោយ UNHCR ដែលផ្តល់ការជួយដល់អ្នកស្រុកភ្នំស្វែងរកសិទ្ធិជ្រកកោន។ នៅខែមេសា អាជ្ញាធរបានបង្ខំអោយស្ត្រីមានផ្ទៃពោះម្នាក់ និងប្តីរបស់គាត់ចេញពីបរិវេណនោះ ហើយនាំពួកគាត់ទៅសួរចំលើយនៅមជ្ឈមណ្ឌលអន្តោប្រវេសន៍។

បានរាយការណ៍ថា អ្នកស្រុកភ្នំវៀតណាមចំនួនជាង ១៧០ នាក់ បនៅភ្នំពេញបានបង្ហាញបំណងចង់ចុះឈ្មោះជាអ្នកស្វែងរកសិទ្ធិជ្រកកោន តែនាយកដ្ឋានជនភៀសខ្លួនរបស់ក្រសួងមហាផ្ទៃមិនអនុញ្ញាតអោយគេធ្វើដូច្នេះទេ។ នៅខែតុលា ក្រសួងបានប្រកាសជាសាធារណៈថា ខ្លួនមិនបានផ្តល់សិទ្ធិជ្រកកោនដល់អ្នកស្រុកភ្នំវៀតណាមភាគច្រើនដែលបន្តស្នាក់នៅ បន្ទាប់ពីធ្វើសំភាសន៍ជាច្រើន ដោយនិយាយថា “ចំលើយរបស់គេមិនបំពេញបានតាមកតិសញ្ញាស្តីពីជនភៀសខ្លួន” ទេ។ ពីដំបូង សារព័ត៌មានក្នុងស្រុកបាននិយាយថា ក្រសួងបានផ្តល់អោយពួកគេនូវពេល ២ សប្តាហ៍សំរាប់ការចាកចេញពីប្រទេស បើគេមិនព្រមចេញទេ នោះគេនឹងត្រូវចាប់បញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ តែក្រោយមក ក្រសួងបានដកការកំណត់ពេលនោះវិញ។ គ្រួសារនោះនៅរង់ចាំការសំរេចចុងក្រោយលើឋានៈជាជនភៀសខ្លួន ហើយក្រោយមក អាជ្ញាធរបានដោះលែងពួកគាត់។

<u>លទ្ធភាពទទួលបានការជ្រកកោន៖</u>

ច្បាប់ប្រទេសកម្ពុជាមានចែងអំពីការផ្តល់សិទ្ធិជ្រកកោន ឬឋានៈជាជនភៀសខ្លួន ហើយរដ្ឋាភិបាលបានរៀបចំប្រព័ន្ធមួយសម្រាប់ផ្តល់កិច្ចការពារដល់ជនភៀសខ្លួន ។ រដ្ឋាភិបាលមិនបានផ្តល់លទ្ធភាពស្មើគ្នាក្នុងការប្រើប្រាស់ប្រព័ន្ធនេះដល់អ្នកសុំសិទ្ធិជ្រកកោនទាំងអស់ទេ។ ដូចជាថា អាជ្ញាធរ ជាធម្មតា មិនផ្តល់លទ្ធភាពដល់ក្រុមអ្នកស្រុកភ្នំមកពីប្រទេសវៀតណាមដែលស្វែងរកសិទ្ធិជ្រកកោន នៅក្នុងដំណើរការចុះឈ្មោះជនភៀសខ្លួនទេ តាំងពីឆ្នាំ ២០១៤ មក។ នាយកដ្ឋានទទួលបន្ទុកផ្នែកជនភៀសខ្លួនរបស់ក្រសួងមហាផ្ទៃបានទទួលស្គាល់អ្នកស្រុកមកពីវៀតណាមថា ជាជនភៀសខ្លួន ហើយបានចាត់វិធានការបញ្ជូនត្រឡប់វិញនូវមនុស្សចំនួន ២៩ នាក់ ដែលខ្លួនអះអាងថា ការទាមទារសិទ្ធិជ្រកកោនរបស់គេនោះគ្មានលក្ខណៈគ្រប់គ្រាន់។ អង្គការ NGO ខ្លះចាត់ទុកថា កង្វះទឹកចិត្តរបស់រដ្ឋាភិបាល ក្នុងការផ្តល់សិទ្ធិជ្រកកោនដល់អ្នកស្រុកភ្នំទាំងនោះ ថាបណ្តាលមកពីការគាបសង្កត់របស់ប្រទេសវៀតណាម។

<u>ការងារ៖</u> អ្នកដែលបានទទួលឋានៈជាជនភៀសខ្លួន គ្មានសិទ្ធិធ្វើការទេ។

លទ្ធភាពទទួលបានការបំរើផ្នែកសេវាសាធារណៈជាមូលដ្ឋាន៖ អ្នកដែលបានទទួលឋានៈជាជនភៀសខ្លួនគ្មានលទ្ធភាពទទួលបានការបំរើផ្នែកសេវាសាធារណៈជាមូលដ្ឋានទ រួមទាំងសេវាសាធារណៈ និងសេវាធនាគារផងដែរ។

ដំណោះស្រាយយូរអង្វែង៖ យោងតាមកិច្ចព្រមព្រៀងជាមួយប្រទេសអូស្ត្រាលី រដ្ឋាភិបាលបានទទួលយកអោយស្នាក់នៅ តាំងពីឆ្នាំ ២០១៤ មក នូវជនភៀសខ្លួនចំនួន ៧ នាក់ ដែលត្រូវបានគេឃុំ ក្នុងពេលដែលពួកគេស្វែងរកសិទ្ធិជ្រកកោននៅប្រទេសអូស្ត្រាលី ។ ជនភៀសខ្លួនចុងក្រោយគេបានមកដល់នៅខែមេសា។ ក្នុងចំណោមអ្នកទាំង ៧ មាន ៣ នាក់ជាជនជាតិ ជនភៀសខ្លួនចុងក្រោយគេបានមកដល់នៅខែមេសា។ ក្នុងចំណោមអ្នកទាំង ៧ មាន ៣ នាក់ដែលជាជនជាតិ Rohingya ពីប្រទេសភូមា បានបន្តស្នាក់នៅកម្ពុជាជាបន្ត ចំណែក ៤ នាក់ទៀត ដែលមានម្នាក់មកពីភូមា និង ៣ នាក់ទៀតមកពីអ៊ីរ៉ាក់ បានសំរេចចិត្តត្រឡប់ទៅប្រទេសរបស់គេវិញ។ ថ្វីបើជនជាតិ Rohingya ទាំង ៣ នាក់ បានសំរេចចិត្តនៅកម្ពុជាក្តី តែគ្មានវិធីច្បាស់លាស់សំរាប់អោយជនភៀសខ្លួនទទួលបានសញ្ជាតិទេ។

**ជនគ្មានប្រទេស [ជនគ្មានរដ្ឋ]**

ប្រទេសកម្ពុជាមានអ្នករស់នៅដែលជាជនគ្មានប្រទេស។ គ្មានទិន្នន័យថ្មី ដែលគួរអោយទុកចិត្តបាន ស្តីពីចំនួនឬប្រជាសាស្ត្រនៃអ្នកគ្មានរដ្ឋទេ តែអង្គការ UNHCR បាននិយាយថា ពួកគេភាគច្រើនជាអាណិកជនវៀតណាម។ រដ្ឋាភិបាលមិនបានអនុវត្តច្បាប់ឬគោលនយោបាយប្រកបដោយប្រសិទ្ធភាព ដើម្បីផ្តល់ឱកាសដល់ជនទាំងនោះអោយទទួលបានសញ្ជាតិឡើយ ។ (សូមមើលផ្នែកទី ៦ ស្តីពីកុមារ)។ ហេតុផលដែលច្រើនមានជាងគេចំពោះភាពគ្មានប្រទេសគឺកង្វះឯកសារត្រឹមត្រូវពីប្រទេសកំណើត។

បើយោងតាមអង្គការមិនមែនរដ្ឋាភិបាលមួយ បុគ្គលដែលគ្មានភស្តុតាងសញ្ជាតិ ច្រើនមិនសូវបានទទួលបានការងារដែលមានលក្ខណៈផ្លូវការ ការសិក្សា ការចុះបញ្ជីអាពាហ៍ពិពាហ៍ លទ្ធភាពតាមផ្លូវតុលាការ និងកម្មសិទ្ធិដីធ្លីទេ។

**ផ្នែកទី៣. សេរីភាពក្នុងការចូលរួមក្នុងដំណើរការនយោបាយ**

រដ្ឋធម្មនុញ្ញផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋក្នុងការជ្រើសរើសរដ្ឋាភិបាលរបស់ខ្លួនតាមរយៈការបោះឆ្នោតជាទៀងទាត់ ដោយសេរី និងយុត្តិធម៌ ដោយផ្អែកលើសិទ្ធិបោះឆ្នោតជាសាកល និងស្មើភាព។ នៅក្នុងឆ្នាំនៃរបាយការណ៍នេះ សភាបានធ្វើវិសោធនកម្មលើច្បាប់គណបក្សចំនួន ២ ដង ដោយម្តងៗ ពង្រីកហេតុផលសំរាប់អោយរដ្ឋាភិបាលរំលាយគណបក្ស ដោយផ្អែកលើហេតុផលមិនច្បាស់លាស់ ដូចជា “ការញុះញង់” ឬ “សន្តិសុខជាតិ” ។ វិសោធនកម្មមួយថែមទាំងហាមប្រាមបុគ្គលដែលស្ថិតក្នុងផ្លូវដឹកនាំគណបក្សមិនអោយធ្វើនយោបាយ នៅពេលរងការចោទប្រកាន់ពីបទ

ឧក្រិដ្ឋ។ ដោយយោលទៅលើភាសាមិនច្បាស់លាស់នៃច្បាប់នោះ អ្នកជំនាញជាច្រើនមិនប្រាកដថា តើបំរាមនោះអនុវត្តតែចំពោះជនដែលតុលាការដាក់ទោស ឬអនុវត្តជាទូទៅលើមនុស្សទាំងឡាយណាដែលរងការចោទប្រកាន់ពីបទល្មើស។ វិសោធនកម្មទាំងនោះថែមទាំងរឹតត្បិតគណបក្សមិនអោយប្រើឯកសារជាសំលេង ជារូបភាព ឬជាសំណេរ ដែលបានមកពីជនល្មើសដែលតុលាការបានដាក់ទោស។ វិសោធនកម្មទាំងនោះផ្តល់សិទ្ធិអោយតុលាការរំលាយគណបក្សនយោបាយ ដែលត្រូវបានរកឃើញថា បានរំលោភច្បាប់  ហើយយកកៅអីរបស់គណបក្សដែលត្រូវបានរំលាយនោះទៅចែកអោយគណបក្សផ្សេង នៅក្នុងករណីមានការរំលាយបែបនេះ អនុញ្ញាតអោយមានការហាមប្រាមមេដឹកនាំគណបក្សពីការធ្វើនយោបាយ នៅក្រោមកាលៈទេសៈកំណត់។

នៅថ្ងៃទី ១៦ ខែវិច្ឆិកា តុលាការកំពូលបានលើកពីវិសោធនកម្មថ្មី នៅក្នុងការសំរេចចិត្តរបស់ខ្លួន ដើម្បីរំលាយគណបក្ស CNRP បែងចែកកៅអីរបស់គណបក្សនេះ នៅក្នុងសភា និងនៅក្នុងអាជ្ញាធរមូលដ្ឋាន ទៅអោយគណបក្សដទៃដោយរួមទាំងគណបក្សកាន់អំណាច CPP ផងដែរ ហាមប្រាមមេដឹកនាំគណបក្ស CNRP ចំនួន ១១៨ នាក់មិនអោយធ្វើសកម្មភាពនយោបាយចំនួន ៥ ឆ្នាំ។ លោកនាយករដ្ឋមន្ត្រីបានប្រកាសថា ការបែងចែកកៅអីឡើងវិញនេះជាការលើកស្ទួយការប្តេជ្ញាចិត្តតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា ចំពោះលទ្ធិប្រជាធិបតេយ្យពហុបក្ស។ តែអ្នកសង្កេតការណ៍មួយចំនួនបានចោទប្រកាន់តុលាការកំពូល ដែលមានប្រធានស្ថិតនៅក្នុងជួរដឹកនាំរបស់គណបក្ស CPP ពីបទមានភាពលំអៀងនយោបាយ ហើយបានចោទសួរពីភាពត្រឹមត្រូវនៃការសំរេចចិត្តរបស់តុលាការ និងកង្វះការប្រកាន់តាមបទដ្ឋានច្បាប់។ ឧទាហរណ៍ ការសំរេចមានបក្ស CNRP មានឡើង មុនពេលមេដឹកនាំរបស់បក្សនេះរងការដាក់ទោសដោយតុលាការពីបទចោទថា ក្បត់ជាតិ។

## ការបោះឆ្នោត និងការចូលរួមផ្នែកនយោបាយ

<u>ការបោះឆ្នោតជាតិថ្មីៗកន្លងទៅ៖</u> ការបោះឆ្នោតជាតិក្នុងពេលថ្មីៗបំផុត ដែលត្រូវបានធ្វើថ្ងៃទី ៤ មិថុនា គឺជាការបោះឆ្នោតឃុំសង្កាត់ ហើយគណបក្សធំជាងគេទាំងពីរបានទទួលយកលទ្ធផលឆ្នោត។ ពលរដ្ឋចំនួន ៧ លាននាក់ ដែលតំណាងអោយ ៩០% នៃអ្នកមានសិទ្ធិបោះឆ្នោត បានចេញទៅបោះឆ្នោត។ គណបក្ស CPP បានឈ្នះក្នុងឃុំចំនួន ១១៥៦ ដោយផ្តល់អោយគណបក្សនេះធ្វើជាមេឃុំនៅតាមឃុំទាំងនោះ ចំណែកគណបក្សប្រឆាំង CNRP បានឈ្នះក្នុងឃុំចំនួន ៤៨៩។ បន្ទប់ស្ថានការណ៍ដែលតាមឃ្លាំមើលការបោះឆ្នោតក្នុងនៅកម្ពុជា បានចេញសេចក្តីប្រកាសមួយថាដំណើរការបោះឆ្នោតត្រូវបានកែលំអច្រើន ហើយមានតំលាភាពច្រើនជាងការបោះឆ្នោតលើកមុន បើនិយាយពីការចុះឈ្មោះអ្នកបោះឆ្នោត និងការគ្រប់គ្រងបញ្ជីអ្នកបោះឆ្នោត ការចុះបញ្ជីបេក្ខជន ដំណើរការរាប់សន្លឹកឆ្នោត និងដំណើរការនៅមណ្ឌលបោះឆ្នោត ហើយនិងការប្រកាសពីលទ្ធផលឆ្នោត។ យ៉ាងណាក្តី បន្ទប់ស្ថានការណ៍នេះបាននិយាយថា

យុទ្ធនាការបោះឆ្នោត ការគ្រប់គ្រងលើលទ្ធផល និងដំណោះស្រាយលើជំលោះទាក់ទងនឹងការបោះឆ្នោត នៅមានចំណុចដែលត្រូវធ្វើការកែលំអថែមទៀត។

នៅក្នុងការបោះឆ្នោតជាតិ ឆ្នាំ ២០១៣ គណបក្ស CPP បានទទួលកៅអីចំនួន ៦៨ ហើយគណបក្សប្រឆាំង CNRP បានទទួលកៅអីចំនួន ៥៥។ អង្គការ NGO ក្នុងស្រុក និងអន្តរជាតិបានវាយតំលៃថា ដំណើរការបោះឆ្នោតនេះមានចំណុចខុសឆ្គងច្រើន ដូចជាបញ្ហាចុះឈ្មោះអ្នកបោះឆ្នោត លទ្ធភាពមិនស្មើគ្នានៅក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ហើយនិងការចេញប័ណ្ណផ្លូវការសំគាល់អ្នកបោះឆ្នោតបណ្តោះអាសន្នច្រើនពេក។ ទោះបីជាមានកង្វល់ដូច្នេះក្តី ក៏គណបក្សទាំងពីរ នៅទីបំផុត បានយល់ព្រមគោរពតាមលទ្ធផលផ្លូវការ ហើយចូលអង្គុយកៅអីនៅក្នុងសភា។

<u>គណបក្សនយោបាយ និងការចូលរួមនយោបាយ៖</u> វិសោធនកម្មលើច្បាប់បោះឆ្នោតដែលហាមប្រាមជនល្មើសដែលតុលាការបានដាក់ទោសហើយ មិនអោយដឹកនាំគណបក្សនយោបាយ ត្រូវបានអ្នកសង្កេតការណ៍ និងអង្គការ NGO មើលឃើញថា មានបំណងរារាំងមិនអោយលោក សម រង្ស៊ីចូលរួមនៅក្នុងការបោះឆ្នោតជាតិ នៅពេលខាងមុខ។ លោក រង្ស៊ីត្រូវបានគេកាត់ទោសកំបាំងមុខ ពីបទចោទមួយចំនួនដែលមានលក្ខណៈនយោបាយ ដោយរួមទាំងបទបរិហារកេរ្តិ៍។

មានគណបក្សនយោបាយចំនួន ១២ អាចចុះឈ្មោះ ហើយចូលរួមក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់។ ទូរទស្សន៍ជាតិកម្ពុជាបានផ្តល់ម៉ោងផ្សាយដល់គណបក្សទាំង ១២។ មុនពេលយុទ្ធនាការចាប់ផ្តើម គណកម្មាធិការជាតិរៀបចំការបោះឆ្នោត(គជប) បានសួរជាផ្លូវការដល់ស្ថានីយទូរទស្សន៍ឯកជនទាំងអស់ថា តើគេនឹងលក់ម៉ោងផ្សាយចំនួនប៉ុន្មាន សំរាប់គ្រប់គណបក្សទាំងអស់ធ្វើការផ្សាយឃោសនា។ គ្មានស្ថានីយ៍ណាមួយនិយាយថា គេនឹងលក់ម៉ោងផ្សាយទេ។ តែនៅថ្ងៃចុងក្រោយនៃយុទ្ធនាការ គណបក្ស CPP តាមសេចក្តីរាយការណ៍មកថា បានទិញម៉ោងផ្សាយចំនួន ៨ ម៉ោង ពីស្ថានីយ៍ទាំងនោះ សំរាប់ផ្សាយឃោសនា។ ស្ថានីយ៍ទាំងនោះបានបន្ទោសគណបក្ស CNRP ចំពោះការខកខានមិនបានទាក់ទងគេ នៅមុនពេលយុទ្ធនាការចាប់ផ្តើម។

គណបក្សខ្មែររួបរួមជាតិ (KNUP) គឺជាគណបក្សតែមួយគត់ ក្រៅពីគណបក្ស CPP និងគណបក្ស CNRP CNRP ដែលបានឈ្នះមួយឃុំ នៅក្នុងការបោះឆ្នោតឃុំសង្កាត់ នៅថ្ងៃ ៤ មិថុនា។ គណបក្ស KNUP បានធ្វើដៃគូនៅក្នុងរដ្ឋាភិបាលចំរុះ តែរដ្ឋាភិបាលបានដកតំណែងប្រធានគណបក្ស KNUP បន្ទាប់ពីមានលេចចេញនូវសំលេង ដែលក្នុងនោះ គាត់ត្រូវបានចោទថា បានពិភាក្សាពីការចូលរួមគ្នាជាមួយគណបក្ស CNRP ។ បន្ទាប់មក អាជ្ញាធរបានចាប់ខ្លួនគាត់ ដោយផ្អែកលើការចោទប្រកាន់ដែលមានរយៈពេលមួយទសវត្សមកហើយ ពីបទផលិតគ្រឿងញៀន។ ដើម្បីធ្វើអោយគណបក្ស KNUP អាចចូលរួមក្នុងការបោះឆ្នោតបានបន្ទាប់ពីការចាប់ខ្លួនគាត់ លោក ប៊ុនឆៃបានចាកចេញពីគណបក្សជាផ្លូវការ។

រដ្ឋាភិបាលបានប្រើវិសោធនកម្មទាំង ៤ ដែលខ្លួនបានបង្កើតឡើងចំពោះច្បាប់ស្តីពីគណបក្សនយោបាយ នៅក្នុងឆ្នាំនៃរបាយការណ៍នេះ សំដៅធ្វើទុក្ខគណបក្ស CNRP និងមេដឹកនាំនៃគណបក្សនេះ ហើយតុលាការកំពូលបានលើកឡើងពីវិសោធនកម្មទាំងនេះ នៅពេលខ្លួនរំលាយគណបក្ស CNRP នៅថ្ងៃទី ១៦ ខែវិច្ឆិកា។ កៅអីរបស់គណបក្ស CNRP ចំនួន ៥៥ នៅក្នុងសភាជាតិ ត្រូវបានបែងចែកឡើងវិញទៅអោយគណបក្សតូចៗចំនួន ៦ ដែលបានចូលរួមនៅក្នុងការបោះឆ្នោតសភាលើកមុន តែមិនបានទទួលកៅអីមួយសោះ នៅពេលនោះ។ នៅថ្នាក់មូលដ្ឋាន ក្រុមប្រឹក្សាឃុំរបស់គណបក្ស CNRP ចំនួន ៥០០៧ នាក់ត្រូវបង្ខំចិត្តបោះបង់កៅអីរបស់គេទៅអោយគណបក្សកាន់អំណាច។ សមាជិកក្រុមប្រឹក្សាឃុំរបស់គណបក្ស CNRP ត្រូវបានផ្តល់ឱកាសអោយរក្សាកៅអីរបស់គេ បើគេចុះចូលជាមួយគណបក្ស CPP ហើយប្រកាសជាសាធារណៈថា កឹម សុខាគឺជាជនក្បត់ជាតិ។

<u>ការចូលរួមរបស់ស្ត្រី និងក្រុមជនជាតិភាគតិច៖</u>គ្មានច្បាប់ដែលដាក់កំហិតព្រំដែនលើការចូលរួមរបស់ស្ត្រី និងជនជាតិភាគតិច នៅក្នុងដំណើរការនយោបាយទេ តែវប្បធម៌ប្រពៃណីកម្រិតការចូលរួមរបស់ស្ត្រីនៅក្នុងនយោបាយ និងរដ្ឋាភិបាល ។ ទោះបីជាគណបក្សធំៗទាំងពីរបានសន្យាម្តងហើយម្តងទៀតថា នឹងបង្កើនតំណាងរបស់ស្ត្រីក្តី តែចំនួនបេក្ខជនជាស្ត្រីដែលជាប់ឆ្នោតនៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ តាមពិតទៅ មានការថយចុះពីលទ្ធផល ឆ្នាំ ២០១២។ ការបោះឆ្នោតនៅខែមិថុនាក៏មានការចូលរួមផងដែរនៃគណបក្សប្រជាធិបតេយ្យជនជាតិដើមកម្ពុជា។

## ផ្នែកទី៤ ៖ អំពើពុករលួយ និងកង្វះតម្លាភាពក្នុងរដ្ឋាភិបាល

ច្បាប់មានចែងអំពីទោសព្រហ្មទណ្ឌសម្រាប់អំពើពុករលួយដែលប្រព្រឹត្តដោយមន្ត្រីនានា ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលមិនបានអនុវត្តច្បាប់នេះប្រកបដោយប្រសិទ្ធភាពឡើយ ហើយមន្ត្រីជាញឹកញាប់តែងតែប្រព្រឹត្តអំពើពុករលួយដោយមាននិទណ្ឌភាព ។

<u>អំពើពុករលួយ៖</u> ក្រមព្រហ្មទណ្ឌបានកំណត់អំពើពុករលួយនានា ហើយកំណត់ច្បាស់នូវទោសចំពោះការប្រព្រឹត្តអំពើទាំងនេះ។ ច្បាប់ប្រឆាំងអំពើពុករលួយចែងពីមូលដ្ឋានច្បាប់សំរាប់អោយក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយទទួល និងស៊ើបអង្កេតបណ្តឹងទាក់ទងនឹងអំពើពុករលួយ។ អង្គភាពប្រឆាំងអំពើពុករលួយមិនសហការអោយបានញឹកញាប់ជាមួយសង្គមស៊ីវិល ហើយត្រូវបានគេមើលឃើញថា គ្មានប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ ផ្ទុយទៅវិញ អង្គភាពប្រឆាំងអំពើពុករលួយមានភាពសកម្មនៅក្នុងការដឹកនាំការស៊ើបអង្កេតទៅលើសមាជិកនៃគណបក្សប្រឆាំង ដែលជាការនាំអោយគេនាំគ្នាយល់ថា អង្គភាពនេះបំរើផលប្រយោជន៍របស់គណបក្សកាន់អំណាច។ ផ្ទុយទៅវិញ អង្គភាពនេះមិនដែលស៊ើបអង្កេតសមាជិកជាន់ខ្ពស់នៃគណបក្ស

កាន់អំណាចទេ។ មន្ត្រីរាជការត្រូវមានការយល់ព្រមពីប្រធាន មុនពេលឆ្លើយសំណួររបស់សាខានិតិបញ្ញាតិ ទាក់ទងនឹងការចោទប្រកាន់ទាក់ទងនឹងអំពើពុករលួយ។

អំពើពុករលួយមានលក្ខណៈរាលដាល នៅក្នុងសង្គម និងរដ្ឋាភិបាល។ មានសេចក្តីរាយការណ៍មកថា នគរបាល ព្រះរាជអាជ្ញា ចៅក្រមស៊ើបអង្កេត និងចៅក្រមជំរះក្តី បានទទួលសំណូកពីអ្នករកស៊ីខុសច្បាប់។ ពលរដ្ឋតែងតែត្អូញត្អែជាសាធារណៈអំពីអំពើពុករលួយ។ បៀវត្សរ៍មិនគ្រប់គ្រាន់រួមចំណែកអោយ មាន"អំពើពុករលួយដើម្បីរស់" ក្នុងចំណោមមន្ត្រីថ្នាក់ទាប ចំណែកវប្បធម៌និទណ្ឌភាពធ្វើអោយអំពើពុករលួយរីកសាយក្នុងចំណោមមន្ត្រីជាន់ខ្ពស់ ។

យោងតាមអង្គការសន្ទស្សន៍យល់ឃើញស្តីពីអំពើពុករលួយ ឆ្នាំ ២០១៦ របស់អង្គការតំលាភាពអន្តរជាតិ (Transparency International) ប្រទេសកម្ពុជាស្ថិតនៅក្នុងចំណោមប្រទេសពុករលួយបំផុត នៅក្នុងពិភពលោក។ បើយោងតាមការវាស់ស្ទង់ដែលមានឈ្មោះថា 2016 Global Corruption Barometer តុលាការគឺជាវិស័យដែលពុករលួយជាងគេ នៅក្នុងរយៈពេល ៣ ឆ្នាំជាប់គ្នា ដែលបន្ទាប់មកមានផ្នែកអនុវត្តច្បាប់ និងមន្ត្រីរដ្ឋាភិបាល។ នៅខែកក្កដា មន្ត្រី២ រូបនៅក្នុងក្រសួងរ៉ែ និងថាមពល ដែលត្រូវបានរកឃើញថា មានទោសពុករលួយ បានរួចខ្លួន បន្ទាប់ពីចៅក្រមនិយាយថា ពួកគេបានបំពេញរយៈពេលមានទោសខ្លះហើយ ហើយបានព្យួរទោសដែលនៅសល់។ មានភាពប្រសើរឡើងខ្លះ នៅក្នុងការខិតខំរបស់រដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក្នុងវិស័យអប់រំ។

<u>ការប្រកាសទ្រព្យសម្បត្តិ៖</u> រាជការ រួមទាំងមន្ត្រីតែងតាំង និងមន្ត្រីជាប់ឆ្នោតផង តាមច្បាប់ ត្រូវប្រកាសទ្រព្យសម្បត្តិរបស់គេ។ អង្គភាពប្រឆាំងអំពើពុករលួយ (ACU) ទទួលខុសត្រូវក្នុងការទទួលយកសេចក្តីប្រកាស ចំណែកការពិន័យចំពោះការមិនគោរពតាមមានការជាប់ពន្ធនាគាររាប់ពី ១ ខែទៅ ១ ឆ្នាំ។ ការប្រកាសទ្រព្យសម្បត្តិរបស់មន្ត្រីជាន់ខ្ពស់មិនត្រូវបានអោយដឹងដល់សាធារណៈទេ ហើយនៅបិទជិតក្នុងស្រោមសំបុត្រ រហូតទាល់តែមានការប្តឹងទាក់ទងនឹងអំពើពុករលួយ។ មានតែសេចក្តីប្រកាសទ្រព្យសម្បត្តិតែមួយគត់ត្រូវបានបើកមើល គឺសេចក្តីប្រកាសរបស់អតីតប្រធានគណបក្ស CNRP កឹម សុខា ។ នៅខែមិថុនា ACU តំរូវអោយមេឃុំ និងសមាជិកក្រុមប្រឹក្សាទាំងអស់ប្រកាសទ្រព្យសម្បត្តិរបស់គេ។ អ្នកសង្កេតការណ៍យល់ឃើញថា វាជាវិធីដើម្បីគំរាមក្រុមប្រឹក្សាឃុំដែលមកពីគណបក្ស CNRP ។

**ផ្នែកទី៥ ៖ឥរិយាបថរបស់រដ្ឋាភិបាលចំពោះការស៊ើបអង្កេតរបស់អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលលើការចោទប្រកាន់ពីបទរំលោភសិទ្ធិមនុស្ស**

មានរបាយការណ៍ជាច្រើនអំពីកង្វះការសហការ ហើយនៅក្នុងករណីមួយចំនួន មានការបំភិតបំភ័យដោយមន្ត្រីរដ្ឋាភិបាល ដូចជាករណីប្រឆាំងនឹងបុគ្គលិកនៃសមាគមអាដហុក (សូមមើលផ្នែក ១ ង) ។

អង្គការសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិរងកំណើននៃការគម្រាមកំហែង ការតាមដាន ការគំរាមកំហែង និងការសំឡុតពីមន្ត្រីមូលដ្ឋាន និងអ្នកដែលមានទំនាក់ទំនងជាមួយរដ្ឋាភិបាល ។ អំពើទាំងនេះមានលក្ខណៈជាទម្រង់រឹតត្បិត និងការរំខានដល់ការជួបប្រជុំដែលឧបត្ថម្ភដោយអង្គការមិនមែនរដ្ឋាភិបាលនានា ការបំភិតបំភ័យដោយពាក្យសម្តី ការគម្រាមចាត់វិធានការផ្លូវច្បាប់ ការតាមសង្កេតមើលលើការងារ និងសកម្មភាពផ្ទាល់ខ្លួន និងការរារាំងតាមបែបការិយាធិបតេយ្យ ដោយផ្អែកលើបទបញ្ញាតិ ។

មានអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារផ្នែកសិទ្ធិមនុស្សប្រមាណជា ២៥ នៅក្នុងប្រទេស និងមានចំនួនប្រហែល ១០០ ទៀតដែលផ្តោតការយកចិត្តទុកដាក់លើសិទ្ធិមនុស្សជាផ្នែកមួយនៃការងាររបស់គេនៅក្នុងវិស័យផ្សេងទៀត ប៉ុន្តែមានតែអង្គការមួយចំនួនតូចប៉ុណ្ណោះ ដែលធ្វើសកម្មក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាល ឬស៊ើបអង្កេតការរំលោភសិទ្ធិមនុស្ស ។

<u>អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដទៃទៀត</u>៖ រដ្ឋាភិបាលជាទូទៅបានអនុញ្ញាតអោយតំណាងអង្គការសហប្រជាជាតិមកធ្វើទស្សនកិច្ច ។ នៅខែសីហា អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា លោកស្រី Rhona Smith បានមកធ្វើទស្សនកិច្ចនៅកម្ពុជាជាលើកទី ៤។ នៅក្នុងការប្រជុំ លោកស្រីបានពិភាក្សាពីការគំរាមកំហែងរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចថា នឹងបង្ក្រាបលើសង្គមស៊ីវិល វិសោធនកម្មលើច្បាប់ស្តីពីគណបក្សនយោបាយ ក្រុមដែលស្ថិតក្នុងស្ថានភាពខ្សត់ខ្សោយ និងមិនសូវទទួលបានការយកចិត្តទុកដាក់ ដូចជាក្រុមស្ត្រី ជនជាតិភាគតិច និងជនរងគ្រោះដោយការប្រកាន់ពូជសាសន៍ និងប្រកាន់ជាតិពន្ធ ការប្រើប្រាស់នូវមធ្យោបាយឃុំខ្លួនបណ្តោះអាសន្ន។ រដ្ឋាភិបាលតែងតែរិះគន់តំណាងពិសេសនៃអង្គការសហប្រជាជាតិជាសាធារណៈ ចំពោះការនិយាយរបស់គេស្តីពីបញ្ហានានាផ្នែកសិទ្ធិមនុស្ស។ ជាធម្មតា រដ្ឋាភិបាលតែងតែបដិសេធសំណើធ្វើទស្សនកិច្ចផ្លូវការរបស់អ្នករាយការណ៍ពិសេសដទៃទៀតរបស់អង្គការសហប្រជាជាតិ។

<u>ស្ថាប័នសិទ្ធិមនុស្សរបស់រដ្ឋាភិបាល</u>៖ រដ្ឋាភិបាលមានស្ថាប័នសិទ្ធិមនុស្សចំនួន ៣ ដែលរួមមានគណៈកម្មាធិការដាច់ដោយឡែក ទទួលបន្ទុកការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង នៅក្រោមព្រឹទ្ធសភា និងរដ្ឋសភា ព្រមទាំងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដែលស្ថិតនៅក្រោមខុទ្ទកាល័យនាយករដ្ឋមន្ត្រី។ គណៈកម្មាធិការទាំងនេះពុំមានការប្រជុំទៀងទាត់ ឬដំណើរការប្រកបដោយតម្លាភាពឡើយ។ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាប្រគល់របាយការណ៍របស់រដ្ឋាភិបាល ដើម្បីចូលរួមក្នុងដំណើរការពិនិត្យសិទ្ធិមនុស្សជាអន្តរជាតិ ដូចជាការពិនិត្យទៀងទាត់ជាសកល និងបានឆ្លើយតបចំពោះរបាយការណ៍របស់ស្ថាប័នរដ្ឋាភិបាល និងអង្គការអន្តរជាតិ ប៉ុន្តែមិនបានធ្វើការស៊ើបអង្កេតស្ថានភាព

សិទ្ធិមនុស្សដោយឯករាជ្យឡើយ។ អង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សដែលគួរឱ្យទុកចិត្តបានចាត់ទុកថា គណៈកម្មាធិការរបស់រដ្ឋាភិបាលថា មានប្រសិទ្ធភាពការងារនៅមានកំរិត ហើយបានរិះគន់តួនាទីរបស់គេនៅក្នុងការនិយាយការពារការបង្ក្រាបរបស់រដ្ឋាភិបាល ទៅលើសង្គមស៊ីវិល និងអ្នកប្រឆាំង។

រដ្ឋាភិបាលបានបន្តធ្វើជាម្ចាស់ផ្ទះសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (ECCC) ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៦ ដើម្បីធ្វើការស៊ើបអង្កេត និងដាក់ទោស មេដឹកនាំខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើយង់ឃ្នង ដែលត្រូវបានប្រព្រឹត្តពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែលនៅក្នុងនោះ ប្រជាជននៅក្នុងប្រទេសចំនួនជិត ១ ភាគ ៤ បានស្លាប់។ ECCC គឺជាតុលាការកូនកាត់ ដោយមានបុគ្គលិក និងចៅក្រមជាតិ និងអន្តរជាតិ ហើយគ្រប់គ្រងដោយច្បាប់ក្នុងស្រុករបស់កម្ពុជាផង និងកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល និងអង្គការសហប្រជាជាតិផង។ នៅខែវិច្ឆិកា ឆ្នាំ ២០១៦ តុលាការកំពូលនៃតុលាការនេះបានតំកល់ការដាក់ទោសទៅលើឈ្មោះ នួន ជា និង ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ជនទាំងពីរនាក់នេះប្រឈមនឹងការចោទប្រកាន់ថែមទៀត ដែលរួមមានបទប្រល័យពូជសាសន៍ នៅក្នុងសវនាការលើកទី ២ ដែលបានបញ្ចប់នៅខែមិថុនា។ តុលាការមិនទាន់ចេញសាលដីការនៅឡើយទេ។

## ផ្នែកទី៦៖ ការរើសអើង ការរំលោភបំពានក្នុងសង្គម និងការជួញដូរមនុស្ស

រដ្ឋធម្មនុញ្ញហាមប្រាមការរើសអើងទាក់ទងនឹងពូជសាសន៍ យេនឌ័រ ពិការភាព ភាសា ឬឋានៈសង្គម ប៉ុន្តែ ជាទូទៅ រដ្ឋាភិបាលមិនបានអនុវត្តបំរាមទាំងនេះអោយមានប្រសិទ្ធភាពឡើយ ។

## ស្ត្រី

ការ<u>រំលោភសេពសន្ថវៈ និងហឹង្សាក្នុងគ្រួសារ៖</u> ច្បាប់ដាក់ទោសព្រហ្មទណ្ឌចំពោះអំពើរំលោភសេពសន្ថវៈ និងការបំពារបំពាន។ អំពើរំលោភសេពសន្ថវៈត្រូវកាត់ទោសឱ្យជាប់ពន្ធនាគារពី ៥ឆ្នាំ ទៅ ៣០ឆ្នាំ។ អំពើរំលោភសេពសន្ថវៈ ប្តី/ប្រពន្ធមិនត្រូវបានចែងជាក់លាក់នៅក្នុងក្រមព្រហ្មទណ្ឌឡើយ ប៉ុន្តែ អាចធ្វើការចោទប្រកាន់ថាជា “អំពើរំលោភសេពសន្ថវៈ” “ការបង្ករបួសស្នាម” ឬ “ការបំពារបំពានមិនសមរម្យ”បាន។ កម្រមានការចោទប្រកាន់ពីបទរំលោភសេពសន្ថវៈប្តី/ប្រពន្ធតាមក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារណាស់។ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារកំណត់ដាក់ទោសព្រហ្មទណ្ឌចំពោះអំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែ មិនមានចែងជាក់លាក់អំពីការដាក់ទោសឡើយ។ ប៉ុន្តែ គេអាចប្រើក្រមព្រហ្មទណ្ឌ ដើម្បីដាក់ទោសចំពោះបទល្មើសហឹង្សាក្នុងគ្រួសារ ដោយដាក់ទោសពន្ធនាគារចាប់ពី ១ ឆ្នាំ រហូតដល់ ១៥ឆ្នាំ។

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិបានរាយការណ៍ថា អំពើហិង្សាប្រឆាំងស្ត្រី មានដូចជាអំពើហឹង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ កើតមានជាទូទៅ។ អំពើហិង្សាក្នុងគ្រួសារនិងការរំលោភផ្លូវភេទច្រើនតែ

មិនត្រូវបានគេរាយការណ៍អស់ ដោយសារជនរងគ្រោះខ្លាចការសងសឹកដោយជនល្មើស ការរើសអើងនៅក្នុងសង្គម និងការដែលគេមិនទុកចិត្តប្រព័ន្ធតុលាការ។

អង្គការ NGO បាននិយាយថា អាជ្ញាធរមិនសូវប្រឹងប្រែងខ្លាំងក្នុងការអនុវត្តច្បាប់គ្រួសារទេ ហើយជៀសវាងការពាក់ព័ន្ធក្នុងជំលោះក្នុងគ្រួសារ។

នៅខែកក្កដា ក្រសួងព័ត៌មាន និងក្រសួងកិច្ចការនារីបានចាប់ផ្តើមអនុវត្តក្រមអាកប្បកិរិយាសំរាប់ប្រព័ន្ធផ្សព្វផ្សាយទាក់ទងនឹងហឹង្សាទៅលើនារី។ ក្រមនេះហាមប្រាមការបោះពុម្ភព័ត៌មាន ដែលរួមទាំងរូបនៃជនរងគ្រោះ ការបង្ហាញពីការស្លាប់ របួស ឬភាពអាក្រាតរបស់ជនរងគ្រោះ ការប្រើពាក្យប្រមាថទៅលើស្ត្រី។ ជាដំបូង ក្រសួងកិច្ចការនារីបានប្រកាសពីប្រព័ន្ធធ្វើសេចក្តីរាយការណ៍ នៅក្នុងជួររដ្ឋាភិបាល ដើម្បីបង្កើនតំលាភាព និងគណនេយ្យភាពនៅក្នុងការឆ្លើយតបរបស់រដ្ឋាភិបាល ចំពោះហឹង្សាទៅលើស្ត្រី។ ក្រសួងកិច្ចការនារីថែមទាំងបានធ្វើការសំរបសំរួលជាមួយអង្គការ NGO មួយចំនួន និងផ្នែកសារព័ត៌មានខ្លះ ដើម្បីធ្វើកម្មវិធីតាមវិទ្យុ និងទូរទស្សន៍ស្តីពីបញ្ហាទាក់ទងនឹងស្ត្រី។

<u>ការបៀតបៀនផ្លូវភេទ៖</u> ក្រមព្រហ្មទណ្ឌដាក់ទោសព្រហ្មទណ្ឌចំពោះការបៀតបៀនផ្លូវភេទ ដោយដាក់ពន្ធនាគារពី ៦ ថ្ងៃទៅ ៣ ខែ និងពិន័យជាទឹកប្រាក់ចំនួនពី ១០០ ០០០រៀលទៅ ៥០០ ០០០រៀល (២៥ ទៅ ១២៥ ដុល្លារអាមេរិក)។ ការសិក្សាមួយដែលត្រូវបានធ្វើក្នុងឆ្នាំនៃរបាយការណ៍នេះ ដោយអង្គការ CARE International បានរកឃើញថា ជិត ១ ភាគ ៣ នៃកម្មការិនីរោងចក្រកាត់ដេរធ្លាប់ត្រូវបានគេបៀតបៀនផ្លូវភេទ នៅកន្លែងធ្វើការរបស់គេ នៅក្នុងរយៈពេល ១២ ខែចុងក្រោយនេះ។

<u>ការបង្ខិតបង្ខំក្នុងការកំណត់ចំនួនប្រជាជន៖</u> គ្មានការនិយាយពីរំលូតកូនដោយបង្ខំ ការធ្វើមិនអោយមានកូនដោយមិនទៅតាមការស្ម័គ្រចិត្ត ឬវិធីកំណត់ចំនួនកូនដោយបង្ខំណាផ្សេងទេ។ ចំនួនប៉ាន់ប្រមាណលើការស្លាប់របស់ម្តាយ និងអត្រាប្រេវ៉ាឡង់នៃការប្រើវិធីការពារមិនអោយមានកូន មាននៅក្នុងគេហទំព័រ
www.who.int/reproductivehealth/publications/monitoring/maternal-mortality-2015/en/ ។

<u>ការរើសអើង៖</u> រដ្ឋធម្មនុញ្ញចែងអំពីសិទ្ធិស្មើភាពគ្នាសំរាប់ស្ត្រី ការទទួលបានប្រាក់កម្រៃស្មើគ្នាចំពោះការងារដូចគ្នា និងឋានៈស្មើគ្នាក្នុងអាពាហ៍ពិពាហ៍។ ជាទូទៅ ស្ត្រីមានសិទ្ធិលើទ្រព្យសម្បត្តិស្មើភាពគ្នា មានសិទ្ធិតាមផ្លូវច្បាប់ដូចគ្នាក្នុងការដាក់ពាក្យបណ្តឹងលែងលះ និងសិទ្ធិស្មើគ្នាក្នុងការទទួលបានការអប់រំ និងការងារមួយចំនួន។ ប៉ុន្តែ ប្រពៃណីវប្បធម៌ និងការទទួលខុសត្រូវក្នុងការមើលកូនបានកម្រិតលទ្ធភាពរបស់ស្ត្រី ក្នុងការឈានទៅដល់ការទទួលបានមុខតំណែងខ្ពស់នៅក្នុងការងារ ឬបានការងារធ្វើ។

**កុមារ**

<u>ការចុះសំបុត្រកំណើត៖</u> តាមច្បាប់ សញ្ជាតិអាចទទួលបានតាមរយៈកំណើតពីឪពុកម្តាយដែលមិនមែនជាជនជាតិខ្មែរ ក្នុងករណីដែលឪពុកម្តាយទាំងពីរនោះបានកើត និងរស់នៅដោយស្របច្បាប់នៅក្នុងប្រទេសកម្ពុជា ឬករណីដែលឪពុក/ម្តាយណាម្នាក់ទទួលបានសញ្ជាតិកម្ពុជាតាមរយៈមធ្យោបាយផ្សេងទៀតតាមផ្លូវច្បាប់។ ជនជាតិខ្មែរដើមត្រូវបានចាត់ទុកថាជាពលរដ្ឋ។ ក្រសួងមហាផ្ទៃបានគ្រប់គ្រងប្រព័ន្ធចុះបញ្ជីកំណើតតាមបែបទំនើប ប៉ុន្តែទារកទាំងអស់មិនសុទ្ធតែត្រូវបានចុះបញ្ជីភ្លាមៗឡើយ ដោយសារតែឪពុកម្តាយពន្យារពេល។ ក្រៅពីនេះ កុមារដែលបានកើតចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៧០ ដល់ពាក់កណ្តាល ទសវត្សរ៍ឆ្នាំ១៩៩០ ជាទូទៅ មិនត្រូវបានចុះបញ្ជីកំណើតឡើយ ដោយសារការគ្រប់គ្រងរបស់វៀតណាម/ខ្មែរ ក្រហម/សង្គ្រាមស៊ីវិល។ អ្នកដែលមិនបានចុះបញ្ជីទាំងនេះជាច្រើន ដែលក្រោយមកមានគ្រួសារផ្ទាល់ខ្លួន មិនបានយល់អំពីភាពចាំបាច់នៃការចុះបញ្ជីនេះទេ។ ជាទូទៅ កុមារមិនទៅចុះបញ្ជីកំណើតឡើយ រហូតទាល់តែគេត្រូវការចាំបាច់។

ការខកខានមិនបានចុះបញ្ជីកំណើតនាំអោយមានការរើសអើង រួមទាំងការមិនផ្តល់សេវាសាធារណៈផង។ ការសិក្សាមួយនៅឆ្នាំ ២០០៧ ដែលធ្វើឡើងដោយអង្គការ UNHCR ស្តីពីភាពគ្មានសញ្ជាតិនៅក្នុងប្រទេសកម្ពុជាបាននិយាយថា ជារឿយៗ កុមារជនជាតិភាគតិច និងកុមារដែលគ្មានសញ្ជាតិត្រូវបានផាត់ចេញពីដំណើរការចុះបញ្ជីកំណើត។ អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាចំពោះសហគមន៍ដែលត្រូវបានគេផាត់ចេញ បានរាយការណ៍ថា ជារឿយៗ កុមារដែលគ្មានសំបុត្រកំណើត និងសៀវភៅគ្រួសារ បាត់បង់លទ្ធភាពទទួលបានការអប់រំ និងការថែទាំសុខភាព។ អង្គការមិនមែនរដ្ឋាភិបាលទាំងនោះក៏បានបញ្ជាក់ផងដែរថា អ្នកទាំងនេះច្រើនតែគ្មានលទ្ធភាពក្នុងការទទួលបានការងារធ្វើ ការមានទ្រព្យសម្បត្តិផ្ទាល់ខ្លួន ការចូលរួមបោះឆ្នោត ឬការប្រើប្រាស់ប្រព័ន្ធច្បាប់។

<u>ការអប់រំ៖</u> ការអប់រំរហូតដល់ថ្នាក់ទី៩ គឺឥតមានបង់ថ្លៃឡើយ ប៉ុន្តែ មិនមែនជាកាតព្វកិច្ចត្រូវតែរៀនទេ។ កុមារជាច្រើនបានឈប់រៀនដើម្បីជួយគ្រួសារក្នុងការងារកសិកម្មលក្ខណៈគ្រួសារ ធ្វើការងារនៅក្នុងសកម្មភាពផ្សេងទៀត ចូលរៀននៅអាយុច្រើន ឬមិនចូលរៀនសោះតែម្តង។ រដ្ឋាភិបាលមិនបដិសេធក្មេងស្រីក្នុងការទទួលបានការអប់រំស្មើភាពគ្នាទេ។ ប៉ុន្តែ ជារឿយៗ គ្រួសារដែលមានធនធានមានកំរិត ផ្តល់អាទិភាពដល់ក្មេងប្រុសជាងក្មេងស្រី ពិសេសនៅតំបន់ជនបទ។ បើយោងតាមរបាយការណ៍អង្គការអន្តរជាតិ បន្ទាប់ពីកម្រិតបឋមសិក្សា ចំនួនក្មេងស្រីចុះឈ្មោះចូលរៀនធ្លាក់ចុះយ៉ាងខ្លាំងនៅតំបន់ក្រុង ចំណែកការចូលរៀនរបស់ក្មេងប្រុសនៅក្រោយថ្នាក់បឋមសិក្សា មានចំនួនធ្លាក់ចុះច្រើនគួរសម នៅតំបន់ជនបទ។

<u>ការរំលោភធ្វើបាបកុមារ៖</u> បើតាមអ្នកសង្កេតការណ៍ ការរំលោភធ្វើបាបកុមារមានជាទូទៅ ហើយការប្តឹងប្រឆាំងនឹងជនប្រព្រឹត្តកម្រមានណាស់។ ការរំលោភសេពសន្ថវៈលើកុមារនៅតែជាបញ្ហាធ្ងន់ធ្ងរមួយនៅឡើយ។

ការរៀបអាពាហ៍ពិពាហ៍ និងការបង្ខំអោយរៀបអាពាហ៍ពិពាហ៍៖ អាយុគ្រប់ការតាមច្បាប់សំរាប់ក្មេងប្រុស និងក្មេងស្រីគឺ ១៨ ឆ្នាំ តែកុមារអាយុត្រឹម ១៦ ឆ្នាំអាចរៀបការដោយស្របច្បាប់បាន បើមានការយល់ព្រមពីឪពុកម្តាយ។ ការរៀបការរបស់កុមារមិនត្រូវបានចាត់ទុកថា ជាបញ្ហាទេ ។

ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ៖ ការរួមភេទជាមួយកុមារអាយុក្រោម ១៥ ឆ្នាំ គឺជាអំពើខុសច្បាប់។ ប៉ុន្តែ ពេស្យាចារកុមារបានកើតឡើង។ រដ្ឋាភិបាលបានបន្តឆ្មក់ផ្ទះបន ដើម្បីរកមើល និងប្រមូលជនរងគ្រោះដោយសារការជួញដូរផ្លូវភេទជាកុមារ ថ្វីបើភាគច្រើននៃការជួញដូរផ្លូវភេទលើកុមារមានការលាក់បាំង មនៅតាមកន្លែងបំរើផ្លូវភេទ "ដោយមិនផ្ទាល់" ដូចជាតាមបៀហ្គាដិន កន្លែងធ្វើម៉ាសា កន្លែងកែសម្ផស្ស បាខារ៉ាអូខេ និងកន្លែងមិនមែនធ្វើពាណិជ្ជកម្មនានា។ នគរបាលបន្តស៊ើបអង្កេតលើករណីជួញដូរកុមារ នៅតាមផ្ទះបន ឬក្នុងករណីដែលជនរងគ្រោះមកប្តឹងដោយផ្ទាល់ តែមិនធ្វើការលើករណីស្មុគស្មាញខ្លាំងទេ។ រដ្ឋាភិបាលមិនបានចេញការណែនាំជាផ្លូវការដែលអនុញ្ញាតអោយមានការប្រើបច្ចេកទេសស៊ើបអង្កេតសំងាត់នៅក្នុងការស៊ើបអង្កេតលើការជួញដូរទេ ហើយកង្វះសិទ្ធិអំណាចច្បាស់លាស់បានបន្តរាំងស្ទះមិនអោយនគរបាលចាប់អោយអ្នកប្រព្រឹត្តិការជួញដូរលើកុមារទទួលខុសត្រូវពេញលេញបានទេ។

ប្រទេសកម្ពុជានៅតែជាគោលដៅទេសចរណ៍ផ្លូវភេទលើកុមារ។ រដ្ឋាភិបាលបានប្រើប្រាស់ច្បាប់ ដើម្បីកាត់ទោសទាំងអ្នកទេសចរផ្លូវភេទ ទាំងពលរដ្ឋដែលកេងប្រវ័ញ្ចកុមារក្នុងពេស្យាចារ។ ច្បាប់ដាក់ទោសជាប់ពន្ធនាគារចាប់ពី ២ ទៅ ១៥ ឆ្នាំ ចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ ច្បាប់នេះក៏ហាមប្រាមផងដែរនូវការផលិត និងការមានរូបអាសអាភាសកុមារ។

បើយោងតាមអង្គការផ្នែកសិទ្ធិមនុស្សក្នុងស្រុកមួយ ជនប្រព្រឹត្តដែលមានខ្សែរយៈក្នុងរដ្ឋាភិបាល មិនត្រូវបានចាប់អោយទទួលខុសត្រូវ នៅក្រោមច្បាប់ឡើយ ហើយអ្នកជំនាញក្នុងស្រុកបានសំដែងកង្វល់អំពីការខកខានរបស់រដ្ឋាភិបាល ក្នុងការដាក់ទោសអោយបានសមស្របទៅលើជនបរទេសដែលទិញការរួមភេទជាមួយកុមារ។ អំពើពុករលួយដែលរាលដាលនៅគ្រប់ផ្នែកទាំងអស់ក្នុងរដ្ឋាភិបាល ដាក់កំហិតព្រំដែនយ៉ាងខ្លាំងលើលទ្ធភាពរបស់មន្ត្រីម្នាក់ៗ ក្នុងការចាប់អោយជនប្រព្រឹត្តការជួញដូរផ្លូវភេទលើកុមារទទួលខុសត្រូវ ហើយរដ្ឋាភិបាលមិនធ្វើការស៊ើបអង្កេតឬកាត់ទោសមន្ត្រីដែលឃុបឃិតឡើយ។

កុមារផ្លាស់ទីលំនៅ៖ រដ្ឋាភិបាលបានផ្តល់សេវាមានកំរិត និងមិនគ្រប់គ្រាន់ដល់កុមាររស់នៅតាមចិញ្ចើមថ្នល់ នៅមជ្ឈមណ្ឌលស្តារនីតិសម្បទា។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយបានវាយតម្លៃថា មានកុមារតាមចិញ្ចើមផ្លូវក្នុងចំនួនប្រហែលជាពី ១២០០ ទៅ ១៥០០ នាក់នៅក្នុងរាជធានីភ្នំពេញ ដែលគ្មានទំនាក់ទំនងគ្រួសារ ហើយកុមារប្រមាណជាពី ១៥ ០០០ ទៅ ២០ ០០០នាក់ បានធ្វើការងារនៅតាមចិញ្ចើមផ្លូវ ប៉ុន្តែ បានត្រឡប់ទៅផ្ទះវិញនៅពេល

យប់។ កុមារប្រមាណជា ២០០ ទៅ ៤០០ នាក់បានរស់នៅជាមួយគ្រួសាររបស់ខ្លួននៅតាមចិញ្ចើមផ្លូវនៃរាជធានីភ្នំពេញ។

អង្គការ NGO និងអ្នកសង្កេតការណ៍ដទៃទៀតបានចោទថា មជ្ឈមណ្ឌលកុមារកំព្រាឯកជនជាច្រើនគ្មានការគ្រប់គ្រងល្អទេ ហើយមានកុមារអត់កំព្រាច្រើន ដើម្បីទាក់ទាញអំណោយពីជនបរទេស។

<u>ការចាប់ជំរិតកុមារឆ្លងដែន៖</u> ប្រទេសកម្ពុជាមិនមែនជាហត្ថលេខីនៃអនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩៨០ ស្តីពីទិដ្ឋភាពស៊ីវិលនៃការចាប់ជំរិតកុមារឆ្លងដែនឡើយ។ សូមមើលរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិកស្តីពីការចាប់កុមារឆ្លងដែន តាម travel.state.gov/content/childabduction/en/legal/compliance.html ។

<u>ការប្រឆាំងនឹងសាសនាជ្វីស (Anti-Semitism)</u>

មានសហគមន៍អនិកជនកាន់សាសនាជ្វីសតូចមួយនៅក្នុងរាជធានីភ្នំពេញ ហើយមិនមានរបាយការណ៍អំពីទង្វើប្រឆាំងនឹងសាសនានេះឡើយ។

## ការជួញដូរមនុស្ស

សូមចូលមើល*របាយការណ៍ស្តីពីការជួញដូរមនុស្ស* របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក នៅគេហទំព័រ www.state.gov/j/tip/rls/tiprpt/។

# ជនពិការ

ច្បាប់ហាមប្រាមការរើសអើង ការព្រងើយកន្តើយ ការកេងប្រវ័ញ្ច ឬការបោះបង់ជនពិការ ។ តាមច្បាប់នេះជនពិការរាប់ទាំងជនមានជំងឺផ្នែកសតិបញ្ញា។ ច្បាប់នេះមិននិយាយពីការបង្ករលក្ខណៈងាយស្រួលសំរាប់ជនពិការ ក្នុងការធ្វើដំណើរតាមយន្តហោះ ឬមធ្យោបាយធ្វើដំណើរណាផ្សេងទេ។ ក្រសួងសង្គមកិច្ចជាអ្នកទទួលខុសត្រូវរួមក្នុងការការពារសិទ្ធិរបស់ជនពិការ ថ្វីបើច្បាប់កំណត់ដាក់ភារកិច្ចដោយឡែកជាក់លាក់សំរាប់ក្រសួងដទៃទៀត ដែលរួមមានក្រសួងសុខាភិបាល អប់រំ សាធារណការ និងដឹកជញ្ជូននិងក្រសួងការពារជាតិ។ រដ្ឋាភិបាលសុំអោយគ្រប់ស្ថានីយ៍ទូរទស្សន៍ទាំងអស់មានកម្មវិធីបកប្រែជាភាសាសញ្ញាអមកម្មវិធីផ្សាយរបស់គេ។ មកដល់ត្រឹមខែមិថុនា មានស្ថានីយ៍ទូរទស្សន៍ធំៗពីរ ដែលមួយជាទូរទស្សន៍ និងមួយទៀតជាទូរទស្សន៍ឯកជន មានការបកប្រែភាសាជាភាសាសញ្ញា

ដោយនៅក្នុងឆ្នាំ ២០១៦ មានតែទូរទស្សន៍មួយទេ បកប្រែកម្មវិធីជាភាសាសញ្ញា។ ជនពិការជួបប្រទះការរើសអើងជាច្រើនពីសង្គម ជាពិសេសក្នុងការទទួលការងារជំនាញ ។

កុមារដែលមានភាពពិការខ្លះៗបានចូលរៀននៅសាលាធម្មតា។ បើយោងតាមក្រសួងអប់រំ កុមារពិការចំនួន ១៩ ០០០ នាក់ បានរៀននៅសាលាបឋមសិក្សា ក្នុងឆ្នាំសិក្សា ២០១៥ -២០១៦។ ក្រសួងបានធ្វើការលើការបណ្តុះបណ្តាលគ្រូស្តីពីវិធីបញ្ចូលសិស្សពិការអោយរៀនជាមួយសិស្សមិនពិការ។

កុមារដែលពិការខ្លាំងបានរៀននៅសាលាដោយឡែក ដែលឧបត្ថម្ភដោយអង្គការ NGO នៅភ្នំពេញ។ ការសិក្សាសំរាប់ពួកគេគ្មាននៅក្រៅភ្នំពេញទេ។

ពុំមានការកម្រិតតាមច្បាប់ណាមួយចំពោះសិទ្ធិជនពិការក្នុងការបោះឆ្នោត ឬចូលរួមក្នុងកិច្ចការនានារបស់ពលរដ្ឋឡើយ ប៉ុន្តែរដ្ឋាភិបាលមិនបានចូលរួមខិតខំប្រឹងប្រែង ដើម្បីជួយដល់ជនពិការអោយចូលរួមកាន់ តែច្រើនក្នុងនាមជាពលរដ្ឋឡើយ ។

**សញ្ជាតិ/ពូជសាសន៍/ជាតិពន្ធុភាគតិច**

សិទ្ធិរបស់ជនជាតិភាគតិច តាមច្បាប់សញ្ជាតិ មិនមានចែងច្បាស់លាស់នោះទេ ។ការការពារតាមរដ្ឋធម្មនុញ្ញមានផ្តល់តែចំពោះ “ពលរដ្ឋខ្មែរ”តែប៉ុណ្ណោះ ។ ពលរដ្ឋជាជនជាតិដើមកំណើតចិន និងវៀតណាម មានចំនួនច្រើនជាងគេ នៅក្នុងជាតិពន្ធុភាគតិច ។ ប្រជាពលរដ្ឋដើមកំណើតចិនត្រូវបានទទួលយកនៅក្នុងសង្គម ប៉ុន្តែការស្អប់ខ្ពើមនៅតែមានជាបន្តចំពោះជនជាតិដើមកំណើតវៀតណាម ដែលត្រូវបានគេមើលឃើញថា ជាការគម្រាមកំហែងចំពោះប្រព័ន្ធនយោបាយ សន្តិសុខ និងវប្បធម៌របស់ប្រទេស ។ នៅក្នុងឆ្នាំនៃរបាយការណ៍នេះ អាជ្ញាធរបានចាប់ប្រមូលជនជាតិវៀតណាមដែលត្រូវបានចោទថា ជាជនអន្តោប្រវេសន៍ខុសច្បាប់។ រដ្ឋាភិបាលថែមទាំងបានធ្វើការពិនិត្យមើលឡើងវិញនូវចំនួនអាណិកជនវៀតណាម ដែលមានជាច្រើននាក់បានរស់នៅក្នុងប្រទេសកម្ពុជា រាប់ទសវត្សមកហើយ ដោយមានបំណងចាប់បញ្ជូនពួកគេត្រឡប់ទៅវៀតណាមវិញ បើគេគ្មានភស្តុតាងបង្ហាញថា គេមានសញ្ជាតិខ្មែរ។ ការមិនចេះនិយាយភាសាខ្មែរត្រូវបានចាត់ទុកថា ជាភស្តុតាងថា គេមិនមែនជាពលរដ្ឋខ្មែរទេ។

**ជនជាតដើម**

ដើម្បីជួយដល់ការខិតខំរបស់សហគមន៍ជនជាតិដើម នៅក្នុងកាការពារដីធ្លីពីដូនតា និងធនធានធម្មជាតិរបស់ខ្លួន ក្រសួងដែនដីបានចេញប័ណ្ណកម្មសិទ្ធិដីរួម របស់ជនជាតិចំនួន ៧ សហគមន៍ នៅក្នុងឆ្នាំនៃរបាយការណ៍នេះ។ គិតមកត្រឹមខែមិថុនា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា មានតែសហគមន៍ជនជាតិដើមចំនួនតែ ១៨ ប៉ុណ្ណោះក្នុងចំណោមសហគមន៍ជនជាតិដើមចំនួន ៤៥៨ ដែលបានទទួលប័ណ្ណកម្មសិទ្ធិដី ពីរដ្ឋាភិបាល។

## ការរំលោភបំពានពីសង្គម ការរើសអើង និងអំពើហឹង្សាដោយផ្អែកលើប្រភេទនៃចំណង់ផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ

គ្មានច្បាប់ដែលដាក់ទោសចំពោះការរួមភេទនៃមនុស្សភេទដូចគ្នាទេ ហើយក៏គ្មានការរើសអើងជាផ្លូវការចំពោះក្រុមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស បុគ្គលស្រឡាញ់ទាំងពីរភេទ និងបុគ្គលប្តូរភេទ (LGBTI) ទេ ទោះបីជាការរើសអើង និងការពេបជ្រាយនៅតែមាន ជាពិសេសនៅតំបន់ជនបទ។

ជាទូទៅ ក្រុម LGBTI ពុំសូវមានឱកាសទទួលបានការងារធ្វើទេ ដោយសារមានការរើសអើងនិងការផាត់ពួកគេចេញ។ មនុស្សក្នុងក្រុមនេះ ច្រើនតែត្រូវបានគេយាយី និងសំលុត ដោយសាររាងរៅរបស់គេ និងការងាររបស់គេនៅក្នុងកន្លែងកំសាន និងផ្នែកជួញដូរផ្លូវភេទ។ ពុំមានរបាយការណ៍អំពីការរើសអើងដោយរដ្ឋាភិបាលដោយសារប្រភេទនៃចំណង់ផ្លូវភេទ នៅក្នុងការងារ ភាពជាពលរដ្ឋ ការទទួលបានការសិក្សា ឬការថែទាំសុខភាពទេ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ប្រជាជនទូទៅមានការខ្លាចឬសង្ស័យចំពោះអ្នកដែលមានការរួមភេទជាមួយមនុស្សភេទដូចគ្នា។

អង្គការក្នុងស្រុកមួយដែលធ្វើការផ្នែកសិទ្ធិរបស់ក្រុមមនុស្សនៅក្នុងក្រុម LGBTI បានរាយការណ៍ពីករណីចំនួនជាង ១០០ នៃហឹង្សាឬការធ្វើបាបទៅលើសមាជិកក្នុងក្រុមមនុស្សនេះ ដូចជាហឹង្សាប្រព្រឹត្តដោយសមាជិកក្នុងគ្រួសារ។ ការមាក់ងាយ ឬការគំរាមប្រហែលជាបារាំងមិនអោយគេប៊ានិយាយប្រាប់។

មានរបាយការណ៍មួយចំនួនតូច ដែលបុគ្គលម្នាក់ៗបដិសេធមិនព្រមផ្តល់ការងារ ជួលអចលនទ្រព្យ ទៅអោយបុគ្គលដោយសារបញ្ហាប្រភេទចំណង់ផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័រ ។

## ការមាក់ងាយក្នុងសង្គមទាក់ទងនឹងជំងឺអេដស៍

ការសិក្សាបង្ហាញថា មានមនុស្សជាច្រើនមានការរើសអើងនឹងអ្នកជំងឺ និងអ្នកមានផ្ទុកមេរោគអេដស៍។

## ផ្នែកទី៧ ៖ សិទ្ធិកម្មករ

### ក. សិទ្ធិបង្កើតអង្គការ/សមាគម និងសិទ្ធិចរចារអនុសញ្ញារួម

ច្បាប់អនុញ្ញាតអោយអ្នកធ្វើការផ្នែកឯកជនបង្កើត និងចូលរួមសហជីពតាមការជ្រើសរើសរបស់ខ្លួនគេផ្ទាល់ សិទ្ធិក្នុងការធ្វើកូដកម្ម និងសិទ្ធិក្នុងការចរចាអនុសញ្ញារួម។ ច្បាប់ថ្មីស្តីពីការចុះបញ្ជីសហជីពមានន័យថា គេត្រូវមានការអនុញ្ញាតជាមុនសិន មុនបង្កើតសហជីព ។ សភាជាតិបានចេញច្បាប់ថ្មីស្តីពីសហជីព (TUL) នៅខែមេសា ឆ្នាំ ២០១៦។ បទបញ្ជាសំរាប់អនុវត្តចំនួន ៤ ត្រូវបានចេញនៅខែសីហា តែយ៉ាងហោចណាស់នៅមាន ៥ ទៀត ដែលមិនទាន់បានចេញ។

TUL ដាក់កំហិតព្រំដែនថ្មីលើសិទ្ធិក្នុងការធ្វើកូដកម្ម សំរួលអន្តរាគមរបស់រដ្ឋាភិបាល នៅក្នុងកិច្ចការផ្ទៃក្នុងរបស់សហជីព ផាត់មិនអោយកម្មករប្រភេទខ្លះចូលរួមក្នុងសហជីព ហើយអនុញ្ញាតអោយភាគីទី៣ ស្វែងរកការរំលាយសហជីព ដោយទន្ទឹមនឹងនោះ ធ្វើការដាក់ពិន័យតិចតួចលើថៅកែ ចំពោះការប្រព្រឹត្តមិនត្រឹមត្រូវជាមួយកម្មករ។ លក្ខខ័ណ្ឌទាមទារថ្មីក្នុងការចុះបញ្ជីរួមមានការដាក់មកនូវធម្មនុញ្ញ ការស្រង់ឈ្មោះមន្ត្រី និងសមាជិកគ្រួសាររបស់គេ ហើយផ្តល់សេចក្តីលំអិតទាក់ទងនឹងធនាគារ ទៅក្រសួងការងារ។ TUL ហាមមិនអោយសហជីពដែលមិនបានចុះបញ្ជីការដំណើរការទេ។ ច្បាប់ក៏ហាមផងដែរមិនអោយសហជីពដែលតំណាងអោយកម្មករចំនួនតិចជាង ១ ភាគ ៣ ចុះកិច្ចព្រមព្រៀងអនុសញ្ញារួម ឬយន្តការដោះស្រាយជំលោះអនុសញ្ញារួម។ នៅក្រោម TUL មន្ត្រីរាជការ គ្រូបង្រៀន អ្នកធ្វើការនៅតាមសហគ្រាសរដ្ឋ និងអ្នកធ្វើការផ្នែកធនាគារ ផ្នែកថែទាំសុខភាព និងវិស័យក្រៅផ្លូវការ អាចបង្កើតបានតែសមាគមទេ មិនអាចបង្កើតសហជីពបានទេ។

ការដែលមានអ្នកចូលសហជីពតិចត្រូវបានបង្ហាញចេញដោយការអង្កេតមួយ ដែលត្រូវបានធ្វើនៅខែមេសា ដោយសហព័ន្ធសហជីព ដែលមានឈ្មោះថា Building and Wood Workers" Trade Union Federation of Cambodia (BWTUC) (BWTUC) ដែលបង្ហាញថា ៩១% នៃកម្មករសំណង់ចំនួន ១០១០ នៅតាមការដ្ឋានក្នុងក្រុងភ្នំពេញ មិនបានចូលជាសមាជិកនៃសហជីពឬសមាគមណាមួយទេ។ នៅក្នុងឧស្សាហកម្មបដិសណ្ឋារកិច្ច អ្នកចូលសហជីពមានចំនួនត្រឹមតែ ២០%ទេ។ សូម្បីតែនៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់និងស្បែកជើងក្តី ក៏អត្រាអ្នកចូលសហជីពមានតែ ២០ ទៅ ៣០ ភាគរយទេ ហើយសហជីពទាំងនេះជាច្រើនតំណាងអោយផលប្រយោជន៍របស់គណបក្ស CPP និងរោងចក្រច្រើនជាងតំណាងអោយផលប្រយោជន៍របស់កម្មករ។

ច្បាប់មានចែងថាកម្មករអាចធ្វើកូដកម្មបាន តែបន្ទាប់ពីបំពេញបានតាមលក្ខខ័ណ្ឌទាមទារមួយចំនួនតែប៉ុណ្ណោះ ដូចជាការចុះបញ្ជីបានត្រឹមត្រូវនៃសហជីព ដូចការដែលវិធីសាស្ត្រដោះស្រាយវិវាទដទៃទៀតមិនបានទទួលជោគជ័យ (ដូចជាការចរចារ ការផ្សះផ្សា ឬការដោះស្រាយដោយអាជ្ញាកណ្តាល ជាដើម) ការបញ្ចប់រយៈពេលរង់ចាំ ៦០ ថ្ងៃ បន្ទាប់ពីមានលេចឡើងនូវជំលោះ ការបោះឆ្នោតដោយសម្ងាត់របស់សមាជិកសហជីព និងការជូនដំណឹងជាមុនរយៈពេលប្រាំពីរថ្ងៃទៅកាន់និយោជក និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MOLVT) ។ អ្នកធ្វើកូដកម្មត្រូវមានទោសព្រហ្មទណ្ឌ បើគេបិទផ្លូវ មាត់ច្រកចូល ឬប្រព្រឹត្តអ្វីផ្សេងទៀត ដែលអាជ្ញាធរមូលដ្ឋានចាត់ទុកថាប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។ TUL ចែងថា ការសំរេចចិត្តធ្វើកូដកម្មទាមទារអោយមានការយល់ព្រមដោយសំលេងភាគច្រើនដាច់ខាតនៃសមាជិកសហជីព ដែលចូលរួមនៅក្នុងការប្រជុំស្តីពីការធ្វើកូដកម្ម ដែលនៅក្នុងអង្គប្រជុំនោះ ត្រូវបានការចូលរួមនៃចំនួនភាគច្រើនដាច់ខាតនៃសមាជិកសហជីពសរុប។ នៅពេលសហជីពបានបោះឆ្នោតដោយជោគជ័យលើការធ្វើកូដកម្មហើយ តុលការអាចចេញសេចក្តីសំរេចប្រឆាំងនឹងការធ្វើកូដកម្ម ហើយតំរូវអោយចាប់ផ្តើមឡើងវិញនូវការចរចាជាមួយនិយោជក។

ការពង្រឹងការអនុវត្តសិទ្ធិក្នុងការចូលរួមក្នុងសមាគម ដោយរួមទាំងសេរីភាពរួចផុតពីការរើសអើងប្រឆាំងនឹងសហជីព និងសេរីភាពក្នុងការធ្វើការចរចាអនុសញ្ញារួម មានលក្ខណៈមិនស៊ីសង្វាក់ទេ។ ទំនាក់ទំនងជិតស្និទ្ធក្នុងចំណោមមន្ត្រីរដ្ឋាភិបាល និយោជក និងមេដឹកនាំសហជីព ពិសេសមេដឹកនាំនៃសហជីពដែលគាំទ្ររដ្ឋាភិបាល ដាក់កំហិតព្រំដែនលើឆន្ទៈរបស់រដ្ឋាភិបាល នៅក្នុងការដោះស្រាយបញ្ហានៃការរំលោភសិទ្ធិកម្មករ។ ទំនាក់ទំនងទាំងនេះធ្វើអោយរាំងស្ទះដល់ការងារឯករាជ្យរបស់សហជីព ពីព្រោះភាគច្រើននៃសហព័ន្ធសហជីពនៅក្នុងប្រទេសមានទំនាក់ទំនងជិតស្និទ្ធជាមួយគណបក្សគ្រប់គ្រងប្រទេស ហើយមានតែភាគតិចទេដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយគណបក្សប្រឆាំង ឬធ្វើការដោយឯករាជ្យ។

កម្មករបាននិយាយពីឧបសគ្គនានានៅក្នុងការអនុវត្តសិទ្ធិរបស់គេក្នុងការចូលរួមក្នុងសមាគមដោយសេរី។ តាមសេចក្តីរាយការណ៍មកថា និយោជកខ្លះមិនព្រមចុះហត្ថលេខាទទួលស្គាល់សហជីពជាផ្លូវការទេ (រដ្ឋាភិបាលមិនផ្តល់ដំណោះស្រាយផ្លូវការទេចំពោះរឿងនេះ) ឬមិនព្រមបន្តកុងត្រារយៈពេលខ្លីដល់កម្មករដែលបានចូលរួមនៅក្នុងសហជីព (ប្រហែល ៨០% នៃកម្មករនៅក្នុងវិស័យកម្មន្តសាលផ្លូវការធ្វើការតាមកុងត្រារយៈពេលខ្លី)។ ដើម្បីចុះបញ្ជីការ

សហជីពត្រូវតែប្រមូលឯកសារពីនិយោជក និងមន្ត្រីអាជ្ញាធរមូលដ្ឋាន ដែលជាញឹកញាប់ មិនព្រមផ្តល់ក្រដាសស្នាមចាំបាច់។ អាជ្ញាធរការងារថ្នាក់ខេត្ត តាមសេចក្តីរាយការណ៍មក បានទុកចោលដោយគ្មានកំណត់ថ្ងៃ នូវពាក្យសុំចុះបញ្ជីការ ដោយសួររកឯកសារបន្ថែម ឬអោយដាក់ពាក្យមកសារជាថ្មី ដោយសារមានកំហុសបន្តិចបន្តួច នៅក្នុងរយៈពេលដាក់ពាក្យម្តងៗ ដែលកំណត់ត្រូវមានរយៈពេល ៣០ ថ្ងៃ។ កម្មករបាននិយាយផងដែរថា ស្របតាមបញ្ញាតិនៃច្បាប់ TUL សហជីពមិនអាចចុះបញ្ជីបាន រហូតទាល់តែគេបានផ្តល់ព័ត៌មានលំអិតស្តីពីធនាគារសិន តែធនាគារជាច្រើនមិនបើកកុងអោយសហជីពដែលមិនទាន់ចុះបញ្ជីទេ។

សមាគមរបស់អ្នកធ្វើការក្នុងវិស័យសាធារណៈបន្តប្រឈមនឹងឧបសគ្គធំៗ។ ឧទាហរណ៍ នៅក្នុងឆ្នាំនៃរបាយការណ៍នេះ រដ្ឋាភិបាលបានបដិសេធសំណើរបស់សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជាចំនួន ២ ដង ដែលសុំការអនុញ្ញាតដើរហែរក្បួន។ សមាគមវិស័យសាធារណៈមួយទៀត គឺសមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា បាននិយាយពីការខ្លាចការយាយី ការរើសអើង និងការបញ្ចុះឋានៈ។ ទាំងអស់នេះធ្វើអោយម្នាក់ៗមានការរារែកមិនចង់ចូលរួម។

អង្គការពលកម្មអន្តរជាតិ (ILO) បានកត់សំគាល់ពីការរើសអើងទៅលើសហជីពដោយនិយោជក តាមរយៈការជ្រៀតជ្រែកនិងការបណ្តេញសមាជិកនៃសហជីពឯករាជ្យ ព្រមទាំងតាមរយៈការបង្កើតសហជីពគាំទ្រនិយោជក។ គណកម្មាធិការរបស់អង្គការ ILO ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១៧ សំរាប់ធ្វើការលើការអនុវត្តបទដ្ឋាន បានអំពាវនាវអោយរដ្ឋាភិបាលធានាថា សេរីភាពក្នុងការចូលរួមជាក្រុម ជាសមាគមអាចត្រូវបានប្រើនៅក្នុងបរិយាកាសគ្មានការគំរាមកំហែង និងហឹង្សាទៅលើកម្មករ អំពើរើសអើងលើសហជីពត្រូវបានស៊ើបអង្កេតជាប្រញ៉ាប់ ហើយត្រូវមានទណ្ឌកម្មដាក់អោយរាងចាល ហើយធ្វើយ៉ាងណាអោយកម្មករអាចចុះបញ្ជីការសហជីពក្នុងដំណើរការងាយប្រកបដោយយុត្តិធម៌ និងតំលាភាព។

ដំណោះស្រាយជំលោះសមូហភាពមានភាពមិនស៊ីចង្វាក់គ្នា ជាមួយនឹងការកើតមានឡើងយ៉ាងច្រើន នៅក្នុងពេលថ្មីៗនេះ នូវក្រុមជួយដោះស្រាយជំលោះ។ ក្រុមហ៊ុនអន្តរជាតិបាននិយាយជាសាធារណៈ អំពីការធ្វើអោយលែងមានប្រសិទ្ធភាពនូវយន្តការដោះស្រាយជំលោះដែលមានប្រសិទ្ធភាពពីមុនមក បាននាំអោយមានការពិបាក ដោយកម្មករបាននាំជំលោះសមូហភាពរបស់គេដោយផ្ទាល់ទៅអោយក្រុមហ៊ុនជួយដោះស្រាយ។

ជំលោះនិមួយៗក្នុងការងារអាចយកទៅអោយតុលាការដោះស្រាយ ថ្វីបើប្រព័ន្ធតុលាការមានភាពលំអៀង និងគ្មានតំលាភាពក្តី។ គ្មានតុលាការឯកទេសសំរាប់ជំលោះក្នុងការងារទេ។

មានរបាយការណ៍គួរអោយជឿទុកចិត្តថា មានការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងសហជីពពីសំណាក់និយោជក រួមទាំងការបណ្តេញមេដឹកនាំសហជីពក្នុងរោងចក្រកាត់ដេរ និងសហគ្រាសផ្សេងទៀតចេញពីការងារផងដែរ។ នៅខែមករា គំរោងធ្វើរបាយការណ៍ស្តីពីមូលដ្ឋានទិន្នន័យស្តីពីតំលាភាពរបស់កម្មវិធីរោងចក្រល្អនៅកម្ពុជា (BFC) បានទទួលព័ត៌មានពីរោងចក្រចំនួន ៤៨០ ដែលធ្វើការនៅក្នុងវិស័យនាំចេញ ហើយបានកត់សំគាល់ឃើញកំណើនបន្តិចបន្តួចនៃការមិនគោរពតាមសេរីភាពនៃសិទ្ធិចូលរួមក្នុងក្រុមសមាគម រួមទាំងសិទ្ធិរបស់សហជីពក្នុងការចូលរួមក្នុងសហព័ន្ធ និងសហភាពសហព័ន្ធតាមការចង់បានរបស់គេ សិទ្ធិរបស់កម្មករក្នុងការចូលរួមក្នុងសហជីពតាមការចង់បានរបស់គេ ការបង្ខំអោយនិយោជិកចូលរួមនៅក្នុងសហជីពដែលឧបត្ថម្ភដោយនិយោជក និងក្នុងចំនួននៃរោងចក្រដែលថៅកែគ្រប់គ្រងលើសកម្មភាពរបស់សហជីព។ BFC កត់សំគាល់ឃើញមានកំណើនចំនួន ១% នៃចំនួនរោងចក្រដែលក្នុងនោះ សេរីភាពរបស់កម្មករក្នុងការចូលរួម និងបង្កើតសហជីពត្រូវបានរំលោភ។

មេដឹកនាំសហជីពប្រមាណជា ៣៥ នាក់បានអះអាងថា ខ្លួនត្រូវបានថៅកែបណ្តេញចេញពីការងារ ឬព្យួរការងារដោយមិនមានមូលហេតុនៅក្នុងអំឡុងពេល៧ខែដំបូងនៃឆ្នាំរបាយការណ៍នេះ។ នៅក្នុងរោងចក្រមួយចំនួនថៅកែទំនងជាបានបង្កើត ឬគាំទ្រសហជីពដែលគាំទ្រថៅកែ ឬបន្ថយឥទ្ធិពលមេដឹកនាំសហជីព ដោយបង្ករបញ្ហាដល់ការងាររបស់ពួកគេ។

BFC គឺជាកម្មវិធីរបស់អង្គការ ILO ដែលតាមមើលរោងចក្រទាំងអស់ដែលមានអាជ្ញាប័ណ្ណនាំចេញ បានរកឃើញនៅក្នុងរបាយការណ៍របស់ខ្លួនពីខែឧសភា ឆ្នាំ ២០១៦ ដល់ខែមេសាថា ៦,៨% នៃរោងចក្រទាំងអស់បានដកថ្លៃបង់សមាជិកសហជីព ដោយគ្មានការយល់ព្រមដោយសេរីកម្មករ ឬបានរាំងកម្មករមិនអោយបង្កើត ឬចូលរួមក្នុងសហជីព ដោយគំរាមថានឹងបញ្ឈប់ពីការងារ។ ការងាររបស់ BFC គ្របដណ្តប់តែត្រឹមវិស័យនាំចេញទេ ដូច្នេះកំរិតជាក់ស្តែងនៃការយាយីសហជីពទំនងជាមានច្រើនជាងនេះឆ្ងាយ ពិសេសនៅតាមរោងចក្រដែលមិនបានចុះបញ្ជីការ។

ការសិក្សាអង្កេតមួយទៅលើកម្មករកាត់ដេរសំលៀកបំពាក់ ដែលត្រូវបានធ្វើដោយអង្គការមីក្រូហិរញ្ញវត្ថុ (Micro-Finance Organization) បានរកឃើញថា កម្មករនៅក្នុងសហជីពដែលគ្មានចុះបញ្ជីការ ច្រើនតែមានប្រាក់ខែទាបជាងប្រាក់ខែអប្បបរិមាដែលត្រូវបានកំណត់ជាផ្លូវការ។

មានរបាយការណ៍ដ៏គួរអោយទុកចិត្តបានមកថា កម្មករត្រូវបានបណ្តេញពីការងារ ដោយមូលហេតុមិនត្រឹមត្រូវ ក្រោយពីបានរៀបចំ ឬចូលរួមកូដកម្ម ។ ទោះបីជាកូដកម្មភាគច្រើនខុសច្បាប់ក៏ដោយ ក៏ការចូលរួមនៅក្នុងកូដកម្មខុសច្បាប់មិនអាចជា ហេតុផល ដែលអាចទទួលយកបានដោយស្របច្បាប់សម្រាប់ការបណ្តេញកម្មករពីការងារឡើយ ។ ក្នុងករណីមួយចំនួន និយោជកបានគាបសង្កត់អោយកូដករ ឬបុគ្គលិកសហជីពទទួលយកសំណងហើយលាលែងពីការងាររបស់ខ្លួន ដោយលើកហេតុផលថា កុងត្រារយៈពេលខ្លីរបស់គេបានចប់ ។ ចលនាសហជីពជាទូទៅមិនបានមើលឃើញថា រដ្ឋាភិបាលមិនបានដោះស្រាយអ្វីអោយមានប្រសិទ្ធភាពទេ ចំពោះការបណ្តេញចេញបែបនេះ។

## ខ. ការហាមការងារដោយបង្ខំ ឬដោយការតំរូវ

ច្បាប់ហាមប្រាមគ្រប់ទំរង់ទាំងអស់នៃការងារដោយបង្ខំ ឬដោយការតំរូវ។

រដ្ឋាភិបាលមិនបានអនុវត្តច្បាប់នេះអោយមានប្រសិទ្ធភាព នៅក្នុងគ្រប់ករណីទាំងអស់ទេ។ មន្ត្រីនានាបាននិយាយពីការលំបាកនៅក្នុងការបញ្ជាក់ពីស្ថានភាពការងារ និងប្រាក់ខែ នៅក្នុងវិស័យក្រៅផ្លូវការក្នុងផ្នែកនេសាទ កសិកម្ម សំណង់ និងការងារបំរើតាមផ្ទះ។ ពិន័យដែលកំណត់ដោយច្បាប់ ចំពោះការបង្ខំអោយធ្វើពលកម្មគឺមានភាពតឹងតែង ដោយរួមមានទាំងការដាក់ពន្ធនាគារ និងការពិន័យជាប្រាក់។ ថ្វីបើរដ្ឋាភិបាលប្រឹងប្រែងក្នុងការទាញការចាប់អារម្មណ៍ទៅលើការងារដោយបង្ខំនៅក្នុងប្រទេសក្តី តែប្រសិទ្ធភាពនៃការខិតខំទាំងនេះនៅមិនច្បាស់។ លើសពីនេះទៀត មានភស្តុតាងខ្លះដែលបង្ហាញថា និយោជកបានធ្វើការជាមួយសមត្ថកិច្ចមូលដ្ឋានដើម្បីធ្វើអោយកម្មករជាប់ក្នុងទាសភាពបំណុលពលកម្ម ដែលមានដូចជានៅក្នុងឧស្សាហកម្មឡអិដ្ឋ។

នៅខែធ្នូ ឆ្នាំ ២០១៦ នៅពេលអង្គការលីកាដូចេញរបាយការណ៍របស់ខ្លួន ស្តីពីស្ថានភាពនៃកុមារ និងពលកម្មទាសភាពបំណុល នៅតាមឡអិដ្ឋ រដ្ឋមន្ត្រីក្រសួងការងារបានប្រាប់អ្នកសារព័ត៌មានក្នុងស្រុកថា លោកនឹងពិចារណាធ្វើការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ប្រសិនបើរបាយការណ៍នោះត្រូវបានបង្ហាញភស្តុតាងថា មិនពិត។ នៅខែកក្កដា

ក្រោយពីការធ្វើការស៊ើបអង្កេតផ្ទាល់ខ្លួនទៅលើឧស្សាហកម្មឡអិដ្ឋ អ្នកនាំពាក្យក្រសួងបានបដិសេធថាមានពលកម្មកុមារ ឬពលកម្មក្រោមទាសភាពបំណុល នៅតាមរោងចក្រ។ តែមន្ត្រីផ្នែកការងារថ្នាក់ខេត្តបាននិយាយផ្ទុយពីរបាយការណ៍ទាំងនេះ នៅពេលគេនិយាយប្រាប់មន្ត្រីរដ្ឋាភិបាលបរទេស នៅខែកុម្ភៈថា ទាសភាពបំណុលនៅតាមឡអិដ្ឋមានច្រើន នៅគ្រប់កន្លែង។ នៅខែសីហា លោកនាយករដ្ឋមន្ត្រីបាននិយាយប្រឆាំងនឹងទូរទស្សន៍ CNN ពេលទូរទស្សន៍នេះរាយការណ៍ពីស្ថានភាពការងារនៅក្នុងឧស្សាហកម្មឡអិដ្ឋនៅកម្ពុជា។

បំណុលដែលជំពាក់ភាគីទី ៣ នៅតែជាបញ្ហាសំខាន់មួយនៅក្នុងការជំរុញអោយមានពលកម្មដោយបង្ខំ។ បើយោងតាមការរកឃើញនៃការសិក្សាអង្កេតរបស់ BWTUC ដែលត្រូវបានធ្វើនៅក្នុងឆ្នាំនៃរបាយការណ៍នេះ ៤៨% នៃកម្មករសំណង់ចំនួន ១០១០ នៅភ្នំពេញជំពាក់បំណុលគេ ៧៥% នៃពួកគេជំពាក់សហគ្រាសមីក្រូហិរញ្ញវត្ថុឬធនាគារ ហើយមាន ២៥% ជំពាក់លុយសមាជិកគ្រួសារ។

កុមារនៅក្នុងគ្រួសារក្រីក្រប្រឈមនឹងគ្រោះថ្នាក់ ពីព្រោះគ្រួសារអ្នកមានបានប្រើលេសមនុស្សធម៌ដើម្បីជួលកុមារអោយបំរើនៅក្នុងផ្ទះ តែបែរជាធ្វើបាប និងកេងប្រវ័ញ្ចលើពួកគេ (សូមមើលផ្នែក ៧ គ) ។ កុមារក៏ត្រូវបានគេបង្ខំអោយដើរសុំទានផងដែរ។ នៅខែកញ្ញា ប្រធានផ្នែកពលកម្មកុមារនៃក្រសួងការងារបានទទួលស្គាល់ថា ក្រសួងខ្វះធនធានដើម្បីធ្វើអធិការកិច្ចលើពលកម្មកុមារ ដែលបំរើនៅតាមផ្ទះ។

BFC បាននិយាយពីពលកម្មដោយបង្ខំនៅតាមរោងចក្រកាត់ដេរ និងរោងចក្រវាយនភណ្ឌក្នុងវិស័យនាំចេញចំនួន ៦ រោងចក្រ នៅឆ្នាំ ២០១៦-២០១៧។ ភាគច្រើននៃករណីទាំងនេះទាក់ទងនឹងការបង្ខំអោយធ្វើការលើសម៉ោង ដែលក្នុងនោះ កម្មករត្រូវមានការយល់ព្រមពីប្រធានជាបរទេស មុនពេលគេអាចចេញពីរោងចក្របាន។ កម្មករត្អូញត្អែរថា គេខ្លាចគេបញ្ឈប់ពីការងារ បើសិនជាគេមិនព្រមធ្វើការលើសម៉ោង។

សូមមើលផងដែរនូវរបាយការណ៍ ប្រចាំឆ្នាំរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិកដែលមានចំណងជើងថា *របាយការណ៍ស្តីពីការជួញ ដូរមនុស្ស* ដែលមានអាស័យដ្ឋាន www.state.gov/j/tip/rls/tiprpt/ ។

## ខ. សិទ្ធិរៀបចំចងក្រង និងចចារអនុសញ្ញារួម

(The right to organize and bargain collectively)

## ឃ. ការហាមឃាត់ពលកម្មកុមារ និងអាយុអប្បបរិមាដែលអាចធ្វើការបាន

ច្បាប់បានកំណត់ថា អាយុ១៥ឆ្នាំ គឺជាអាយុអប្បបរិមាសម្រាប់បំពេញការងារ និង អាយុ១៨ ឆ្នាំជាអាយុអប្បបរិមាសម្រាប់បំពេញការងារដែលមានគ្រោះថ្នាក់ ។ ច្បាប់អនុញ្ញាតអោយកុមារ អាយុចន្លោះពី១២ ទៅ១៥ឆ្នាំ ធ្វើ "ការងារស្រាល" ដែលមិនមានគ្រោះថ្នាក់ដល់សុខភាព និងមិនប៉ះពាល់ដល់ការសិក្សារបស់គេ ។ ច្បាប់កំណត់ព្រំដែនអោយកុមារដែលស្ថិតក្នុងអាយុពី ១២ ដល់ ១៥ ឆ្នាំ ធ្វើការយ៉ាងច្រើនត្រឹម ៤ ម៉ោងនៅថ្ងៃរៀន និង យ៉ាងច្រើនត្រឹម ៧ ម៉ោងនៅថ្ងៃអត់រៀន ហើយហាមប្រាមការធ្វើការពីម៉ោង ៨ យប់ដល់ម៉ោង ៦ ព្រឹក។ ការការពារចំពោះអាយុអប្បបរិមាគ្មានទេសំរាប់កុមារធ្វើការបំរើតាមផ្ទះ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទទួលខុសត្រូវចំពោះអធិការកិច្ចលើបញ្ហាពលកម្មកុមារ ទាំងនៅក្នុងវិស័យផ្លូវការ និងវិស័យក្រៅផ្លូវការនៃសេដ្ឋកិច្ច។ ក្រុមអធិការកិច្ចការងារមិនបានពង្រឹងការអនុវត្តបទដ្ឋានការងារនៅក្នុងវិស័យក្រៅផ្លូវការ ឬនៅកន្លែងការងារដែលគ្មានអាជ្ញាប័ណ្ណទេ។ នៅក្នុងវិស័យផ្លូវការ ប្រភពនានាបាននិយាយថា ក្រុមអធិការកិច្ចការងារបានធ្វើការត្រួតពិនិត្យជាធម្មតា តែទៅលើរោងចក្រដេរស្បែកជើង និងរោងចក្រកាត់ដេរសំលៀកបំពាក់ដែលបានចុះបញ្ជីការតែប៉ុណ្ណោះ ដែលក្នុងនោះ ករណីពលកម្មកុមារមានតិចមែនទែន។ នៅក្នុងឧស្សាហកម្មដែលច្រើនប្រើពលកម្មកុមារ ដូចជាកសិកម្ម សំណង់ និងបដិសណ្ឋារកិច្ច អធិការកិច្ចត្រូវបានធ្វើតែទៅតាមពាក្យបណ្តឹងតែប៉ុណ្ណោះ ។

ច្បាប់ការងារចែងពីការពិន័យជាប្រាក់ចំនួនពី ៣១ ដងទៅ ៦០ ដងនសប្រាក់ខែបច្ចុប្បន្ន ចំពោះជនដែលរំលោភលើបញ្ញាតិរបស់ជាតិស្តីពីពលកម្មកុមារ។ រដ្ឋាភិបាលបានផ្អាកអធិការកិច្ចទាំងអស់លើពលកម្មកុមារ នៅក្នុងឆមាសទីមួយនៃឆ្នាំធ្វើរបាយការណ៍នេះ ដោយសារក្រសួងការងារបាននិយាយថា ខ្លួនមិនទាន់អាចទទួលយកការងាររបស់គំរោងលុបបំបាត់ពលកម្មកុមារក្រោមការកេងប្រវ័ញ្ច តាមរយៈការអប់រំ និងការបង្កើតមុខរបរទ្រទ្រង់ជីវភាពរបស់អង្គការទស្សនៈពិភពលោក។ នៅខែឧសភា ប្រធានផ្នែកពលកម្មកុមារបាននិយាយថា ការធ្វើអធិការកិច្ចនឹងចាប់ផ្តើមជាថ្មី តែមិនពេញលេញទេ។ នាយកដ្ឋាននេះធ្វើការជាមួយពលករចំណាកស្រុក នៅខេត្តបន្ទាយមានជ័យ នៅតាម

ព្រំដែនជាមួយថៃ ដើម្បីនាំមកវិញនូវកុមារធ្វើពលកម្មចំនួនប្រហែល ៥០០ នាក់។ មន្ត្រីក៏បានចុះទៅមើលចំការអំពៅចំនួន ២ ដង នៅខេត្តកោះកុង ដោយគេបានរាយការណ៍ថា គ្មានកុមារធ្វើពលកម្មទេ តែបាននិយាយថា គេបានលើកឡើងពីកង្វល់ទាក់ទងនឹងការសិក្សា ហើយនិងសុខភាព។

ពលកម្មកុមារមានច្រើននៅក្នុងការងារកសិកម្ម ដែលរួមមានក្នុងផលិតកម្មកៅស៊ូ និងអំពៅ ការកាប់ឈើ ការកែច្នៃបង្គារ ការនេសាទ សិប្បកម្មឡឥដ្ឋ កន្លែងធ្វើអំបិល ការបម្រើតាមផ្ទះ ការជួសជុលឡាន វាយនភណ្ឌ សត្តឃាត និងការផលិតស្រា ស្រាបៀរ។ កុមារក៏ធ្វើការផងដែរជាអ្នកសុំទាន អ្នកលក់ដូរតាមផ្លូវ អ្នកខាត់ស្បែកជើង និងអ្នកដើររើសរបស់អេតចាយ។

BFC បានបញ្ជាក់ថា មានករណីចំនួន ៤ នៃពលកម្មកុមារ នៅក្នុងរោងចក្រសំលៀកបំពាក់ និងស្បែកជើងសំរាប់នាំចេញ ពីខែឧសភា ឆ្នាំ ២០១៦ ដល់ខែមេសា។ នៅឆ្នាំ ២០១៥ ២០១៦ មាន១៦ ករណី ៣០ ករណីនៅឆ្នាំ ២០១៤ ២០១៥ និង ៧៤ ករណីនៅឆ្នាំ ២០១៣ ២០១៤។ នៅក្នុងករណីមួយក្នុងចំណោមករណីទាំង ៤ រោងចក្រមិនព្រមចូលរួមនៅក្នុងកម្មវិធីដោះស្រាយឡើងវិញ តាមការចាំបាច់ទេ។

សូមចូលមើលផងដែរនូវលទ្ធផលរកឃើញស្តីពីទំរង់អាក្រក់បំផុតនៃពលកម្មកុមាររបស់ក្រសួងការងារសហរដ្ឋអាមេរិក តាមគេហទំព័រ WWW.dol.gov/ilab/reports/child-labor/findings/។

**ឃ. ការរើសអើងទាក់ទងនឹងការងារ**

ច្បាប់ហាមការរើសអើងក្នុងការងារ ដោយសារពូជសាសន៍ ពណ៌សម្បុរ ភេទ ពិការភាព សាសនានា គំនិតនយោបាយ កំណើត ប្រភពដើមក្នុងសង្គម ឬសមាជិកភាពក្នុងសហជីពទេ។ ច្បាប់ពីរដាច់ដោយឡែកពីគ្នាហាមយ៉ាងច្បាស់នូវការរើសអើង ដោយសារតែការមានមេរោគអេដស៍។ ច្បាប់មិនហាមច្បាស់នូវការរើសអើងដោយផ្អែកលើចំណង់ផ្លូវភេទ អត្តសញ្ញាណជេនឌ័រ អាយុ ភាសា ឬជំងឺឆ្លងទេ។ រដ្ឋធម្មនុញ្ញចែងថា ពលរដ្ឋទាំងពីរភេទទទួលបានប្រាក់បៀវត្សស្មើគ្នា ចំពោះការងារស្មើគ្នា។

ជាទូទៅ រដ្ឋាភិបាលមិនពង្រឹងការគោរពចំពោះច្បាប់ទាំងនេះទេ។ តាមច្បាប់ ទណ្ឌកម្មចំពោះការរើសអើងក្នុងការងាររួមមានការពិន័យជាប្រាក់ សំណងប៉ះប៉ូវរដ្ឋប្បវេណី និងរដ្ឋបាល។ ប្រាក់ពិន័យចំពោះការងាររើសអើងក្នុងការងារមានពី ២,៥ ទៅ ៣,៦ លានរៀល (៦២៥ដុល្លា ទៅ ៩០០ ដុល្លា)។

បើយោងតាមការសិក្សាអង្កេតមួយរបស់ BWTUC ការងារប្រចាំថ្ងៃសំរាប់កម្មករសំណង់ជាប្រុសមានប្រាក់ឈ្នួល ២០,២% ច្រើនជាងប្រាក់ឈ្នួលសំរាប់ការងារដូចគ្នារបស់កម្មការិនី។ កម្មវិធី BFC បាននិយាយថា នៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ និងស្បែកជើង ថៅកែរោងចក្ររើសអើងយ៉ាងខ្លាំងទៅលើបុរសក្នុងការរើសជ្រើសរើសចូលធ្វើការ និងការផ្តល់ប្រាក់បំណាច់ ដោយជាទូទៅ គ្មានរងផលវិបាកផ្លូវច្បាប់ឡើយ។ BFC បាននិយាយថា ៩% នៃរោងចក្រដែលមានអាជ្ញាប័ណ្ណសំរាប់ការនាំចេញ មានការរើសអើងផ្នែកជេនឌ័រ ដោយមានកំរិតធ្លាក់ចុះពីចំនួន ១០% នៅឆ្នាំ ២០១៦។ មូលហេតុរួមមានរោងចក្រមិនចង់ជួលបុរស ដោយសារគេគិតថា មានបញ្ហាទាក់ទងនឹងអាកប្បកិរិយា ព្រមទាំងការរើសអើងលើនារី ដោយសារមានកង្វល់ពីការមានផ្ទៃពោះ ឬការឈប់សំរាកឆ្លងទន្លេ។

គំរោងស្រាវជ្រាវខ្នាតធំមួយ ដែលធ្វើដោយអង្គការ Care International បានរកឃើញថា ចំនួន ១ ភាគ ៣ នៃនារីនៅក្នុងឧស្សាហកម្មកាត់ដេរបានទទួលរងនូវការយាយីផ្លូវភេទ នៅក្នុងរយៈពេល ១២ ខែមុន។ សមាគមនរោងចក្រកាត់ដេរកម្ពុជាបានបដិសេធលទ្ធផលរកឃើញនេះ ដោយអះអាងថា ចំនួនពិតប្រាកដគឺទាបជាងនេះឆ្ងាយ។ សហជីពឯករាជ្យ ជាទូទៅ គាំទ្រការអះអាងនៃរបាយការណ៍នេះ ដោយកត់សំគាល់ថា វាត្រូវទៅតាមបទពិសោធន៍របស់គេផ្ទាល់។

**ខ. លក្ខខណ្ឌការងារដែលអាចទទួលយកបាន**

ច្បាប់ផ្តល់អំណាចអោយអាជ្ញាធរសហភាពការងារកំណត់ប្រាក់ឈ្នួលអប្បបរមា ផ្អែកតាមអនុសាសន៍របស់គណៈកម្មាធិការប្រឹក្សាការងារ ដែលជាក្រុមមានបីភាគី ដែលមានតំណាងមកពីរដ្ឋាភិបាល សហជីព និងស្ថាប័ននិយោជក ។ រឿងបៀវត្សអប្បបរមាបានរងការជ្រៀតជ្រែកពីអ្នកនយោបាយ តាំងពីឆ្នាំ ២០១៣ មក នៅពេលដែលក្រុមខ្លះក្នុងចលនាសហជីពទាមទារសុំដំឡើង នៅចំពេលមានការរំជើបរំជួលជុំវិញការតវ៉ាទាក់ទងនឹងការបោះឆ្នោត។

ច្បាប់ការងារឆ្នាំ ១៩៩៧ មានចែងអំពីរយៈពេលធ្វើការប្រចាំសប្តាហ៍តាមបទដ្ឋានស្របច្បាប់ចំនួន ៤៨ម៉ោង មិនអោយ លើសពី ៨ ម៉ោងក្នុងមួយថ្ងៃឡើយ ។ ច្បាប់កំណត់អត្រា ១៣០ ភាគរយនៃប្រាក់ឈ្នួលធ្វើការនៅពេលថ្ងៃ សម្រាប់វេនការងារនៅពេលយប់ និង ១៥០ ភាគរយសម្រាប់ការងារបន្ថែមម៉ោង ដែលត្រូវកើនឡើងដល់ ២០០ ភាគរយ ប្រសិនបើការងារលើសម៉ោងនោះកើតមានឡើងនៅពេលយប់ នៅថ្ងៃអាទិត្យ ឬនៅថ្ងៃឈប់សម្រាក ។ និយោជិកត្រូវបានអនុញ្ញាតអោយធ្វើការលើសម៉ោងយ៉ាងច្រើន ២ ម៉ោងក្នុងមួយថ្ងៃ។ ច្បាប់ហាមការធ្វើការលើសម៉ោងជ្រុល

ចែងថា ការធ្វើការលើសម៉ោងទាំងអស់ត្រូវតែទៅតាមការស្ម័គ្រចិត្ត ហើយចែងពីការឈប់សំរាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល។

រដ្ឋាភិបាលមិនបានពង្រឹងការអនុវត្តច្បាប់ទំលាប់ស្តីពីម៉ោងការងារ និងការងារថែមម៉ោង ប្រកបដោយប្រសិទ្ធភាពឡើយ ។ កម្មករបានរាយការណ៍ថា ការងារលើសម៉ោងច្រើនហួសកម្រិត ហើយជួនកាលគេតំរូវអោយធ្វើជាចាំបាច់ទៀតផង ។ នៅក្រៅឧស្សាហកម្មកាត់ដេរ បទប្បញ្ញត្តិអំពីម៉ោងធ្វើការកម្រត្រូវបានអនុវត្តណាស់ ។ ជារឿយៗ កម្មករត្រូវប្រឈមនឹងការផាកពិន័យ ការបណ្តេញពីការងារ ឬការបាត់បង់ប្រាក់រង្វាន់ ប្រសិនបើកម្មករទាំងនោះបដិសេធមិនធ្វើការបន្ថែមម៉ោង ។

ច្បាប់ចែងថា កន្លែងធ្វើការត្រូវគោរពតាមបទដ្ឋានអនាម័យ និងសុវត្ថិភាពគ្រប់គ្រាន់ដើម្បីផ្តល់សុខមាលភាពដល់កម្មករ ។ អធិការរបស់ក្រសួងការងារវាយតំលៃប្រាក់ពិន័យ ដោយយោងទៅតាមរូបមន្តស្មុគស្មាញផ្អែកលើភាពធ្ងន់ធ្ងរ និងរយៈពេលនៃកំហុស ព្រមជាមួយនឹងចំនួនកម្មករដែលទទួលរង។ អធិការរបស់ក្រសួងការងារមានអំណាចវាយតំលៃប្រាក់ពិន័យទាំងនេះ នៅនឹងកន្លែង ដោយមិនបាច់មានការសហការពីនគរបាលទេ តែគ្មានបទបញ្ញាតិជាក់ច្បាស់ណាមួយសំរាប់ការពារកម្មករ ដែលតវ៉ាពីស្ថានភាពប៉ះពាល់ដល់សុខភាព ឬគ្មានសុវត្ថិភាពទេ។

អ្នកធ្វើការក្នុងឧស្សាហកម្មដឹកជញ្ជូនតាមយន្តហោះ និងនាវាគ្មានសិទ្ធិទទួលបានប្រាក់ធានាសង្គមកិច្ច និងប្រាក់ចូលនិវត្តន៍ទេ ហើយត្រូវបានលើកលែងពីការកំរិតព្រំដែនលើម៉ោងការងារ ដែលចែងដោយច្បាប់។ ការសិក្សាអង្កេតមួយដែលត្រូវបានធ្វើដោយ BWTUC បានប៉ាន់ប្រមាណថា មានប្រជាជនចំនួន ២០០ ០០០ នាក់កំពុងធ្វើការផ្នែកសំណង់ ៨៩% នៃអ្នកឆ្លើយចំនួន ១០១០ នាក់គ្មានកុងត្រា ហើយភាគច្រើនមិនដែលបានទទួលប្រាក់រង្វាន់បន្ថែម ឬប្រាក់បើកផ្តាច់អោយពេលឈប់ធ្វើការទេ ហើយមានតែ ៩% មានឈ្មោះនៅក្នុងមូលនិធិសន្តិសុខសង្គមជាតិ (NSSF) ។ អង្គការ Human Rights Watch បាននិយាយនៅឆ្នាំ ២០១៦ ថា កម្មកររោងចក្រកាត់ដេរនៅតាមរោងចក្រដែលគ្មានចុះបញ្ជីការ ដោយភាគច្រើនជាអ្នកម៉ៅការបន្តអោយរោងចក្រធំ សំរាប់ការនាំចេញ ងាយរងនឹងការធ្វើបាបក្នុងការងារ ដែលជាការរំលោភលើច្បាប់ក្នុងស្រុក និងច្បាប់អន្តរជាតិ។

រដ្ឋាភិបាលបានអនុវត្តបទដ្ឋានដែលមានស្រាប់មិនបានអស់ទេ  ម្យ៉ាងដោយសារខ្លួន ខ្វះបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ និងបរិក្ខារចាំបាច់ ហើយនិងអំពើពុករលួយ ។ មន្ត្រីរបស់ក្រសួងការងារបានសារភាពពីភាពអសមត្ថភាព នៅក្នុងការធ្វើអធិការកិច្ចពេញលេញ នៅក្នុងម៉ោងការងារ។ នាយកដ្ឋានអធិការកិច្ចការងាររបស់

ក្រសួងបានចេញសេចក្តីព្រមានចំនួន ៣៣០ អំពីការរំលោភច្បាប់ការងារ នៅក្នុងរយៈពេល ៦ ខែដំបូង ដោយមានការកើនឡើងពីចំនួន ១៨៣ នៅក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។ នាយកដ្ឋានថែមទាំងបានផាកពិន័យលើក្រុមហ៊ុនចំនួន ២៧ ដែលជាចំនួនលើសពីចំនួន ១៩ នៅឆ្នាំ ២០១៦ ហើយបានប្តឹងសហគ្រាសចំនួន ២ ទៅតុលាការ។ ក្រសួងបាននិយាយថា ខ្លួនមានអធិការកិច្ចការងារចំនួន ៤៩៩ នាក់ បូកនឹងអធិការកិច្ចមកពី NSSF ចំនួន ៨៧ នាក់ នៅទូទាំងប្រទេស។ ចំនួននេះមិនគ្រប់គ្រាន់ទេសំរាប់ធ្វើការងារអធិការកិច្ចអោយបានពេញលេញ។ ទណ្ឌកម្មមានភាពមិនគ្រប់គ្រាន់សំរាប់ដោះស្រាយបញ្ហា។ ថ្វីបើ ជាញឹកញាប់ ក្រសួងសំរេចអោយកម្មករឈ្នះ តែខ្លួនកម្រប្រើសិទ្ធិស្របច្បាប់របស់ខ្លួនដើម្បីដាក់ទណ្ឌកម្មទៅលើថៅកែ ដែលមិនគោរពតាមបទបញ្ជា។

គេមានកង្វល់ផងដែរថា ការប្រើកុងត្រារយៈពេលខ្លី (FDC) ពិសេសនៅក្នុងវិស័យកាត់ដេរ ដែលកំណើននៃផលិតភាពច្រើននៅទ្រឹងមិនឡើង អនុញ្ញាតអោយក្រុមហ៊ុនគេចផុតពីលក្ខខ័ណ្ឌទាមទារខ្លះតាមច្បាប់ និងលើប្រាក់បៀវត្ស។ កុងត្រារយៈពេលខ្លីមានត្រឹម ២៤ ខែ ហើយក្រសួងការងារបានបកស្រាយថា វាមានន័យថា ២៤ ខែជាប់គ្នា ដែលជាការអនុញ្ញាតអោយនិយោជករក្សាអោយកម្មករធ្វើការតាមកុងត្រារយៈពេលខ្លី ដែលភាគច្រើន រយៈពេល ៣ ខែ ប្រសិនបើមានការដាច់ក្នុងការងាររវាល់រយៈពេល ២៤ ខែ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងអង្គការ ILO បានជំទាស់នឹងការបកស្រាយច្បាប់នេះ ដោយទទូចថា ក្រោយរយៈពេល ២៤ ខែ កម្មករត្រូវតែទទួលបាន "កុងត្រាដែលមានរយៈពេលមិនកំណត់" អចិន្ត្រៃយ៍។ ការបកស្រាយរបស់ក្រសួងការងារមានផលវិបាកធ្វើអោយប៉ះពាល់ដល់ការងារសហជីព ដោយសារកម្មករដែលធ្វើការតាមកុងត្រាបណ្តោះអាសន្ន បាននិយាយថា បានរងការគំរាមកំហែងបណ្តេញចេញពីការងារ ជាការសងសឹកចំពោះសកម្មភាពសហជីព។

របួសក្នុងពេលធ្វើការងារ និងបញ្ហាសុខភាពកើតមានឡើងជាញឹកញាប់ ។ រោងចក្រកាត់ដេរធំៗ ភាគច្រើនដែលផលិតសម្រាប់ទីផ្សារនៅប្រទេសអភិវឌ្ឍ បានបំពេញបានល្អគួរសមតាមបទដ្ឋានអនាម័យ និងសុវត្ថិភាពការងារដែលជាលក្ខខណ្ឌសម្រាប់ចុះកិច្ចសន្យាជាមួយអតិថិជនទិញនៃផលិតផលរបស់ខ្លួន ។ ស្ថានភាពការងារនៅតាមរោងចក្រខ្នាតតូចមួយចំនួន និងឧស្សាហកម្មតូចៗ មានលក្ខណៈទន់ខ្សោយ ហើយជារឿយៗ មិនបានបំពេញតាមបទដ្ឋានអន្តរជាតិទេ ។ NSSF បាននិយាយថា នៅក្នុងរយៈពេល ៦ ខែដំបូងនៃឆ្នាំ ២០១៦ មានកម្មករចំនួន ២៣ ០៩៤ នាក់បានរងរបួសក្នុងការងារ ដោយចំនួននេះមានលើសពីចំនួន ១៦ ០៨០ នៅក្នុងឆ្នាំ ២០១៥ ហើយថា មានកម្មករចំនួន ១០៨ នាក់បានស្លាប់ នៅពេលកំពុងបំពេញការងារ នៅក្នុងឆ្នាំនៃរបាយការណ៍នេះ ដោយគិតមកត្រឹមខែតុលា ដោយនៅក្នុងរយៈពេលដូចគ្នា ក្នុងឆ្នាំ ២០១៦ មានស្លាប់ចំនួន ៨៤ នាក់។ ក្នុងចំណោមអ្នកស្លាប់ទាំង ១០៨ នាក់ NSSF បាននិយាយ

ថា មាន២៥ នាក់បានស្លាប់ដោយសារគ្រោះថ្នាក់ចរាចរ។ ផ្នែកព័ត៌មានក្នុងស្រុកបាននិយាយថា មានយ៉ាងហោច ណាស់ការផ្ទុះផ្ទាំងចំហុយចំនួន ៤ នៅក្នុងរោងចក្រកាត់ដេរ ហើយបានសំលាប់កម្មករចំនួន ៣ នាក់ និងធ្វើអោយរបួស ចំនួន ៣៤ នាក់ផ្សេងទៀត។ អ្នកជំនាញនៅក្រសួងឧស្សាហកម្ម និងសិប្បកម្មបានបន្ទោសការផ្ទុះនោះទៅលើការ ប្រហែសរបស់កម្មករម្នាក់ៗ។ តែអ្នកជំនាញដដែលនោះបានកត់សំគាល់ផងដែរពីកង្វះឧបករណ៍ និងគ្រឿងប្រដាប់សំ រាប់ធ្វើអធិការកិច្ចអោយបានត្រឹមត្រូវ។

នៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន គិតពីខែឧសភា ឆ្នាំ ២០១៦ ដល់ខែមេសា BFC បាននិយាយថា បញ្ហា សុខភាព និងសុវត្ថិភាពក្នុងការងារជាច្រើនគឺជាបញ្ហាដែលចេះតែមានច្រើនឡើងសំរាប់រោងចក្រកាត់ដេរសំលៀក បំពាក់ នៅក្នុងវិស័យនាំចេញ ដោយសារនិតិវិធី គោលនយោបាយក្រុមហ៊ុនមិនសមស្រប ហើយនិងការទទួលខុសត្រូវ និងតួនាទីគ្រប់គ្រងមិនត្រូវបានកំណត់ច្បាស់។ BFC បាននិយាយពីកំណើននៃការមិនគោរពតាម នៅក្នុងគ្រប់បញ្ហាផ្នែក សុខភាព និងសុវត្ថិភាពក្នុងការងារ ដោយមានរួមទាំងការរងនឹងចំហាយជាតិគីមី និងសារធាតុគ្រោះថ្នាក់ ការត្រៀមបំ រុងសំរាប់គ្រាអាសន្ន និងប្រព័ន្ធគ្រប់គ្រងបញ្ហាសុខភាព និងសុវត្ថិភាពក្នុងការងារ កន្លែងផ្តល់សុខមាលភាព បរិយាកាសសំរាប់កម្មករ ការការពារកម្មករ និងកន្លែងស្នាក់នៅរបស់កម្មករ។

ការដួលសន្លប់ទាំងហ្វូងៗនៅតែជាបញ្ហាមួយនៅឡើយ។ NSSF បាននិយាយថា កម្មករចំនួន ៤១៥ នាក់បានដួលសន្លប់ នៅក្នុងរោងចក្រចំនួន ៨ គិតពីខែមករា ដល់ខែមិថុនា ដោយថយចុះពីចំនួន ៥៣៨ នាក់ នៅក្នុង រយៈពេលដូចគ្នានៃឆ្នាំ ២០១៦។ គ្មានសេចក្តីរាយការណ៍ពីរបួសធ្ងន់ដោយសារការសន្លប់ទេ។ អ្នកសង្កេតការណ៍បាន និយាយពីការធ្វើការលើសម៉ោងជ្រុល សុខភាពទ្រុឌទ្រោម ការដេកមិនគ្រប់ ខ្យល់ចេញចូលមិនល្អ កង្វះអាហារូបត្ថម្ភ ត្រឹមត្រូវសំរាប់កម្មករ ថ្នាំសំលាប់សត្វចង្រៃត្រូវបានបាញ់នៅក្នុងវាលស្រែក្បែរខាង និងចំហាយជាតិពុលចេញមកពី សកម្មភាពផលិតកម្ម ទាំងអស់នេះនាំអោយកម្មករសន្លប់ច្រើនគ្នា។